វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ
REGIONAL POLYTECHNIC INSTITUTE TECHO SEN TAKEO

# ផលិតកម្មសត្វស្លាប

## POULTRY PRODUCTION

រៀបចំ និងបង្រៀនដោយ លោកគ្រូ ឃឹម សាម៉ៃ

រៀបរៀងឆ្នាំ២០២៥

# មាតិកា

១. ការចិញ្ចឹមសត្វស្លាប
២. លក្ខណៈជីវសាស្ត្រនិងចំណុចសំខាន់ៗនៃសត្វស្លាប
៣. ការជ្រើសរើសពូជក្នុងការចិញ្ចឹម
៤. ការភ្ញាស់ស៊ុត
៥. ការជ្រើសរើសទីតាំងនិងប្រព័ន្ធចិញ្ចឹមមាន់នៅក្នុងកសិដ្ឋាន
៦. ការផ្គត់ផ្គង់ចំណីសំរាប់មាន់
៧. ការចិញ្ចឹមកូនមាន់
៨. ការចិញ្ចឹមមាន់ជំទង់
៩. ការចិញ្ចឹមមាន់ពង
១០. ការចិញ្ចឹមមាន់ពងពូជ
១១. ការចិញ្ចឹមមាន់ពងអាជីវកម្ម
១២. ការចិញ្ចឹមមាន់សាច់
១៣. ការចិញ្ចឹមមាន់គ្រៀវ
១៤. ករណីដែលត្រូវយល់ដឹងក្នុងការចិញ្ចឹមមាន់
១៥. ជំងឺមួយចំនួនដែលតែងតែជួបនៅលើសត្វមាន់
១៦. ការចិញ្ចឹមក្រួច

# គោលបំណង

## បន្ទាប់ពីបញ្ចប់មេរៀននេះនិស្សិតអាចៈ

- យល់ច្បាស់ពីផលប្រយោជន៍នៃការចិញ្ចឹមសត្វស្លាប
- យល់ច្បាស់ពីបច្ចេកទេសចិញ្ចឹម និងរយៈ ពេលចិញ្ចឹម
- ធ្វើសេចក្តីសំម្រេចចិត្តយ៉ាងត្រឹមត្រូវក្នុងការជំរើសការពូជសត្វចិញ្ចឹម។

# ខ្លឹមសារសំខាន់

- សារៈប្រយោជន៍នៃការចិញ្ចឹមសត្វស្លាប
- ធ្វើសេចក្តីសំរេចចិត្តដ៏មានជ័យជំនះ

# មេរៀនទី១ ការចិញ្ចឹមសត្វស្លាប

## ១.អត្ថន័យក្នុងការចិញ្ចឹមសត្វស្លាប

កម្រិតកើនឡើងយ៉ាងឆាប់រហ័សរបស់សត្វស្លាប គឺជាលក្ខណៈពិសេសនៃការលូតលាស់របស់បណ្ដាកសិដ្ឋានចិញ្ចឹមសត្វ។

ការផលិតផ្នែកចិញ្ចឹមសត្វស្លាបបាន កើនឡើងជាលំដាប់ជំរុញឲ្យជីវភាពរបស់មនុស្សគ្រប់សញ្ជាតិមានជីវភាពធូរធារ អាស្រ័យដោយការកើនឡើងទិន្នផលនៃបច្ចេកទេសចិញ្ចឹមមានការរីកចម្រើន។

បច្ចុប្បន្ននេះសេចក្តីត្រូវការរបស់មនុស្សគ្រប់រូបលើពិភពលោកមានតម្រូវការពីសាច់ និងស៊ុត ក៏បានកើនឡើងជាលំដាប់ផងដែរ។ ដូច្នេះការប្រមូលប្រូតេអ៊ីនសម្រាប់សេចក្តីត្រូវការរបស់មនុស្សមួយភាគធំបានស្រូបយកមកពីផ្នែកចិញ្ចឹមសត្វស្លាប។ ចំពោះស៊ុតសត្វស្លាបគេពិនិត្យឃើញថា ក្នុងផ្នែកឧស្សាហកម្មគេមិនសូវយកទៅកែច្នៃទេ គឺគ្រាន់តែជាសេចក្តីត្រូវរបស់មនុស្សតែប៉ុណ្ណោះ។

## ២.ផលប្រយោជន៍ការចិញ្ចឹមមាន់ជាលក្ខណៈពាក់កណ្ដាលឧស្សាហកម្ម

### ក. ល្បឿននៃការបន្តពូជឆាប់រហ័ស



ជារៀងរាល់ឆ្នាំពូជមាន់អាចផ្តល់ស៊ុត មានលទ្ធភាពអាចពងបាន២៥០ ទៅ៣០០ស៊ុតក្នុងមួយក្បាល។ ចំណែកពូជមាន់ផ្តល់សាច់ផងនិងស៊ុតផងមានលទ្ធភាពពងបាន ពី ១០០ទៅ ១៥០ ស៊ុតមួយក្បាល។

ចំពោះការបន្តពូជបើសិនជាយើងជ្រើសរើសយកស៊ុតសម្រាប់ ភ្ញាស់ ឱ្យត្រូវទៅតាម លក្ខណៈបច្ចេកទេស នោះគឺវាអាចផ្តល់កូនបានពី ២០០ ទៅ២២០ កូនក្នុងមួយក្បាល ។ ដូច្នេះលទ្ធភាពបង្កើតហ្វូង មាន់កើនយ៉ាងឆាប់រហ័សជាងការចិញ្ចឹមសត្វផ្សេងៗ

ទៀត។

## ខ. ល្បឿនលូតលាស់របស់មាន់ផ្តល់សាច់

ក្នុងកូនមាន់មួយក្បាលដែលទើបនឹងញាស់ គឺមានទម្ងន់ប្រហែលពី ៣៥-៤0g តែក្រោយពេលចិញ្ចឹមរយៈពេល ៨-១០ អាទិត្យគឺអាចឡើងទម្ងន់ពី ១.៥ទៅ ២.៥ Kg។ ដូច្នេះនៅក្នុងរយៈ ពេលពី ២-២.៥ខែទម្ងន់របស់វាអាចកើនឡើង ៤0- ៥0 ដងធៀបទៅនឹង ទម្ងន់ដែលទើបនឹងញាស់។

## គ. ការបម្លែងពីចំណីទៅជាសាច់នឹងស៊ុត

មានលទ្ធភាពល្អបំផុតគឺដើម្បីផលិតចេញជាសាច់ ១ kg គេប្រើចំណីផ្សំស្រេចអស់ប្រមាណ ២.៥ kg។

វដ្តនៃការផលិតបន្តពូជរបស់មាន់មានច្រើនដងសមស្របទៅ និងសេចក្តី ត្រូវការរបស់មនុស្ស។រយៈពេលចិញ្ចឹមនៃបណ្តាប្រភេទសត្វតាមបែបឧស្សាហកម្មមាន ដូចខាងក្រោម :



- ❑ - រយៈពេលមាន់ផ្តល់សាច់២ខែ
- ❑ - រយៈពេលជ្រូកផ្តល់សាច់៦សាច់
- ❑ - រយៈពេលមាន់ផ្តល់ស៊ុត ១៨អាទិត្យ (ជាង៤ខែ )
- ❑ - រយៈពេលគោផ្តល់សាច់ ១២-២៤ ខែ។

## ឃ.អំពីទ្រុងចិញ្ចឹម

គឺសង់ឡើងជាមួយនឹងវត្ថុស្រាល ថោកល្មម ផ្ទៃចិញ្ចឹមតូច ហើយមាន របៀប ។ បញ្ហាគ្រួសាររស់នៅទីក្រុងក៏អាចកែឆ្នៃចិញ្ចឹមមាន់បែបឧស្សាហ៍កម្មបានដែរ ប៉ុន្តែត្រូវរក្សា អនាម័យជានិច្ច ។

ក្នុងលក្ខណៈចិញ្ចឹមបែបធំៗគេបានអនុវត្តតាមរបៀបស្វ័យកម្មដែលផ្តល់ប្រយោជន៍ច្រើន ។




## ង. ផលិតផលនៃការចិញ្ចឹម

ផលិតផលដែលបានមកពីការចិញ្ចឹមសត្វគឺ : ស៊ុត . សាច់ ។ហើយថាមពលដែលផ្តល់មកពី សាច់. ស៊ុតនិងទឹកដោះគឺ :

| | protein ( g ) | kcal |
|---|---|---|
| • សាច់ជ្រូក | ១០០ | ៤០៤ |
| • ទឹកដោះ | ៣.៦ | ៦៧ |
| • សាច់គោ (ពេញវ័យ) | ១៨.១ | ២៨៦ |
| • សាច់កូនគោ (មិនលើសពី១៨ខែ) | ១៩.៥ | ១២៤ |
| • សាច់មាន់ | ២១.៥ | ១១៣ |
| • សាច់ទា | ២០ | ១៨០ |
| • ស៊ុត | ១៣.៥ | ១៦៩ |

សាច់ និង ស៊ុតសំបូរទៅដោយប្រូតេអ៊ីននិងវិតាមីនដែលមានលក្ខណៈឆាប់រលាយហើយ អាច កែឆ្នៃ ទៅម្ហូបដែលមានគុណភាពក្នុងការបំប៉ន ។

ច/អនុផលនៃការចិញ្ចឹមសត្វស្លាប

លាមកមាន់មានគុណភាពខ្ពស់បើប្រៀបធៀបទៅនឹងជីនឹងសរីរាង្គដ៏ទៃទៀត ។ចំណែករោម សត្វស្លាបក៏មាន ប្រយោជន៍ដែរ គឺរោមឆ្មារ ១ យើងអាចធ្វើជាគសំរាប់ច្រកខ្នើយរឺពូកនិងធ្វើជារបស់ ផ្សេង ៗ ទៀត ។

ចំណែករោមប្រភេទរឹងអាចយកទៅធ្វើជាម្សៅរោមដែលសំបូរទៅដោយប្រូតេអ៊ីន ទៅក្នុងចំណីពី ១-២% ។

រាល់បញ្ហាគុណសម្បត្តិខាងលើ បានបង្ហាញអំពីការលូតលាស់នៃផ្នែកចិញ្ចឹមសត្វស្លាបបែបឧស្សាហកម្មបាន កើនឡើងឆាប់រហ័សនិងជារៀងរាល់ឆ្នាំមានបណ្តាប្រទេសមួយចំនួនអាចពង្រីកផ្នែកនេះបានកើនឡើងពី ២០-៣០% ។

៣.លទ្ធផលចិញ្ចឹមសត្វស្លាបនិងភាពរីកចំរើននៅលើពិភពលោក :

គេពុំបានធ្វើស្ថិតិអោយបានពិតប្រាកដ ស្តីពីការរីកចំរើនផ្នែកចិញ្ចឹមសត្វស្លាបនៅលើពិភពលោកទេព្រោះបណ្តាប្រទេសខ្លះគ្រាន់តែធ្វើស្ថិតិនៅតំបន់ខ្លះ ៗ និងប្រទេសខ្លះទៀតពុំបានធ្វើទៀតផង ។ នៅឆ្នាំ ១៩៥៩-៦០ នៅប្រទេសប្រេស៊ីលមានទាចំនួន៥.៩លានក្បាលនៅហ្វីលីពីមានទា ចំនួន ២.៣ លាន ក្បាលនៅអាល្លឺម៉ង់ខាងលិចមានទាចំនួន ១.៧លានក្បាល នៅហូឡង់មានទាចំនួន ១.៥លានក្បាល និង នៅអង់គ្លេសមានទាចំនួន១.៣លានក្បាល ។ នៅឆ្នាំ ១៩៦៣ មានមាន់នៅអាមេរិកចំនួន៣៦៤លាន ក្បាល នៅកាណាដាមានមាន់ចំនួន ៨៧.៦លានក្បានៅបារាំងមានមាន់ចំនួន ៧៦.៦លាន ក្បាលនិងនៅអាល្លឺម៉ង់ខាងលិចមានមាន់ចំនួន៦៧.៥ លានក្បាល។

## លទ្ធភាពផ្គត់ផ្គង់ពងមាន់ចំពោះបណ្តាប្រទេសមួយចំនួន

| ឈ្មោះប្រទេស | ឆ្នាំ | ចំនួនពង/ក្បាល/ឆ្នាំ |
|---|---|---|
| Belgique | 1963 | 200 |
| U.S.A | 1963 | 211 |
| Japan | 1963 | 211 |
| Holland | 1963 | 215 |
| Anglais | 1963 | 201 |
| Su.ait | 1963 | 190 |
| Alemand | 1963 | 188 |
| Danamak | 1963 | 180 |
| Alemamd | 1963 | 141 |
| France | 1963 | 160 |
| Suise | 1963 | 156 |

ជាមួយនឹងការរីកចំរើននៃផ្នែកចិញ្ចឹមសត្វស្លាបក្នុងមួយឆ្នាំ ៗ ចំនួនមនុស្សគ្រប់សញ្ជាតិនៅលើពិភព លោកក៏បានកើនឡើងជាលំដាប់ដែរ ។

## សេចក្តីត្រូវការពងនិងសាច់សំរាប់មនុស្សម្នាក់ក្នុងមួយឆ្នាំរបស់ប្រទេសមួយចំនួន



| ឈ្មោះប្រទេស | ឆ្នាំ | ស៊ុតសម្រាប់ម្នាក់/ឆ្នាំ | សាច់សម្រាប់ម្នាក់/ឆ្នាំ |
|---|---|---|---|
| Holland | 1962 | 225 | 3,2Kg |
| Belgique | 1962-63 | 270 | 9,00Kg |
| Lexsombour | 1962-63 | 270 | 9,00Kg |
| Alemand | 1965 | 236 | 6,2Kg |
| Italie | 1962-63 | 168 | 25,2Kg |
| France | 1962-63 | 200 | 9,2Kg |
| Danamak | 1962-64 | 225 | 4,00Kg |
| Anglais | 1964 | 264 | 6,7Kg |
| U.S.A | 1964 | 314 | 17,5Kg |
| Canada | 1963 | 258 | 14,8Kg |
| Alemand | 1965 | 211 | 4,00Kg |

### ៤.ភាពប្រែប្រួលនៃបរិមាណស៊ុតនិងសាច់ខាងផ្នែកចិញ្ចឹមសត្វស្លាបនៅលើពិភពលោក

បរិមានសាច់ និងស៊ុតផ្នែកចិញ្ចឹមសត្វស្លាបនៅលើពីភពលោកមានការប្រែប្រួលជារៀងរាល់ ឆ្នាំ។ នៅខាងក្រោមនេះ គឺជាតួលេខនៃបរិមាណសាច់និងស៊ុតដែលមានការប្រែប្រួលពីមួយឆ្នាំ ទៅមួយឆ្នាំនៅលើពិភពលោកទាំងមូលះ

| ឆ្នាំ | បរិមាណស៊ុត | បរិមាណសាច់ |
|---|---|---|
| ១៩៤៩- ១៩៥២ | ២០៤០០លានគ្រាប់ | ៥, ៧ លានតោន |
| ១៩៦០ | ២០៤០០លានគ្រាប់ | ១២,៣លានតោន |
| ១៩៦៦ | ២៤១០០លានគ្រាប់ | ១២,៣លានតោន |
| ១៩៧០ | ៣៩៧៧០០លានគ្រាប់ | ១៧,៦លានតោន |
| ១៩៨៥ | ៣០៤០០០លានគ្រាប់ | ៣១០,៩១លានតោន |

នៅក្នុងនោះមានទាចំនួន១.៨% ក្ងានចំនួន០,៣% មាន់ចំនួន៩៥,៧% មាន់បារាំង

ចំនួន២,២%។ ការរីកចម្រើននៃទិន្នផលរបស់សត្វស្លាបគឺអាស្រ័យដោយការចិញ្ចឹមយកស៊ុតនិងចិញ្ចឹមយកសាច់។ តាមឯកសាររបស់អង្គការ FAO បានបង្ហាញអោយដឹងថាៈ

**ការចិញ្ចឹមយកស៊ុត**

- ❑ ឆ្នាំ១៩៦០ មេមាន់មួយក្បាលពងបាន១៦០ស៊ុត/ឆ្នាំ
- ❑ ឆ្នាំ១៩៦៥ មេមាន់មួយក្បាលពងបាន២២០ស៊ុត/ឆ្នាំ
- ❑ ឆ្នាំ១៩៨០ មេមាន់មួយក្បាលពងបាន២៤០ស៊ុត/ឆ្នាំ
- ❑ ឆ្នាំ១៩៨៥ មេមាន់មួយក្បាលពងបាន២៨០ស៊ុត/ឆ្នាំ

**ការចិញ្ចឹមយកសាច់ :**

- ❑ ឆ្នាំ ១៩៦០ ចិញ្ចឹមក្នុងរយៈពេល ១០អាទិត្យបានទំងន់១.៦ គក្រ
- ❑ ឆ្នាំ១៩៧០ ចិញ្ចឹមក្នុងរយៈពេល ៨អាទិត្យបានទំងន់១,៦ គក្រ
- ❑ ឆ្នាំ១៩៨០ ចិញ្ចឹមក្នុងរយៈពេល ៧អាទិត្យបានទំងន់១.៦ គក្រ
- ❑ ឆ្នាំ១៩៨៥ ចិញ្ចឹមក្នុងរយៈពេល៤២-៤៥ថ្ងៃបានទំងន់១,៦ គក្រ

បច្ចុប្បន្ននៅក្នុងបណ្តាប្រទេសជឿនលឿនមួយចំនួនគេអាចចិញ្ចឹមមាន់យកសាច់នៅក្នុងរយៈពេលតែ៤អាទិត្យប៉ុណ្ណោះ ។ ដោយសេចក្តីត្រូវការរបស់មនុស្សអំពីស៊ុតនិងសាច់ពីមួយ ថ្ងៃទៅមួយថ្ងៃកាន់តែកើនឡើង បានធ្វើអោយបណ្តាប្រទេសរីកចំរើនមួយចំនួនផ្នែកចិញ្ចឹមសត្វ ស្លាបកាន់ តែវិវត្តន៍ឡើង។ដើម្បីផ្តល់តាមសេចក្តីត្រូវការរបស់មនុស្សដូច្នេះការចិញ្ចឹមសត្វស្លាប របស់គេត្រូវមាន លក្ខណៈបច្ចេកទេសខ្ពស់ និង មានបទពិសោធន៍គ្រប់គ្រាន់ដូចជាបញ្ហាការពារ ជំងឺអោយបានល្អ រក្សា អនាម័យអោយបានត្រឹមត្រូវ បច្ចេកទេសចិញ្ចឹមអោយបានខ្ពស់និងថ្នាំព្យាបាលក៏ត្រូវមានគ្រប់គ្រាន់ ។

## សូមអរគុណ

# មេរៀនទី២ លក្ខណៈជីវសាស្ត្រនិងចំណុចសំខាន់ៗនៃសត្វស្លាប

## I. . ប្រភពដើមនៃសត្វស្លាប :

គ្រប់ប្រភេទសត្វទាំងអស់ដែលយើងយកមកចិញ្ចឹមតាមផ្ទះរឺតាមកន្លែងផ្សេង ៗ ប្រភពដើមកំណើតរបស់វាគឺយើងចាប់យកសត្វមកពីព្រៃហើយធ្វើការបង្ហាត់ និង ម្យ៉ាងវាអោយទៅជាសត្វស្រុកអាចរស់នៅជាមួយមនុស្សបាន ។

### ក/សត្វមាន់ : ប្រភេទសត្តសាស្ត្រ

- ❑ សាខា Chordata
- ❑ ផ្នែក Vetebrata
- ❑ ថ្នាក់ Aves
- ❑ ក្រុម Galliformes
- ❑ អំបូរ Fasianidea
- ❑ ពូជ Gallus
- ❑ ប្រភេទ Gallus gallusdomestica

ដោយរយៈកាលសមស្របគួបផ្សំ នឹងការចំរាញ់ជ្រើសរើសផងនោះទើបពូជមាន់នាពេលបច្ចុប្បន្ននេះ មានអំបូរប្លែក ១ ពីគ្នា ហើយប្រភេទពូជខ្លះផ្តល់នូវទិន្នផលយ៉ាងខ្ពស់សំរាប់សេចក្តីត្រូវការរបស់មនុស្ស ។

### ខ/សត្វទា : ប្រភេទសត្តសាស្ត្រ

- ❑ ក្រុម Anseriformes
- ❑ អំបូរ Anatidea
- ❑ ពូជ Anas
- ❑ ប្រភេទ Anas Phityrphynchos domestica

និយាយរួមប្រភេទទាស្រុកគឺបានមកពីប្រភពទាព្រៃហើយឆ្លងតាមការយកមកចិញ្ចឹមបំប៉នគេអាចបង្កើតបានជាពូជទាដែលផ្តល់សាច់យ៉ាងច្រើននា ពេលបច្ចុប្បន្ន ។

**គ.សត្វក្ងាន : ប្រភេទសត្វសាស្រ្ត** (មានប្រភពមកពីក្ងានព្រៃ)

- ក្រុម Anseriformes
- អំបូរ Anatidea
- ពូជ Anser
- ប្រភេទ Anser anserdomestica

**ឃ. មាន់បារាំង (Dindon ) :** មានប្រភពចេញមកពីមាន់ព្រៃដែលមានឈ្មោះ៖ Meleagris gallopavo.

- ក្រុម Galloformes
- អំបូរ Meleasidea
- ពូជ Meleagia
- ប្រភេទ Melegris

## II. . ចំណុចសំខាន់ៗរបស់សត្វស្លាប :

**១. ប្រដាប់បន្តពូជ :** ពងស្វាសខាងឆ្វេង ធំជាងពងស្វាសខាងស្តាំបន្តិច។

សត្វឈ្មោលៈកោសិកាបន្តពូជរបស់សត្វឈ្មោលគឺ Spermatosoide (ល្អែម៉ាតូសូអ៊ីដ ) ។ ស្ពែ ម៉ាតូសូអ៊ីដកើតចេញឡើងពីបំពង់ទាំងឡាយដែលស្ថិតនៅក្នុងពងស្វាស ។ ពងស្វាសរបស់សត្វ ស្លាប ស្ថិតនៅក្រោមឆ្អឹងខ្នងក្នុងប្រអប់ពោះដែលមានរាងជាពងក្រពើរីគ្រាប់សណ្តែក ។ ពងស្វា សខាងឆ្វេង ធំជាងខាងស្តាំបន្តិច និង នៅពេលមានសកម្មភាពពងស្វាសឡើងធំជាងធម្មតា ប៉ុន្តែនៅ ពេលជ្រុះរោម (ជំរុះរោម) ពងស្វាសរួមតូចមកវិញ ។ប្រព័ន្ធបំពង់បង្កើតរីបញ្ចេញស្ពែ ម៉ាតូសូអ៊ីដប្រទាក់គ្នាដោយ ជាលិកាសន្ទាន ។ ទំហំពងស្វាសនិងការបង្កើតល្អែម៉ាតូសូអ៊ីដវាមិនគ្រាន់តែ ទទួលឥទ្ធិពលខាង ក្នុងខ្លួន របស់វាទេថែមទាំងតែទទួលឥទ្ធិពលពីកត្តាខាងក្រៅថែមទៀត ដូចជាកត្តាគុណភាពចំណី ធាតុអាកាស និង ពន្លឺ ។ល។ ការខ្វះវីតាមីន B នៅក្នុងចំណីអាចបណ្តាលអន្តរាយដល់ពងស្វាសដែរ ។ ពេលមាន់ឈ្មោលកំពុងលូតលាស់ហើយយើងចាប់បញ្ចូលវាចូលទៅក្នុងទ្រុងដែលខ្វះពន្លឺ ពេលនោះពង ស្វាសមិន អាចដំណើរការពេញវ័យបានរឺក៏អាចបែកថែមទៀតផង ។ ក្នុងលក្ខណៈដែល

ខ្ទះពន្លឺកាន់តែខ្លាំងនោះ ដំណើរការពេញវ័យរបស់មាន់ឈ្មោលត្រូវបានបញ្ឈប់ ។ បំពង់នាំបញ្ចេញ Spermatojoid ធ្លាក់មក ក្លូអាក់ ( Cloaque ) ស្របនឹងបំពង់បញ្ចេញទឹកនោម ហើយចូលមកក្លូអាក់ត្រង់សងខាង នៃបំពង់បំពង់បញ្ចេញទឹកនោម ។បំពង់នាំស្ពែម៉ាតូសូអ៊ុត នេះ មុនមកដល់ក្លូអាករីកធំ ហើយបង្កើតជាថង់ទឹក កាមមួយដែលសំរាប់រក្សា ស្ពែម៉ាតូសូអ៊ុតក្នុងពេលសេពកាម។ ចំពោះសត្វទានិងក្ងានការបន្តពូជរបស់ សត្វឈ្មោលប្រព្រឹត្តឡើងដោយលឹង្គដែលមានរាងជារើសិរី ស្ថិតនៅយ៉ាងជ្រៅខាងក្រោយក្លូអាក់ ហើយ នៅពេលជាន់មេ លិង្គនេះពេញទៅដោយគោលិកាល ។**សត្វញី** : ការបន្តពូជរបស់សត្វស្លាបញីប្រព្រឹត្តឡើងដោយពង។ លូត លាស់តែខាងឆ្វេង។ អូវែបានភ្ជាប់ទៅខាងមុខនៃតំរងនោមខាងឆ្វេង ផ្នែកខាងក្រោមនិងត្រូវបាន បិទបាំងដោយកោះ។ អូវែមានទំហំប្រមាណពី ៨-២២ម.ម ប្រវែងពី១២-៣៤ម.មនិងកំរាស់ប្រ ហែលពី៣.៥-១០ម.ម។ នៅពេលធ្វើសកម្មភាព (ដំណើរការពង )

អូវែមានការរីកចំរើនយ៉ាងខ្លាំង គឺវារីកធំឡើងយ៉ាងច្បាស់ ។នៅក្នុងអូវែមានកោសិកាបន្តពូជដែលមិនផ្លាស់ប្តូរតាំងពីកូនមាន់ទើបញាស់ មកម្ល៉េះ ។

ក្នុងរយៈពេលលូតលាស់ដំបូងកោសិកាបន្តញី (អូវុល ) បានគ្របដណ្តប់ដោយកោសិកា១ជាន់ដែល មានទំនាក់ទំនងជាមួយកោសិកាអេពីតេស្យូម (Epitelium ) ។ស្រទាប់កោសិកា១ជាន់នេះនឹងទៅជា ច្រើនជាន់ ហើយការលូតលាស់របៀបនេះ ធ្វើឡើងជាបន្តបន្ទាប់រហូតជាប់នឹងផ្ទៃខាងលើនៃអូវែដែល ជា Follicule (ពងដែលកើតឡើងពេញរូបរាងនៅក្នុងស្រោមអូវែ )។ផ្ទៃខាងក្រៅនៃ Follicule មានសភាពថ្លា ហើយនៅពេលសត្វដំណើរការពង Follicule ជាច្រើនឡើងទុំ ហើយធ្វើអោយមានការ ផ្លាស់ប្តូររូបរាងរបស់អូវែដែលមើលពីខាងក្រៅដូចជាចង្កោមទំពាំងបាយជូ។ ក្រោយពេលដំណើរការ ពងអូវែនឹងត្រឡប់ទៅសភាពដើមវិញ។

កោសិកាពងបានទុំនិងជ្រុះធ្លាក់ចេញពី Follicule ចូលទៅក្នុងបំពង់នាំអូវុលតាមប្រម៉ោយ Fallope ។បំពង់នាំអូវុលនេះជាបំពង់មួយវែង ហើមានច្រើនកង់ និងផ្ទៃខាងក្នុងមានស្រទាប់សាច់ដុំពាសដោយ ភ្នាសរំអិលមួយស្រទាប់ ។

ក្នុងពេលកំពុងពងទំរង់និងរូបរាងនៃបំពង់នាំពង មានការផ្លាស់ប្តូរយ៉ាងខ្លាំងហើយវែងទៀតផង ។កំ លាំងរបស់វាកើនឡើងប្រវែង៥០ដង ។ឧទាហរណ៍ៈ ប្រវែងបំពង់នាំពងរបស់មាន់ Leghorn វែងថែមទៀតប្រមាណពី ៣០-៦០ស.ម (នៅ ពេលវាកំពុងពង និងបំពង់នាំពងរបស់មាន់ Plymouth វែងពី១៣-២៣ស.ម ជួនកាលអាចដល់ពី ៤៥-៥០ ស.ម ។

**បំពង់នាំស៊ុតនៃសត្វស្លាបចែកចេញជា៥ផ្នែកគឺ :**

**ក. ប្រម៉ោយ Fallope :**ជាកន្លែងសំរាប់ទទួលអូវុល និងជាកន្លែងណាត់ជួបគ្នា រវាងស្ពែម៉ាតូសូអ៊ុតនិងអូវុល ។

**ខ/កន្លែងផលិតពងស :** ( ក្រពេញអាល់បុយមីន)

កន្លែងនេះមានប្រវែងប្រមាណពី ២/៣ នៃបំពង់នាំស៊ុតទាំងមូល( ប្រវែង ៤០ស.ម ) ។ នៅពេល កំពុងពង ប្រវែងកន្លែងនេះកើនឡើង ២ដង ធៀបទៅនឹងពេលមិនពង ។ នៅទីនេះមានទៅដោយកោ សិកាក្រពេញ ដែលសំរាប់ផលិតនិងបញ្ចេញពងសគ្របដណ្តប់ព័ទ្ធជុំវិញពងក្រហម ហើយពងសនេះមាន សារធាតុអាល់ប៊ុយមីន

( Albumine)ប្រមាណពី ៥០-៦០%។ស៊ុតស្ថិតនៅទីនេះប្រមាណពី ២-៣ ម៉ោង ។

**គ. កន្លែងផលិតភ្នាសស្តើង :**

ផ្នែកដើមដំបូងនៃកន្លែងនេះមានសភាពស្តើង ហើយមានប្រវែងប្រមាណជា ៤ស.ម។ ជាកន្លែងមួយដែលចង្អៀត និងគ្មានក្រពេញទៀតផង ប៉ុន្តែវាអាចផលិតនូវភ្នាសស្តើងមួយដើម្បីគ្របដណ្តប់ជាប់ ទៅនឹងពងស។ ផ្នែកបន្ទាប់មកទៀតជាកន្លែងមួយដែលមានក្រពេញមួយ សំរាប់បញ្ចេញភាសមួយក្រោមសំបករឹង ហើយស៊ុតអាចនៅទីនេះមានរយៈពេលពី ២-៣ម៉ោង ។

**ឃ. កន្លែងផលិតសំបករឹង : ( ក្រពេញ Ca )**

ផ្ទៃនៃកន្លែងនេះមានទៅដោយក្រពេញជាច្រើនដែលផលិតបញ្ចេញនូវជាតិកំបោរ ។ ស៊ុតអាចនៅទីនេះមានរយៈពេលពី ១៦-២០ម៉ោង ។

## ង . ទ្វារមាស :

ជាសរីរាង្គដែលមានទៅដោយក្រពេញសំរាប់ផលិតបញ្ចេញនូវជាតិរំអិល។  ជាតិរំអិលនេះមានលទ្ធ ភាពសំខាន់ក្នុងជំនួយបញ្ចេញស៊ុត ។ នៅពេលសត្វកំពុងពងទ្វារមាសបានលូនចេញមកក្រៅក្លូអាក់ គឺដើ ម្បីរក្សាស៊ុតមិនអោយប្រឡាក់ ។




## ២. លទ្ធភាពផលិតស៊ុតរបស់សត្វស្លាប

ស៊ុតគឺជាកោសិការស់មួយ  ដែលនៅក្នុងនោះមានទៅដោយបណ្តាសារធាតុសរុប  ។នៅក្នុងរយៈពេលភ្ញាស់ គឺស៊ុតនេះហើយជាអ្នកបង្កើតនូវអំប្រីយ៉ុង ( Embryon › មួយ ហើយចុងបញ្ចប់ក៏លេចចេញជារូបរាងបក្សីថ្មីមួយទៀត ។

- ❑ ស៊ុតគឺជាប្រភពនៃសារធាតុប៉ូតាស្យូមដែលគាំទ្រសរសៃប្រសាទនិងសុខភាពសាច់ដុំ។  ប៉ូតាស្យូមជួយឱ្យកម្រិតជាតិសូដ្យូម   នៅក្នុងរាងកាយមានតុល្យភាពផងដែរហើយវាអាចធ្វើ

អោយសុខភាពសរសៃឈាមបេះដូងរបស់អ្នកប្រសើរ ឡើង។ ស៊ុតមានសារធាតុបំប៉នជាច្រើនដូចជាសារធាតុ lutein ដែលការពារអ្នក ប្រឆាំងនឹងជំងឺ និងកូលីនដែល ផ្តល់ភាពប្រសើរឡើងដល់សុខភាពខួរក្បាល។






ស៊ុតគឺជាកោសិកាបន្តពូជ និងសំបកស៊ុតមានទំងន់ពី ១២-១៥%នៃទំងន់ស៊ុត។ សំបកស៊ុតមានពីរស្រទាប់គឺ : រឹង និង ទន់។ នៅលើផ្ទៃសំបកស៊ុត មានរន្ធតូចៗសំរាប់បណ្តូរប្រព័ន្ធខ្យល់ ហើយសំបក ស៊ុតដែលសមស្រប គឺមានកំរាស់ ០ .៣ម.ម បើស្តើងពេកនាំអោយឆាប់បែក ។

ក្នុងតំណាក់កាលរីកចំរើនរបស់អំប្រីយ៉ុង ស៊ុតដែលមានសំបកស្តើង និងមិនស្មើអាចបណ្តាលអោយអំប្រីយ៉ុងស្លាប់ ។ពណ៌សំបុររបស់សំបកស៊ុត គឺអាស្រ័យទៅនឹងពូជ នៅពេលហ្វូងមាន់កើតជំងឺ ពេលនោះសំបកស៊ុតក៏មានការប្រែប្រួលដែរ ។

**ក.ពងក្រហម :** គឺជាកោសិកាមួយដែលមានតួនាទីជាធាតុបំប៉ន គ្របដណ្តប់ដោយភ្នាសពងក្រហម នឹងភ្ជាប់ទៅដោយពន្លកជីវិតមួយ ។ ពន្លកជីវិតនេះបង្កើតបានជាអំប្រីយ៉ុង ( Embryon ) ។ក្នុងរយៈ ពេលដែលអូវុលទុំ ហើយត្រូវធ្លាយចេញមក នៅពេលនោះដោយមានសរសៃប្លូរលើកន្លែងអូវុលមាន ការដាច់ ហើយត្រូវហូរឈាមធ្លាក់មកជាប់ពងក្រហម ពេលនោះពងក្រហមត្រូវជាប់ ទៅដោយដុំ ឈាម ។ សារធាតុបំប៉នរបស់ពងក្រហម រួមមានទឹក ៥០ % តំណក់ខ្លាញ់តូចធំ ២៣% ប្រូតេអ៊ីន ១៦ % លីពីត ១១ % និងជាតិរ៉ែអិលបន្តិចបន្តួច ។ ពងក្រហមរួមទៅដោយស្រទាប់ពណ៌ក្រហមស និងពណ៌លឿង ហើយនៅកណ្តាលពងក្រហម គឺជាកន្លែងផ្តុំទៅដោយពណ៌ក្រហមលាយស ។ពន្លកជីវិត គេអាចមើលឃើញដោយភ្នែកទទេ និងជានិច្ចកាលពងក្រហមភ្ជាប់ទៅដោយពន្លកជីវិត ។ពងក្រហម គ្របដណ្តប់ដោយសរសៃភ្នាសឆ្មារៗ ពណ៌សវែង ហើយបណ្តាសរសៃទាំងនេះត្រូវវិលរង្គញទៅតាមទិស សងខាងនៃពងក្រហមដែលហៅថាពូរយោងពងក្រហម ។ពងក្រហម គ្របដណ្តប់ដោយសរសៃភ្នាសឆ្មារៗ ពណ៌សវែង ហើយបណ្តាសរសៃទាំងនេះត្រូវវិលរង្គញទៅតាមទិស សងខាងនៃពងក្រហមដែលហៅថាពូរយោងពងក្រហម ។ ពូរយោងពងក្រហមមាននាទីធ្វើអោយពង ក្រហមមានលំនឹង នៅពេលដឹកជញ្ជូន ។

**ខ.ពងស** : មានជាតិអាល់ប៊ុយមីន ( Albumine) ពី ៥០-៦០% នៃទំងន់ស៊ុត ។ គឺជាអ្នកផ្តល់សារ ធាតុអោយអំប្រីយ៉ុង និងជាស្រទាប់មួយជួយការពារមិនអោយអំប្រីយ៉ុងមានការប៉ះ៖ ឬកកិត ។នៅ ខាងក្រៅនៃពងសគឺគ្របដណ្តប់ដោយភ្នាសស្តើងពីរដែលបង្កើតឡើងដោយជាតិស្នែង ( Keratine ដែលមានសភាពស្វិត ។ ភ្នាសទាំងពីរនេះបង្កើតបានជាឃ្លប់ខ្យល់មួយដែលជួយធ្វើអោយធាតុខាងក្នុង នៃស៊ុតមានលំនឹង កំនត់រូបរាងរបស់ស៊ុត និងមានតួនាទីជាអ្នកផ្តល់អុកស៊ីហ្សែន និង ឧស្ម័នកាបូនិកក្នុង ចលនាបណ្តូររូបធាតុរបស់អំប្រីយ៉ុង ។ កាលណាស៊ីតទុកយូរឃ្លប់ខ្យល់នេះរីកកាន់តែធំ ។

**គ. សំបករឹង** : ស៊ុតត្រូវបានគ្របដណ្តប់ដោយសំបករឹងដែលជាជាតិកំបោរ (Ca) ហើយនៅលើសំបកនៅពីលើសំបករឹងមានស្រទាប់ស្តើងមួយមានរន្ធតូចៗជាច្រើនសំរាប់អោយអំប្រីយ៉ុងដកដង្ហើម។ ស្រោបពីខាងក្រៅដែលធ្វើអោយស៊ុតមានសភាពរលីងងាយបញ្ចេញស៊ុតមកក្រៅ និងជារបាំងមួយការពារមិនអោយមេរោគជ្រាបចូលទៅក្នុងស៊ុតបាន។

## III. លទ្ធភាពនៃការផ្តល់ស៊ុត :

ក/ កត្តាពូជនិងលក្ខណៈពេញវ័យ : នៅពេលដែលសត្វស្លាបពងជាលើកដំបូង គឺជារយៈពេលដែលសត្វពេញវ័យ ។ ពូជខុសគ្នា ការពេញវ័យក៏ខុសគ្នាដែរ ហើយការផ្តល់ស៊ុតក៏ខុសគ្នាដែរ ។ ជាធម្មតា ពូជដែលរហ័សពេញវ័យ គឺវាមានលទ្ធភាពផ្តល់ស៊ុតបានច្រើន ។

**ខ.អាយុ** : យើងសង្កេតឃើញថាអាយុខុសគ្នា ការផ្តល់ស៊ុតក៏ខុសគ្នាដែរ។ (15-25)ឧទាហរណ៍ : មាន់ដែលមានអាយុពី ៣០-៤៣ អាទិត្យមានលទ្ធភាពផ្តល់ស៊ុតបានល្អ ហើយគេត្រូវលក់ បញ្ចេញវានៅពេលវាមានអាយុ ១៨-២០ខែ ។ (tenible -ចំពោះទាការផ្តល់ស៊ុតបានល្អ គឺនៅឆ្នាំទីពីរ ហើយគេត្រូវលក់បញ្ចេញវានៅឆ្នាំទី៣។

**គ. លក្ខណៈក្រាបនិងជំរុះរោម :** ចំពោះសត្វស្លាបការក្រាបនិងជំរុះរោមគឺជាលក្ខណៈធម្មជាតិ ហើយ នៅពេលសត្វក្រាបពងបានន័យថាគឺវាឈប់ពង ។ឧ. មាន់ស្រុកពេលពងហើយគឺវាក្រាប ពេលនោះការផ្តល់ស៊ុតរបស់វាគឺបានតិច ។ ចំពោះទាពេលពងរួច ហើយវាមិនក្រាបទេ ដូច្នេះការផ្តល់ស៊ុតរបស់វាបានច្រើន។ដោយលក្ខណៈខុសគ្នាដូច្នេះ ហើយផ្អែកទៅលើបច្ចេកទេសជឿនលឿន ទើបបច្ចុប្បន្ននេះគេបានបង្កើត និងបង្កើនពូជមាន់ដែលមិនចេះក្រាប ដើម្បីអោយវាផ្តល់ទិន្នផលស៊ុតបានច្រើន ក៏ប៉ុន្តែវាក៏នៅតែមាន លក្ខណៈជំរុះរោមដែរ ។ ទន្ទឹមនឹងនេះដែរ គេមានបច្ចេកទេសខ្លះដែរដែលធ្វើអោយមាន់កុំអោយរហ័សជ្រុះរោមនិងមិនអោយ ក្រាប ដោយផ្តល់ចំណីឱ្យវាស៊ីមិនឆ្អែត អោយវានៅជិតមាន់ពេឈ្មោល រឺក៏ប្រើអ័រម៉ូនដើម្បីបន្ថយរយៈ ពេលក្រាបរបស់វា។ ចំពោះសត្វទាដើម្បីបន្ថយរយៈពេលជំរុះរោមយើងអាចបង្អត់ចំណី រឺ ទឹកពី ១-២ ថ្ងៃ ដើម្បីអោយវាជ្រុះរោមឆាប់ និងដើម្បីអោយដុះរោមថ្មីមកលឿន ហើយរយៈពេលក្រោយមកយើងអោយវាស៊ីធម្មតា។

**ឃ. រយៈពេលផ្តល់ស៊ុតនិងសន្ទុះពងរបស់វា**

រយៈពេលមាន់ពងរហូតដល់ពេលជំរុះរោម គឺជារយៈពេលផ្តល់ស៊ុត ។ក្នុងកំឡុងពេលនេះបើមានរយៈ ពេលវែង នោះទិន្នផលស៊ុតក៏បានច្រើន ។ រីឯសំទុះផ្តល់ពងគេគិតជាមធ្យមភាគក្នុងរយៈពេលពងទៅ នឹងចំនួនស៊ុតជាមួយមេដែលពង។ បើសិនជាសំទុះពងបានផលតិច យើងត្រូវគិតគូរអំពីរបបចំណីដែល អោយវាស៊ី តើគ្រាប់គ្រានរឺទេ ។

**ង.កត្តាចំណី :**

បើសិនជាយើងជ្រើសរើសយកពូជមាន់ល្អមកចិញ្ចឹម នោះការផ្តល់ពងរបស់វាក៏អាស្រ័យទៅនឹងចំណី ដែរ ព្រោះចំនួនស៊ុតនិងគុណភាពរបស់វាគឺអាស្រ័យដោយចំណីជាអ្នកកំណត់ ។ដូច្នេះកត្តាចំណីមានសារៈ សំខាន់ណាស់ក្នុងផ្នែកចិញ្ចឹមសត្វស្លាបបែបឧស្សាហកម្ម ។

**ច.សីតុណ្ហភាព និងសំណើម :**

ចំពោះសីតុណ្ហភាពនិងសំណើម បើសិនជាខ្ពស់រឺទាបពេក លទ្ធភាពផ្តល់ស៊ុតក៏ត្រូវថយចុះដែរ ។ ឧទាះ នៅពេលថ្ងៃក្តៅខ្លាំង សីតុណ្ហភាពខ្ពស់ ហើយនៅពេលយប់ត្រជាក់ខ្លាំង ពេលនោះលទ្ធភាពផ្តល់ស៊ុតទទួលនូវការពិបាក ។ ដូច្នេះត្រូវមានវិធានការគឺ :

- សំណើមសមស្របគឺ ពី ៦០-៧៥% ។ បើសិនជាសីតុណ្ហភាពខ្ពស់ ហើយសំណើមក៏ខ្ពស់ដែរនោះនឹង ធ្វើអោយសត្វមានជំងឺ គឺធ្វើអោយសត្វមានការប្រែប្រួលបណ្តូររូបធាតុក្នុងរាងកាយ ហើយធ្វើអោយមានឥទ្ធិពលដល់ការផ្តល់ស៊ុត ។ ដូច្នេះយើងត្រូវ :
- ត្រូវសង់ទ្រុងនៅកន្លែងត្រជាក់ មានខ្យល់ចេញចូលបានល្អ
- ត្រូវដាំដើមឈើព័ទ្ធជុំវិញដើម្បីបន្ថយសីតុណ្ហភាព
- ត្រូវជីកស្រះព័ទ្ធជុំវិញកន្លែងចិញ្ចឹម
- ត្រូវធ្វើអនាម័យក្នុងទ្រុង និងជុំវិញទ្រូងអោយបានជាប្រចាំ
- ត្រូវធានានូវចំនួនក្បាលអោយបានសមស្របទៅនឹងផ្ទៃក្រឡារបស់ទ្រុងនីមួយៗ គឺត្រូវធ្វើយ៉ាងណាកុំអោយចង្អៀតពេក ។

**ឆ.ពន្លឺ:**

ពន្លឺមានសារៈសំខាន់ណាស់ក្នុងការអោយមាន់ស៊ីចំណី និងបំផុសអោយស៊ុតធ្លាក់ ( តំណាក់ កាលបង្ក ជាស៊ុត ) ។ រយៈពេលផ្តល់ពន្លឺនិងអាំងតង់ស៊ីតេ (Intencytee ) នៃពន្លឺក៏មានឥទ្ធិពលដល់ការផ្តល់ស៊ុតរបស់សត្វស្លាប ។ក្នុងការចិញ្ចឹមមាន់ គេច្រើនប្រើពន្លឺពណ៌សដើម្បីបំផុសអោយមាន់ពង។យើងមិនត្រូវ ផ្លាស់ប្តូររយៈពេលផ្តល់ពន្លឺឆាប់រហ័សពេកទេ ព្រោះវាអាចប៉ះពាល់ដល់ការផ្តល់ស៊ុត ។

**ជ. រដូវកាល និង អាកាសធាតុ :**

ការបន្តពូជរបស់សត្វស្លាបមានរដូវរបស់វា គឺមកពីចំណីអាហារ រឺអាកាសធាតុ ដូច្នេះឥទ្ធិពលផ្តល់ស៊ុត ក៏ដូច្នេះដែរ ។ ឧទានិទាយរដូវ (Spring) និងរដូវស្លឹកឈើជ្រុះ (Autumn)សត្វផ្តល់ពងបានច្រើន។

**ឈ.កត្តាជំងឺ :**

ជំងឺធ្វើអោយសត្វថយនូវចំនួនស៊ុត រឺក៏អាចដល់ស្លាប់ ដូច្នេះយើងត្រូវមានវិធីបង្ការការពារ និងព្យាបាលជំងឺ អោយបានល្អ ។

**ញ. ការថែរក្សា** : ត្រូវថែរក្សាអោយបានល្អ និងផ្តល់ទឹកចំណីដល់វាអោយបានគ្រប់គ្រាន់ ។

## IV.លទ្ធភាពផ្តល់សាច់របស់សត្វស្លាប :

**ក.ការផ្តល់សាច់នៃសត្វស្លាប** : សត្វស្លាបមានសំទុះលូតលាស់យ៉ាងឆាប់រហ័ស ដូចនេះលទ្ធភាពផ្តល់សាច់ក៏រីកចំរើនដែរ ។សាច់របស់សត្វស្លាបមានប្រូតេអ៊ីនប្រហែល ២១% ហើយប្រូតេអ៊ីនទាំង នោះសំបូរទៅដោយអាស៊ីតអាមីនេ (Acide Aminee ) ដែលមិនអាចជំនួសបាន ។

ការវាយតំលៃសាច់គឺយោងតាមសាច់ភ្លៅ.សាច់ទ្រូងហើយនិងរសជាតិដែលមានក្នុងសាច់អាស្រ័យ ហេតុនេះសត្វណាដែលមានមាឌធំខ្លួនវែង នោះសមាមាត្រសាច់កាប់របស់វាគឺបានល្អ នេះគឺដោយសារ សំទុះលូតលាស់នៃពូជនិមួយៗ ហើយម៉្យាងទៀតក៏អាស្រ័យទៅតាមអាយុនិងទំងន់របស់វាដែរ ។

ចំពោះមាន់ញីនិងមាន់ឈ្មោល បើទំងន់នៅរស់វាស្មើគ្នានោះ នៅពេលដែលកាប់ហើយគេឃើញ ទំម្ងន់សាច់កាប់មាន់ញីធ្ងន់ជាងមាន់ឈ្មោលហើយរសជាតិក៏ឆ្ងាញ់ជាងដែរ ។

**ខ.កត្តាដែលមានឥទ្ធិពលដល់ការផ្តល់សាច់ និងស៊ុត :**

- ❑ កត្តាពូជ ក្នុងករណីដែលពូជខុសគ្នា ការផ្តល់សាច់និងស៊ុតក៏ខុសគ្នាដែរ ។ ពូជមាន់ដែលគេចិញ្ចឹមយក សាច់មានទំងន់ធ្ងន់ ក្នុងនោះទំងន់សាច់កាប់ផ្តល់ពី ៦៩-៧៧% ។ ចំពោះពូជដែលមិនសូវធ្ងន់ ការផ្តល់ សាច់របស់វាគឺពី ៦៥-៧៥% ។
- ❑ កត្តាចំណី ចំពោះពូជល្អការត្រូវការចំណីរបស់វាក៏ត្រូវតែល្អដែរ។ បើសិនចំណីមិនល្អវិញ នោះយើង មិនអាចធានានូវរសជាតិសាច់និងទំងន់(ពិសេសគឺស៊ុត) របស់វាបានឡើយ ។

ក្នុងករណីដែលយើងអាចធានាទូចសារធាតុផ្សេងៗក្នុងចំណីបានគ្រប់គ្រាន់ ហើយការផ្តល់ចំណីអោយវានិងចិញ្ចឹមបានល្អ នោះ សត្វនឹងមានការលូតលាស់ល្អ។ ដូចនេះកត្តាពូជមាននាទីសំខាន់ ហើយចំណីវាកំណត់នូវការលូតលាស់ របស់សត្វ ។បច្ចេកទេសក្នុងការចិញ្ចឹមយើងត្រូវបែងចែកចំនួនក្បាលសត្វទៅនឹងផ្ទៃក្រឡាកន្លែងចិញ្ចឹមអោយ បានសមស្រប ។ជាមួយគ្នានេះដែរយើងត្រូវសំរួលសីតុណ្ហភាព, សំណើម និងរបៀបថៃទាំអោយបានសមស្របនិងអនុវត្តនូវការការពារ ព្យាបាលទាន់ពេលវេលា ជាពិសេសគឺរក្សាអនាម័យទ្រុងអោយបាន ត្រឹមត្រូវ ។



# មេរៀនទី៣ ការជ្រើសរើសពូជក្នុងការចិញ្ចឹម

## ១.អត្ថន័យនៃពូជសត្វស្លាបក្នុងសេដ្ឋកិច្ចៈ

នៅលើពិភពលោកទាំងមូលក្នុងចំណោមពូជរាប់រយរាប់ពាន់និងសៃស្រឡាយរបស់វា បានត្រូវបៀបថៃទាំអោយគេធ្វើការជ្រើសរើសសំរាំងពូជមួយចំនួនតូចដែលមានតំលៃក្នុងសេដ្ឋកិច្ច ។ ហើយមួយភាគតូចនៃពូជ ដែលបានជ្រើសរើសសំរាំងនេះត្រូវបានគេរក្សានិងពង្រីកចិញ្ចឹមគ្រប់ទីកន្លែងដើម្បីបំពេញសេចក្តីត្រូវ ការរបស់មនុស្ស ។ ពូជសត្វស្លាបមួយចំនួនដែលគេទទួលស្គាល់គឺវាស្ថិតនៅលើលក្ខណៈសម្បត្តិរបស់ពូជនាម័យទ្រុងអោយនីមួយៗ ហើយនៅក្នុងនោះគេបានបែងចែកជាបីប្រភេទសត្វស្លាបគឺ :

ក/ប្រភេទសត្វស្លាបដែលផ្តល់ទិន្នផលខាងស៊ុតមាន :

ឧ. ពូជមាន់លីហ្គន (Leghorn), អ៊ីសាប្រោន (Isabrown) ហ្គូលលិន (Goldline )
ៗល ៗ

ខ/ប្រភេទសត្វស្លាបដែលផ្តល់ទិន្នផលខាងសាច់មាន :

ឧ. ពូជមាន់ភ្លីមុត (Plymouth). ហ៊ីប្រូ (Hybro) ៗលៗ

គ/ប្រភេទសត្វស្លាបដែលផ្តល់ទិន្នផលខាងសាច់និងស៊ុតមាន :

ឧ.ពូជមាន់រូដ (Rhode). ញូហាមសៃ (New Hamshaire) ៗលៗ

## ២.ពូជមាន់មួយចំនួន :

ក/ពូជមាន់ក្នុងស្រុក : នៅក្នុងប្រទេសកម្ពុជាយើងប្រជាជនចូលចិត្តចិញ្ចឹមពូជមាន់ក្នុងស្រុក ដែលនលក្ខណៈងាយស្រួលក្នុងការចិញ្ចឹ ។ ពូជមាន់ក្នុងស្រុកមាន :

- ❑ មាន់ចៃ
- ❑ មាន់សំឡី
- ❑ មាន់សំពៅ
- ❑ មាន់ស្ទួយ
- ❑ មាន់ក្រញាស់

❑ មាន់ប្រជល់

ក្នុងការប្រើចំណីដើម្បីបានស៊ុតចំនួន ១ គីឡូក្រាម គេត្រូវចំណាយចំណីផ្សំស្រេចអស់ប្រហែល ៣ ឡូក្រាម។ បច្ចុប្បន្ននេះនៅកន្លែងចិញ្ចឹមមាន់ខ្លះ គេបានបង្កាត់ពូជមាន់លីហ្គនជាមួយ និងពូជមាន់រ៉ូត ដើម្បីបង្កើតចេញជាពូជកូនកាត់ថ្មីមួយទៀតដែលសំបកស៊ុតរបស់វាមានពណ៌លឿងស្លេក រឺប្រផេះដូច ណ៌សំបកពងមាន់ក្នុងស្រុក ។

អាស្រ័យដោយពូជមាន់លីហ្គនជាពូជមាន់ផ្តល់ស៊ុតដូច្នេះហើយត្រូវផ្តល់ចំណីអោយវាស៊ីអោយបានគ្រប់គ្រាន់ ដើម្បីអោយវាមានលទ្ធភាពផ្តល់ស៊ុតមកអោយយើង។

ពូជមាន់នេះបើយើងចិញ្ចឹមតាមលក្ខណៈឧស្សាហកម្មគឺសមស្រប តែបើយើងនាំយកពូជមាន់នេះទៅចិញ្ចឹមនៅឯជនបទតាមលក្ខណៈគ្រួសារនោះវាក៏ផ្តល់ទិន្នផលអោយយើងបានបង្គួរដែរ។

យើងត្រូវបង្ហាត់អោយវាស្គាល់នូវរបៀបចិញ្ចឹម បាលក្ខណៈគ្រួសារ ហើយត្រូវផ្តល់ចំណីអោយវាស៊ីពី ២-៣ដង/មួយថ្ងៃ ។ក្រៅពីនេះយើងត្រូវអោយវាដើររកស៊ីដោយខ្លួនឯង។ ការចិញ្ចឹមជាលក្ខណៈគ្រួសារយើងត្រូវមានដីទូលាយសំរាប់អោយវាដើររកស៊ី រីឯទិន្នផលស៊ុតគឺខ្ពស់បង្គួរ បើប្រៀបធៀបទៅនឹងការចិញ្ចឹមបែបឧស្សាហកម្ម ប៉ុន្តែអាត្រានៃការ កើតជំងឺគឺតិចជាងការចិញ្ចឹមបែបឧស្សាហកម្ម ហើយការកើតជំងឺ Leucose, Marek, CRD ក៏តិចខាងការចិញ្ចឹមបែបឧស្សាហកម្មដែរ ។

❑ ពូជមាន់ (Hubbard Comet) (ពូជនាំចូល)

ពូជមាន់ប្រភេទនេះមានរោមពណ៌លឿងអុជស រឺ ពណ៌សអុជលឿង។ គឺជាប្រភេទមាន់កូនកាត់ដែលបានមកពីការបង្កាត់រវាងមាន់ New Hamshireឈ្មោលពណ៌លឿងជាមួយនឹងពូជមាន់២២០-២៤០ស៊ុត/ក្បាល/ឆ្នាំ។ សំបកលុះដល់ពេលពេញវ័យមាន់Hubbard Sreeder ញីពណ៌ស ។ ជាមធ្យមវាអាចពងបានពី ប៊ុតរបស់វាមានពណ៌ត្នោតហើយក្រាស់ និងទំងន់ស៊ុតជាមធ្យមពី ៥៧-៦០ក្រាម/ស៊ុត។ ក្រោយពេល ញាស់កូនមាន់ឈ្មោលមានរោមពណ៌សចំណែកកូនញីមានពណ៌ឈាមជ្រូក រ៉ូមានពណ៌ស្លេតជាងពីក្មេង ចំណែកមាន់ឈ្មោលមានពណ៌ក្រហមប្រហាក់ប្រហែលនងមាន់ញី ។ ក្រោយពេលចិញ្ចឹមវាបានប្រហែល៤ខែ មាន់

ឈ្មោលមានទំងន់ពី ២.២ - ២.៥គីឡូក្រាម និងមាន់ញី បានទំងន់ជាមធ្យមពី ១.៩ - ២.២ គីឡូក្រាម ។

ការចំណាយចំណីសំរាប់ពូជមាន់នេះគឺច្រើនជាងពូជ ( Leghorn )។

❑ ពូជមាន់ ហ្គូលលីន (Goldline) (ពូជនាំចូល)

ពូជមាន់ប្រភេទនេះគឺជាពូជមាន់ដែលទើបតែនាំចូលមកថ្មីៗនេះ ហើយវាមានប្រភពចេញមកពី ប្រទេសហូឡង់។ សមាមាត្រនៃការចិញ្ចឹមគឺល្អ ចាប់តាំងពីអាយុ ១ថ្ងៃរហូតដល់ពេលវាផ្តល់ស៊ុតគឺបាន ពី ៩៣ - ៩៤% ។ ការចំណាយចំណីសំរាប់វាចាប់ពីអាយុ១ថ្ងៃរហូតដល់ ២០អាទិត្យអស់ប្រហែល ៧.៥ គីឡូក្រាម។ វាចាប់ផ្តើមពងនៅពេលវាមានអាយុបាន ២០អាទិត្យរហូតដល់ ៨០អាឱ្យ ។ ទិន្នផលពង ខ្ពស់បំផុតគឺនៅពេលចន្លោះអាយុចាប់ពី ២៤ - ៤០អាទិត្យ (៩០ - ៩៣%) ។ លទ្ធភាពផ្តល់ស៊ុតគឺពី ២៦០-២៨០ស៊ុត/ក្បាល/ឆ្នាំ និងទំងន់ជាមធ្យមពី ៥៨ - ៦០ ក្រាមស៊ុត(សំបកស៊ុតមានពណ៌ត្នោត) គេត្រូវចំណាយចំណីប្រហែល ១៥០ - ១៦០ក្រាមដើម្បីបានស៊ុតមួយរីដើម្បីបានស៊ុត ១គីឡូក្រាមគេ ត្រូវចំណាយចំណីអស់ប្រហែល ២.៤ - ២.៦ គីឡូក្រាម ។

❑ ពូជមាន់អ៊ីសាប្រោន (Isabrown) (ពូជនាំចូល)

ពូជមាន់នេះមានប្រភពចេញមកពីប្រទេសបារាំង ហើយក៏ជាពូជដែលផ្តល់ទិន្នផលស៊ុតខ្ពស់ដែរ ។ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលបាននាំចូលមកចិញ្ចឹមនៅក្នុងឆ្នាំ ១៩៩១ ហើយកម្មវិធីនេះគឺ រៀបចំដោយបារាំង ។ លក្ខណៈពិសេសរបស់ពូជមាន់នេះ គឺវាមានរោមពណ៌ត្នោត ឯសំបកស៊ុតរបស់វា ក៏មានពណ៌ត្នោតដែរ ។ សមាមាត្រនៃការចិញ្ចឹមគឺខ្ពស់ ពី ៩៣ - ៩៤% ។ ការចំណាយចំណីសំរាប់វា ចាប់ពីអាយុ១ថ្ងៃរហូតដល់ ២០អាទិត្យអស់ប្រហែល ៧.៤ - ៧.៥ គីឡូក្រាម/ក្បាល ។ទំងន់ជាមធ្យម នៅពេលវាចាប់ផ្តើមពងគឺពី ១.៦ - ១.៧ គីឡូក្រាម/ក្បាល។ ក្រោយពេលពងរហូតដល់ពេលជំរុះវា មានទំងន់ពី ២.១ - ២.៣ គីឡូក្រាម/ក្បាល ហើយវាចាប់ផ្តើមពងនៅពេលវាមានអាយុ ២២អាទិត្យនៅអាទិត្យទី ២៤ សមាមាត្រនៃការពងគឺបាន ៥០% ។ ចាប់ពីអាទិត្យទី ២៧-៣០សមាមាត្រនៃការ ពងរបស់វាគឺខ្ពស់បំផុតពី ៩០ -៩២% ។ ក្រោយមក

ទៀតការពងរបស់វាក៏ចាប់ផ្តើមថយចុះបន្តិចម្តង។ រហូតមកដល់អាទិត្យទី ៧៦ គឺបានប្រហែល ៦៥% ។

ការចំណាយចំណីក្នុងតំណាក់កាលដែលវាកំពុងពងគឺ ១១៥ - ១២០ ក្រាម/ថ្ងៃ/ក្បាល។ ដើម្បីបាន ស៊ុតមួយគេត្រូវចំណាយចំណីអស់ប្រហែល ១៤៩ ក្រាម។ ជាមធ្យមស៊ុតរបស់វាមានទំងន់ពី ៥៧ ៦៣ក្រាម/ស៊ុត ហើយក្នុងនោះមានប្រហែល ៤០% នៃពងដែលមានទំងន់លើ ៦៥ ក្រាម ។

- ❑ ពូជមាន់ផ្តល់សាច់ (ពូជមាន់នាំចូល )
- ➢ ពូជមាន់ភ្លីមុត (Plymouth)

ពូជមាន់នេះមានប្រភពចេញមកពីប្រទេសអាមេរិក។ វាមានរោមពណ៌សស្គុស់ រឺពណ៌សស្លួយ ដែល មានក្បាល តូចល្មម សិរទាបតែ មួយផ្លូវ ត្រដោក(រឺណង់) និងស្លឹកត្រចៀកមានពណ៌ក្រហម។ មុខវាមានរោមបន្តិច ភ្នែកធំដែលផ្លាស់ពីក្រម៉ៅទៅជាពណ៌ទឹកក្រូច ចំពុះខ្លី កវែងល្មម ដងខ្លួនធំវែងទូ លាយជ្រៅ ទ្រូងរីក រោមក្តោបទៅនឹងដងខ្លួន។ វាចាប់ផ្តើមពេញវ័យនៅពេលវាមានអាយុ ១៧០ថ្ងៃ ហើយក្រោយពេលចិញ្ចឹមបានជាង ៣ខែ : មាន់ញីមានទំងន់ពី ២.៨ - ៣.៣ គីឡូក្រាម/ក្បាល

: មាន់ឈ្មោលមានទំងន់ពី ៣.១ - ៣.៨ គីឡូក្រាម/ក្បាលរីឯទិន្នផលស៊ុតវិញគឺ ១៥០ - ១៦០ ស៊ុត/ក្បាល/ឆ្នាំ ។ ពូជស្រាលសំបកស៊ុតមានពណ៌ត្នោត ហើយភ្លី និងចំពោះពូជធ្ងន់គឺ ១៣០ ស៊ុត/ក្បាល/ឆ្នាំ កូនទើបញាស់មានសំបុរពណ៌ប្រផេះ និងពណ៌ស ។ បើគេចិញ្ចឹមតាមលក្ខណៈឧស្សាហកម្ម នោះគេត្រូវចំណាយចំណីផ្សំស្រេចអស់ប្រហែល ៣គីឡូក្រាម ទើបបាន ១ គីឡូក្រាមនៃទំងន់មាន់ ។

ពូជមាន់ភីមុតឆាប់ទទួលជំងឺណាស់ នៅពេលដែលអាកាសធាតុក្តៅខ្លាំងពេក រឺត្រជាក់ខ្លាំងពេក។ នៅរដូវភ្លៀង ប្រសិនបើយើងពុំបានថៃរក្សាវាអោយបានត្រឹមត្រូវ ហើយបណ្តាលអោយភ្លៀង ទទឹកវា នោះវានឹងងាយកើតជំងឺខ្វិន នឹងស្វិតដៃជើង ។

ប្រសិនបើយើងនាំពូជមាន់នេះទៅចិញ្ចឹមនៅតាមជនបទតាមរបៀបជាលក្ខណៈគ្រួសារ និងពាក់កណ្តាលជាលក្ខណៈឧស្សាហកម្មនោះក៏បានដែរ តែព្រឹកឡើងត្រូវរង់ចាំអោយថ្ងៃរះឡើង

សិន ទើប យើងព្រលែងវាចេញ ។ នៅក្នុងតំណាក់កាលដំបូង ត្រូវអោយវាស៊ីអាហារដែលមានរសជាតិ និងមានជីវ ជាតិគ្រប់គ្រាន់។ ក្រោយពេលចិញ្ចឹមបានអាយុជាង ១ខែ ក្រៅពីអាហារដែលយើងដាក់អោយវាស៊ី (មួយថ្ងៃបីដង) ត្រូវអោយវាដើររកស៊ីបន្ថែមទៀតដោយខ្លួនវា។ ការចិញ្ចឹមតាមរបៀបពាក់កណ្តាល គ្រួសារពាក់កណ្តាលឧស្សាហកម្ម មាន់ក្រធំ ប៉ុន្តែវាមិនសូវកើតជំងឺ សាច់របស់វាណែនល្អ ខ្លាញ់តិច និង មានរសជាតិជាងមាន់ចិញ្ចឹមរបៀបឧស្សាហកម្ម ។

- ពូជ Hubbard :

ពូជមាន់នេះមានប្រភពចេញមកពីរដ្ឋ NewHamshire (អាមេរិក) ។ វាមានរោមពណ៌សរលោង និងចំពុះពណ៌លឿង ទ្រូងទូលាយ ដងខ្លួនជ្រៅ កន្ទុយធំ ស្មាទូលាយ ។ ក្រោយពេលចិញ្ចឹមបាន ជាងបួនខែ ទំងន់ជាមធ្យមគឺ ពី ៣.៦ - ៤.២ គីឡូក្រាម/ក្បាល។ ការចំណាយចំណីគឺតិច ដើម្បីបានសាច់ ១គីឡូក្រាម គឺគេត្រូវចំណាយចំណីផ្សំស្រេចអស់ប្រហែល ២.២ គីឡូក្រាម។ ពូជមាន់នេះងាយ នឹងទទួលជំងឺណាស់ ដូច្នេះក្នុងការចិញ្ចឹមត្រូវរក្សាអនាម័យអោយបានត្រឹមត្រូវ ។

ពូជមាន់នេះមានរោមពណ៌ស ជើងនិងចំពុះមានពណ៌លឿង ដើមទ្រូងទូលាយ ដងខ្លួនវែងជ្រៅ ពូជមាន់នេះមានប្រភពចេញមកពីប្រទេសហូឡង់។ ក្រោយពេលចិញ្ចឹមបានជាងពីរខែ ទំងន់ជាមធ្យម គឺពី ១.៨ - ២.២គីឡូក្រាម/ក្បាល។ ការចំណាយចំណីសំរាប់វាតិចតួចល្មម គឺក្នុងតំណាក់កាលទី១ (ចាប់ពី ១ - ៥ អាទិត្យ) ត្រូវចំណាយចំណីផ្សំស្រេច ១.៧៥គីឡូក្រាម ដើម្បីបានសាច់ ១គីឡូក្រាម -នៅអាទិត្យ ទី ៦ ត្រូវចំណាយចំណីផ្សំស្រេចអស់ ១.៨៧ គីឡូក្រាម ទើបបានសាច់ ១គីឡូក្រាម

- នៅអាទិត្យ ទី ៦ ត្រូវចំណាយចំណីផ្សំស្រេចអស់ ១.៨៧ គីឡូក្រាម ទើបបានសាច់ ១ គីឡូក្រាម
- នៅអាទិត្យ ទី ៧ ត្រូវចំណាយចំណីផ្សំស្រេចអស់ ២ គីឡូក្រាម ទើបបានសាច់ ១ គីឡូក្រាម
- នៅអាទិត្យ ទី ៨-៩ ត្រូវចំណាយចំណីផ្សំស្រេចអស់ ២.១៣ គីឡូក្រាម ទើបបានសាច់ ១គីឡូក្រាម ។

ពូជមាន់នេះ គឺជាពូជមាន់ដែលផ្តល់ទិន្នផលខ្ពស់ ហើយត្រូវបានគេនិយមចូលចិត្តចិញ្ចឹមវានៅគ្រប់ទីកន្លែង ។

- ពូជមាន់ Cornish:

ពូជមាន់នេះមានប្រភពចេញមកពីប្រទេសអង់គ្លេស(គឺបានមកពីពូជមាន់ជល់នៅក្នុងឆ្នាំ ១៨៥០) ។ អ្នកជ្រើសរើសពូជមាន់អង់គ្លេសបានបង្កាត់ពូជមាន់ជល់អង់គ្លេសជាមួយនឹងពូជមាន់ម៉ាឡេស៊ី ហើយ បានដាក់ឈ្មោះពូជមាន់ Cornish ។

រហូតមកដល់ឆ្នាំ ១៨៨៧ ពូជមាន់នេះត្រូវបានគេយកមកសិក្សា នៅប្រទេសអាមេរិក ។ វាមានក្បាលធំខ្លី ហើយទូលាយ សិររួញអង្កាញ់ ដងខ្លួនរាងអែនទៅមុខ ស្មាទូ លាយ ត្រដោកនិងស្លឹកត្រចៀកមានពណ៌ក្រហម (ត្រដោករាងតូច) មុខគ្មានរោម កូនក្រមុំកែវភ្នែក ពណ៌ក្រហមស្រស់ រឺក្រហមទឹកក្រូច ចំពុះម៉ាខ្លី ករវែងល្មម រោមកខ្លីៗ ភ្លៅវែងហើយម៉ា ស្បែកពណ៌ លឿង រោមរបស់វាមានពណ៌ខ្មៅ និងលាយទៅដោយពន្លឺពណ៌ប្រាក់នៅលើរោមឆ្នារ១ ។

- មាន់ឈ្មោលមានទំងន់ពី ៤-៤.៦ គីឡូក្រាម/ក្បាល
- មាន់ញីមានទំងន់ពី ៣.២ - ៣.៥ គីឡូក្រាម/ក្បាល

ចំណែកការផ្តល់ស៊ុត គឺពី ១៣០ - ១៤០ ស៊ុត/ក្បាល/ឆ្នាំ។ សំបកស៊ុតរបស់វាមានពណ៌ក្រ ហមត្នោត ទំងន់ស៊ុតគឺ ៥០ - ៦០ក្រាម/ស៊ុត និងកូនដែលទើបនឹងញាស់មានពណ៌ស ។ ការចិញ្ចឹមក្នុងរយៈពេល ១០អាទិត្យផ្តល់សាច់ពី ១ - ១.៤គីឡូក្រាម/ក្បាល (ចំពោះមាន់ឈ្មោលអាចបាន ២ គីឡូ ក្រាម ) ។ ចំពោះមាន់ពូជ កូនកាត់រវាង Plymouth and Cornish វិញ ការចិញ្ចឹមគឺផ្តល់ទិន្នផល ឆាប់រហ័ស គឺក្នុងរយៈពេល ៦០ថ្ងៃ អាចផ្តល់សាច់បាន ១.៦ គីឡូក្រាម ហើយការចំណាយចំណីគឺ

២.៣៥គីឡូក្រាម ដើម្បីឡើងទំងន់ ១ គីឡូក្រាម។

- ពូជមាន់ចិញ្ចឹមយកសាច់ និង ស៊ុត : (ពូជនាំចូល )

-ពូជមាន់ Newhamshire:

ពូជមាន់ប្រភេទនេះមានប្រភពចេញមកពីប្រទេសអាមេរិក។ រោមរបស់វាមានពណ៌លឿង ស្លែតក្បាលធំ សិរតែមួយផ្លូវ រឹងខ្ពស់បន្តិច (ទាបជាងសិរ Leghorn) ត្រដោក (រីណង់ ទន់ជ្រាយ

ត្រចៀកនិងត្រដោកមានពណ៌ក្រហម ភ្នែកធំ រាងលៀនចេញក្រៅ ចំពុះម៉ាមានពណ៌ផ្កាឈូក ដងខ្លួន វែងជ្រៅទូលាយ បាតជើងពណ៌លឿង រោមក្តោបទៅនឹងដងខ្លួន កន្ទុយរួមជាមួយនឹងឆ្អឹងខ្នងមានរាង ជាខ្សែកោង ។ ក្រោយពេលចិញ្ចឹមបានជាង ៤ខែ ទំងន់ជាមធ្យមគឺ :

- ➢ មាន់ឈ្មោលមានទំងន់ពី ២.៩ - ៣.៧គីឡូក្រាម/ក្បាល
- ➢ មាន់ញីមានទំងន់ពី ២.៥- ២.៧គីឡូក្រាម/ក្បាល

ការផ្តល់ស៊ុតជាមធ្យមគឺ ១៥០ - ១៦០ស៊ុត/ឆ្នាំ។ ពូជមាន់ប្រភេទនេះត្រូវបានគេចូលចិត្តចិញ្ចឹម ព្រោះសាច់របស់វាមានរសជាតិ ស្រួលចិញ្ចឹម ហើយមិនសូវកើតជំងឺ ។

❑ ពូជមាន់ Rhode :

ពូជមាន់នេះមានប្រភពចេញមក ពីប្រទេសអាមេរិក។ រោមរបស់វាមានពណ៌ក្រហមជា និងជើងពណ៌លឿង។ ក្រោយពេលចិញ្ចឹមរយៈពេលជាង ៤ខែ មានទំងន់ជាមធ្យមគឺ ១.៣ - ១.៥គីឡូក្រាម/ក្បាល និងក្រោយពេលជាង ៦ខែ មានទំងន់ជាមធ្យម ពី៣.៣ - ៤.២គីឡូក្រាម ។ រីឯទិន្នផល ស៊ុត ជាមធ្យមគឺ ១៨០ - ២០០ស៊ុតក្នុងមួយឆ្នាំ រីឯទំងន់ស៊ុតជាមធ្យមគឺ ៥០ - ៦០ក្រាម/ស៊ុត ។ សំ បកស៊ុតមានពណ៌ត្នោតស្លែត ។

បច្ចុប្បន្ននេះ គេបានយកពូជមាន់ Rhode ទៅបង្កាត់ជាមួយពូជមាន់ Leghorn ដើម្បីកែប្រែយកស៊ុត។ ស៊ុតរបស់វាមានពណ៌ត្នោតស្លែត ដូចពណ៌សំបកពងមាន់ក្នុងស្រុក។ ការចំណាយចំណីសំរាប់ វាគឺតិច សាច់របស់វាឆ្ងាញ់ ហើយការលូតលាស់ឆាប់រហ័ស និងមិនសូវកើតជំងឺ ។

❑ ពូជមាន់ Sunex :

ពូជមាន់នេះមានប្រភពចេញមកពីប្រទេសអង់គ្លេស។ វាមានរោមពណ៌ស ករបស់វាមានឆ្នូត ពណ៌ខ្មៅ ស្លាបនិងកន្ទុយ មានលាយពណ៌ខ្មៅ។ ការផ្តល់ស៊ុតជាមធ្យមគឺ ១២០ - ១៥០ ស៊ុត/ឆ្នាំ ។ ពូជ មាន់នេះយើងអាចចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម និងជាលក្ខណៈពាក់កណ្តាលឧស្សាហកម្ម ។

❑ ពូជមាន់ Australerp:

ពូជមាន់នេះមានរោមពណ៌ខ្មៅ ជើងពណ៌ប្រផេះ រីឯការផ្តល់ស៊ុតគឺ ១៥០ - ១៦០ស៊ុត/ឆ្នាំ។ សំបកស៊ុតរបស់វាមានពណ៌ត្នោតស្លួត ទំងន់ជាមធ្យមគឺ ៥០ - ៥៥ក្រាម/ស៊ុត ។ ការចញ្ចឹមពូជមាន់ នេះតាមរបៀបឧស្សាហកម្ម និង ពាក់កណ្តាលឧស្សាហកម្មគឺបានដូចគ្នា ។

- ពូជមាន់ Moravia :

ពូជមាន់នេះមានប្រភពមកពីប្រទេសឆេកូ រោមរបស់វាមានពណ៌ដូចមាន់ Hubbard Comet ទិន្នផលស៊ុតរបស់វាខ្ពស់បង្គួរ ជាមធ្យមគឺ ២២០ - ២៤០ស៊ុត/ឆ្នាំ/ក្បាល ។ សំបកស៊ុតរបស់វាមានពណ៌ត្នោត ហើយលក្ខណៈពិសេសរបស់របស់វា គឺចាញ់នឹងអាកាសធាតុក្តៅ ហើយមានលក្ខណៈបន្សា នឹងធាតុត្រជាក់ ។ សីតុណ្ហភាពសមស្របសំរាប់វា គឺក្នុងរយៈពេល ៤អាទិត្យដំបូង គឺពី ៣០ អង្សា- ២០អង្សា ហើយចាប់ពីអាទិត្យទី ៥ឡើងទៅសីតុណ្ហភាពត្រូវរក្សាពី ១៥ -១៨ អង្សា។ ប្រសិនបើសីតុ ណ្ហភាពលើសពី ៣០ អង្សា នោះអាត្រាពងនឹងធ្លាក់ចុះ ។

## ៣. ការជ្រើសរើសពូជ :

ក/ការងារពូជដើម្បីចិញ្ចឹម: អាស្រ័យដោយបច្ចេកទេសចិញ្ចឹមជាលក្ខណៈឧស្សាកម្ម មានការរីកចំរើនខ្លាំង ដូច្នេះមុខជំនាញក្នុងការជ្រើសរើសពូជក៏ត្រូវអោយសមស្របទៅតាមលក្ខណៈ ផលិតនៃសេចក្តីត្រូវការរបស់ទីកន្លែងចិញ្ចឹមនិមួយៗ។ ដូច្នេះហើយទើបគេបែងចែកពូជសត្វស្លាបជាបីប្រភេទដូចខាងក្រោម :

### ក/១ ពូជមាន់ចិញ្ចឹមយកស៊ុត :

មានពូជមាន់ Leghorn. ពូជមាន់ Hubbard Comet. ពូជមាន់កូនកាត់រវាង Legom ជាមួយ Hubbard ព្រោះពូជមាន់ប្រភេទនេះមានទំងន់ស្រាល ការចំណាយចំណីសំរាប់វាគឺអស់តិច អាយុពេញវ័យឆាប់រហ័ស ឯទិន្នផលស៊ុតបានច្រើនហើយធំទៀត ។

### ក/២ ពូជមាន់ចិញ្ចឹមយកសាច់ :

មានពូជមាន់ Plymouth. ពូជមាន់ Cornish. ពូជមាន់ Hubbard ផ្តល់សាច់ និងពូជមាន់ កូនកាត់ Cornish ជាមួយនឹង Plymouth ។ ប្រភេទពូជមាន់ទាំងនេះ ការលូតលាស់របស់វាឆាប់រ ហ័ស ទំងន់ក៏ធ្ងន់ និងលទ្ធភាពផ្តល់សាច់ក៏បានច្រើនដែរ ។ ការចិញ្ចឹមពូជប្រភេទទាំងនេះគឺពូជសុទ្ធ

និង សែស្រទ្បាយរបស់វា ត្រូវមានកំរិតកំណត់ ព្រោះថាពូជសុទ្ធ និងសែស្រទ្បាយនេះវាមានកំទ្បាំងប្រឆាំង ទប់ទល់នឹងមេរោគខ្សោយ សមាមាត្រនិងអាត្រាស្លាប់អាចឡើងខ្ពស់ ។

ក/៣ ពូជមាន់ចិញ្ចឹមយកសាច់និងស៊ុត :

មានពូជមាន់ Rhode Island Red ពូជមាន់ NewHamshire ។ ល ។ ប្រភេទពូជមាន់ទាំងនេះ គឺមានលក្ខណៈសមស្របទៅនឹងការចិញ្ចឹមព្រលែង ។

ខ/ការជ្រើសរើសពូជ (គុណភាពពូជ )

ការជ្រើសរើសពូជគឺជាកត្តាសំខាន់ណាស់ព្រោះវាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការផលិតដែលជាបែបផែនឧស្សាហកម្ម ។ គេធ្វើការជ្រើសរើសពូជជាពីររបៀបគឺ :

ខ/១ ការជ្រើសរើសតាមការវាយតំលៃដេណូទីប (Phenotipe) (គំរូទិដ្ឋភាព )

ការជ្រើសរើសរបៀបនេះ គឺគេធ្វើឡើងដោយពឹងផ្អែកទៅលើការកំណត់សំគាល់នូវបណ្តាលក្ខណៈទាំងឡាយដែលអាចត្រួតពិនិត្យ និងវាស់ស្ទង់បាននូវពូជសត្វ ។ ករណីនេះត្រូវបានគេអនុវត្តនិងប្រើ ប្រាស់គ្រប់បណ្តាកន្លែងចិញ្ចឹម ។

ពូជសត្វមួយដែលល្អត្រូវមានលក្ខណៈទាំងខាងក្នុង និងខាងក្រៅបង្ហាញអំពីលក្ខណៈរបស់ពូជ សត្វនោះ។ ដូច្នេះគេត្រូវការរួមផ្សំទៅដោយបច្ចេកទេសជាច្រើនក្នុងការចិញ្ចឹមដូចជា : ការជំរើស. ការបង្កាត់. ការចិញ្ចឹមបំប៉ន. ការធ្វើអនាម័យកន្លែងភ្ញាស់ និងកន្លែងចិញ្ចឹម ... ។ល។

ពេលកូនមាន់ទើបយកចេញពីទូភ្ញាស់ យើងត្រូវជ្រើសរើសយកកូនណាដែលមានសុខភាពល្អ ហើយត្រូវជំរុះចោលចំពោះកូនណា ដែលមានសុខភាពខ្សោយចេញ។ ប្រសិនបើយើងពុំបានយកកូន ដែលខ្សោយចេញ ហើយយកវាមកចិញ្ចឹមរួមគ្នាជាមួយនឹងកូនមាន់ដែលមានសុខភាពល្អពេលនោះ យើងឃើញថា កូនមាន់ដែលមានសុខភាពខ្សោយងាយនឹងទទួលជំងឺជាងកូនមាន់ដែលមានសុខភាពល្អ ហើយវាងាយចំលងជំងឺនោះមកដល់កូនមាន់ដែលមានសុខភាពល្អ ។

កូនមាន់ដែលមានសុខភាពល្អ គឺពេលដែលយើងយកវាចេញពីទូភ្ញាស់ រោមរបស់វាស្ងួតដូចសំឡីត្រសុសគ្របជិតដងខ្លួន ចំពុះលើនិងក្រោមបិទជិត ស្លាបក្តោបទៅនឹងដងខ្លួន ជើងមូលស្មើល្អដំណើរឈរត្រង់ ភ្នែកភ្លឺ មានសកម្មភាពរហ័សរហួន(តាមធម្មតារោមរបស់វាស្ងួតរយៈពេល២ម៉ោងក្រោយពេលវាញាស់ )។

ម៉្យាងទៀតវាមានខ្នាតទំងន់ ទៅតាមពូជនិមួយៗរបស់វា គឺពី ៣៨ - ៤៥ក្រាម/ក្នុងមួយក្បាល ។

កូនមាន់ដែលមានសុខភាពខ្សោយ គឺទំងន់របស់វាស្រាលពេក មានជំងឺជាប់នឹងខ្លួន ជើងរៀចរើ កោង ផ្សិតលៀនចេញមកក្រៅ ស្បែកជិតជាប់ជាមួយរោម ចំពុះបិទមិនជិត រឺកាងខុបចុះមកក្រោម កវែងពេក និងខ្វាក់ភ្នែក។

- ការជ្រើសរើសក្រោយពេលអាយុ ៨ អាទិត្យ :

នៅក្នុងតំណាក់កាលនេះ មាន់ដែលគេចិញ្ចឹមយកសាច់មិនសូវចោទជាបញ្ហាទេ ព្រោះនៅក្នុងរយៈពេលនេះ គេអាចបញ្ចេញវាយកទៅធ្វើជាម្ហូបអាហារ ក៏ប៉ុន្តែចំពោះមាន់ដែលយើងទុកធ្វើជាពូជ រឺ សំរាប់ចិញ្ចឹមដើម្បីផលិតយកស៊ុតនោះ គឺជាតំណាក់កាលមួយដែលសំខាន់ ។

ការជ្រើសរើសនៅក្នុងតំណាក់កាលនេះសំខាន់គឺយើងសំរាំងពូជមាន់ដែលល្អ និងជំរុះចោលនូវ មាន់ណាដែលមិនពេញលក្ខណៈសំរាប់ធ្វើពូជ។ នៅក្នុងបញ្ហានេះ យើងត្រូវជ្រើសរើសទំងន់របស់មាន់ គឺមិនត្រូវស្រាលពេក រឺធ្ងន់ជាងខ្នាតទំងន់របស់ពូជ។ ត្រូវជ្រើសរើសយកមាន់ដែលមានរោមដុះអោយ បានសមស្រប ចំពុះលើ និងក្រោមត្រូវបិទជិត ហើយស្លាប រក្តោបយើងខ្លួន ។ល ។

បន្ទាប់មកទៀតនៅក្នុងតំណាក់កាលអាយុ ៤.៥ខែ គឺយើងត្រូវយកចិត្តទុកដាក់ដល់ការលូតលាស់នូវបណ្តាលក្ខណៈបន្តពូជ។ នៅក្នុងតំណាក់កាលនេះ មាន់មានប្រព័ន្ធសាច់ដុំ និងរោមលូតលាស់ គ្រប់គ្រាន់ ចំពោះមាន់ឈ្មោលមានរោមដុះវែង និងរោមនៅកដុះយ៉ាងល្អ ហើយគេអាចបង្កើតជាហ្វូង មាន់មេផ្តល់ពងបានល្អ ។

មាន់ដែលមានលក្ខណៈល្អ គឺបណ្តាសរីរាង្គដូចជា : សិរ ត្រដោក ស្លឹកត្រចៀកលូតលាស់ស្មើៗគ្នា ហើយមានពណ៌ក្រហមស្រស់ ភ្នែកធំភ្លឺ ជើងត្រង់ល្អ ដំណើរឈរត្រង់ម៉ា រោមដុះលូតលាស់ល្អ និងភ្លឺរលោង មានរូបរាងសមរម្យ និងសកម្មភាពរហ័សរហួន។

ចំណែកមាន់ញីសំរាប់ផ្តល់ស៊ុតវិញ យើងត្រូវយកចិត្តទុកដាក់ជ្រើសរើសអំពីការលូតលាស់ទៅលើផ្នែកពោះរបស់វា ដែលជាផ្នែកមួយយ៉ាងសំខាន់ដល់ការផលិតស៊ុត។ នៅក្នុងការអនុវត្តផ្ទាល់មាន់ ញីដែលមានលក្ខណៈល្អ គឺចន្លោះពីទ្រូងទៅនឹងគូទមានប្រវែងប្រមាណពី ៣ - ៤ ម្រាមដៃ។

## ខ/២ ការជ្រើសរើសក្នុងគ្រាពង :

ក្នុងបណ្តាកន្លែងចិញ្ចឹមមាន់ផ្សេងៗ យើងពិនិត្យឃើញថាមានមេមាន់ខ្លះបាត់ ខ្លាញ់ច្រើន គឺ បណ្តាលមកពីវាទទួលជំងឺ រឺក៏អាស្រ័យដោយការចិញ្ចឹមបំប៉នមិនត្រឹមត្រូវ និង ទំរង់សរីរាង្គមិនល្អ ធ្វើអោយមេមាន់ពងមិនសូវល្អ រឺក៏របស់ឈប់ពង។ នៅក្នុងកណីដែលយើងចិញ្ចឹមបំប៉នធម្មតា ចំនួនមេ មាន់ដែលមិនពង ក៏គង់មានប្រមាណពី ១០ ១៥% ដូច្នេះយើងគម្បីជំរុះចោលជាបន្ទាន់នូវមេមាន់ ណាដែលបាត់បង់លទ្ធភាពផ្តល់ស៊ុត។ ក្នុងករណីដែលអាត្រាពងមានដល់ ៧០%ឡើងទៅ យើងអាច ចាត់ទុកថាជាហ្វូងមាន់ពងបានល្អ ។ បើសិនជាលទ្ធភាពផ្តល់ស៊ុតបានតិចពេក ហើយពិបាកធ្វើការ សន្និដ្ឋាន អំពីទិសដៅនៅពេលអនាគតរបស់សត្វនោះ យើងត្រូវយកមាន់ម្តងមួយក្បាល១មកធ្វើការ ត្រួតពិនិត្យ និងជំរុះចោលនូវមាន់ណាដែលមានលក្ខណៈមិនល្អចេញ។

យើងត្រូវត្រួតពិនិត្យហ្វូងមាន់ រាយបានពី ៣ - ៤ ដងក្នុងមួយឆ្នាំ។ បើសិនជាយើងមិនមានការជំរុះវាចោលក្នុងគ្រាវាពងនោះទេ ទោះជាយើងចិញ្ចឹម និងថែរក្សាត្រូវតាមក្បួនខ្នាតបច្ចេកទេសក៏ដោយនោះ យើងក៏មានការពិបាកដើម្បី បង្កើនអាត្រាពងរបស់ហ្វូងមាន់អោយបានខ្ពស់ដែរ ។

ខាងក្រោមនេះគឺជាលក្ខណៈខាងក្រៅមួយចំនួនដើម្បីយល់ដឹងអំពីមេមាន់មិនពង :

- ការពិនិត្យលក្ខណៈសិររបស់មេមាន់ : មេមាន់ដែលមិនពង សិររបស់វារួញស្វិតតូច ។
- ការពិនិត្យទៅលើពណ៌សំបុរៈ ចំពុះស្បែកជាធម្មតា នៅពេលកំពុងពង សារធាតុការ៉ូតែន (Karotene ) នៅក្នុងចំណីអាហារ គឺជាធាតុមួយជំនួយដល់ស៊ុតក្រហម។ ដូច្នេះ សារធាតុនេះមិនសូវ បានផ្ទុកនៅក្នុងស្បែកច្រើនទេ ជាហេតុនាំអោយស្បែកមិនសូវលឿង។

យើងត្រូវបំពេញបន្ថែមសារធាតុនេះអោយបានគ្រប់គ្រាន់នៅពេលមាន់កំពុងពង ។

- ការពិនិត្យរោម : ការចញ្ចឹមមាន់មេនៅលើកំរាលដែលមានមាន់ឈ្មោលនៅជិត តែមាន់មេមិនផ្តល់ស៊ុតទេនោះ គឺវាមានរោមរលោងស្អាត រឺរោមច្រើន នោះក៏មិនទាន់ដល់ពេលរកឈ្មោលដែរ ។ ផ្ទុយទៅវិញមេមាន់ណាដែលពងច្រើនហើយយល់ព្រមដោយឈ្មោល នោះធ្វើអោយរោមនៅលើក្បាល និងខ្នងមានការជ្រុះរោមជាច្រើន ។ ចំពោះមេមាន់ណាដែលឆាប់ផ្លាស់ រឺជ្រុះរោមច្រើន ក៏ត្រូវចាត់ទុកថា ជាមេមាន់មិនពងដែរ ។

ការពិនិត្យទៅលើពោះ និងក្ងអាក់នៅក្នុងបណ្តាកន្លែងចិញ្ចឹមមា គេអាចធ្វើការ ឯងដោយផ្អែកទៅលើការពិនិត្យពោះ និងក្លូអាក់ (Cloaque) ។ក្នុងលក្ខណៈ កត់សំគាល់មាន់ពង រឺមិនពងដោយផ្អែកទេ ដែលពិនិត្យទៅឃើញមេមាន់ណាដែលមានក្ងអាក់ស្ងួត រន្ធគូថរបស់វាតូច មានពណ៌រាងជាគឺបង្ហាញថា មេមាន់នោះមិនពង រឺក៏ពងដែរ ប៉ុន្តែពងតិច ពងតិច ។ ផ្ទុយទៅវិញមេមាន់ណាដែលមានតួអាក់សើម មានរន្ធគូថធំ និងមានចលនាជីបអូចៗ ពណ៌រាងស្លេក នោះគឺបង្ក នោះពងបានល្អ ។

ម៉្យាងទៀតយើងអាចពីឱ្យទៅលើពោះរបស់វា ដោយសង្កត់ទៅលើស្បែកពោះ បើស្បែករ ទន់ហើយយឺត និងចន្លោះពីឆ្អឹងទ្រូងទៅគូថពី ៣ - ៤ម្រាមដៃនោះ គឺបញ្ជាក់ថាមេមាន់ពងបានល្អ ។

- បច្ចេកទេសនៃការចាប់មាន់កំពុងពង

នៅពេលចាប់មាន់មកធ្វើការត្រួតពិនិត្យ យើងត្រូវជៀសវាងកុំអោយមានការប៉ះទង្គិចខ្លាំងពីខាងក្រៅ។ បើសិនជាយើងដេញចាប់មាន់ក្នុងហ្វូងដោយប្រើដៃទទេ នោះវាអាចបណ្តាលអោយមាន ឥទ្ធិពលដល់ការថយចុះនៃពង ។ ដើម្បីចាប់វាអោយបានងាយស្រួល យើងគប្បីធ្វើជាសំភារៈសំរាប់ចាប់ ដូចជា សំណាញ់(លួត ) ទំពក់សំរាប់ថ្ពក់ជើងមាន់ដែលមានដងវែងសំរាប់កាន់ រឺក៏ប្រើពន្លឺស្រអាប់ដូច ជាពន្លឺពណ៌ខៀវ រឺពណ៌ស្វាយ ដើម្បីកុំអោយមាន់មើលឃើញច្បាស់ ជាការងាយស្រួលក្នុងការចាប់វា។ នៅពេលដែលយើងភ្លៀងចាប់អាន់ គួរធ្វើឡើងកុំអោយចង្អៀតពេក ព្រោះមាន់អាចឡើងជាន់លើគ្នា បណ្តាលអោយមានបាតុភូត Stress រឺការបែកពងនៅក្នុងពោះ ។

ការចាប់កាន់មាន់មានពីររបៀបគឺ :

- ការចាប់កាន់នៅស្លាប គឺត្រូវដាក់ម្រាមចង្អុលមួយចូលក្នុងចន្លោះស្លាបទាំងពីរ រួចចាប់កាន់ ទៅគល់ស្លាបលើកឡើង ទើបធ្វើការត្រួតពិនិត្យពីក្បាលរហូតដល់ចុងជើងរបស់វា។
- ការចាប់កាន់នៅជើង : គឺត្រូវសិកម្រាមដៃខាងក្រោមឆ្អឹងទ្រូង រួចទ្រលើកឡើង ទើបយើង ធ្វើការត្រួតពិនិត្យវា។

❑ គ/ការបង្កាត់ និងបង្កើនពូជ :

ដើម្បីបង្កើនបរិមាណ និងគុណភាពសត្វស្លាប គេតែងតែអនុវត្តការប ការបង្កាត់ពូជដើម្បីប ដើម្បីបង្កើនហ្វូង មាន់ជារឿយៗ ។ សព្វថ្ងៃនេះតាមទិសដេ តាមទិសដៅរបស់អ្នកចិញ្ចឹមភាគខ្លះគេបង្កាត់ពូជត គបង្កាត់ពូជសុទ្ធ ជាមួយពូជសុទ្ធ ខ្លះទៀតគេបង្កាត់យកពូជកូនកាត់ ។ ដូច្នេះបើគេចង់បង្កើតចំនួនហ្វូងនៃពូជណាមួយនោះ គឺគេត្រូវអនុ អាយល្អនោះ គឺគេត្រូវអនុ វត្តការបង្កាត់រវាងពូជសុទ្ធ និងពូជសុទ្ធ ហើយបើចង់កែប្រែនូវពូជណាមួយអោយល្អ វត្តតាមគោលការណ៍បង្កាត់ស៊ីប្រ៊ីត។

ឧទា : មាន់ឈ្មោល ( Leghorn ) X មាន់ញី ( Leghorn )

↓

ឈ្មោល .ញី ( Leghorn )

ក្នុងការបង្កាត់រវាងពូជសុទ្ធនិងពូជសុទ្ធ ដើម្បីបង្កើនពូជអោយបានកាន់តែច្រើននោះ ត្រូវផ្អែក ទៅលើលក្ខណៈសំគាល់បីយ៉ាងខាងក្រោមគឺ :

- ❑ ត្រូវជ្រើសរើសអោយបានត្រឹមត្រូវនូវលក្ខណៈពូជតាមការបង្កាត់ដែលបានបញ្ជាក់នៅខាង លើ។ ហើយបើអនុវត្តតាមរបៀបខាងលើនេះ គឺកាន់តែបង្កើនគុណភាពលក្ខណៈរបស់ពូជ។ គេមិនអនុ ញ្ញាតអោយរើសពូជតាមចំណង់ចិត្តឡើយ ហើយគប្បីជ្រើសរើសញី និងឈ្មោលអោយបានល្អ ។

ជាមួយនឹងការជ្រើសរើសពូជ យើងត្រូវចិញ្ចឹមអោយបានសមស្របទៅតាមលក្ខណៈបច្ចេក ទេសរបស់ពូជនិមួយៗ។ ប្រសិនបើពូជល្អ តែការចិញ្ចឹមពុំបានល្អត្រឹមត្រូវទេនោះ លក្ខណៈរក្សាពូជ នឹងមានការថយចុះ ។

ឧទាហរណ៍ៈ ពូជមាន់ លីហ្គន ពងបាន ៣០០/ឆ្នាំ ដូច្នេះបើយើងចង់បានពូជដែលពងបាន ៣០០/ឆ្នាំ ដែរ យើងត្រូវផ្តល់ចំណីដែលមានប្រូតេអ៊ីនពី ១៦ - ១៧%។ តែបើការផ្តល់ចំណីដែលមានប្រូ

តែអ៊ីនត្រឹមតែ ១២ - ១៣% នោះចំនួនអាត្រានៃពងនឹងត្រូវថយចុះមកត្រឹមតែ ១៥០ - ១៦០ស៊ុត/ឆ្នាំដូច្នេះគុណភាពពូជត្រូវថយចុះ ។

នៅពេលបង្កាត់ពូជសុទ្ធ និងពូជសុទ្ធ យើងត្រូវជៀសវាងនូវការបង្កាត់ដែលមានលក្ខណៈជាន់ឈាមគ្នា ព្រោះវាអាចបណ្តាលអោយគុណភាពពូជថយចុះ ការរស់នៅរបស់វាក៏នៅមានកំលាំងខ្សោយ ហើយគុណសម្បត្តិរបស់ពូជបានលេចឡើងនូវលក្ខណៈថយចុះ ។

**គ/២ ការបង្កាត់អ៊ីប្រ៊ីត (Hybride)**

បច្ចុប្បន្ននេះគេអនុវត្តរូបមន្តនៃការបង្កាត់អ៊ីប្រ៊ីតមានបីយ៉ាងគឺ :

- ការបង្កាត់សេដ្ឋកិច្ច : ការបង្កាត់នេះ គឺគេយកពូជខុសគ្នាមកបង្កាត់ ហើយគេយកកូនជំនាន់ ទី១ (F1) ទុកចិញ្ចឹម។ លក្ខណៈនេះ គឺគេកែច្នៃយកទិដ្ឋភាពក្លាយនៃពូជដើមដើម្បីអោយចំណេញ ខាងសេដ្ឋកិច្ច តែខាងពូជគឺមិនបានចំណេញទេ។ ការបង្កាត់សេដ្ឋកិច្ច គឺគេចង់បានទិន្នផលរបស់មាន់ ក្នុងស្រុកអោយបានកើនឡើង ហើយទាញយកផលរបស់មាន់បរទេសពាក់កណ្តាល។ ករណីនេះគឺគេ យកមាន់ឈ្មោល ( ពូជបរទេស ) មកបង្កាត់ជាមួយមាន់ញី (ពូជក្នុងស្រុក ) ។



ការបង្កាត់កែប្រែពូជ : នៅពេលដែលយើងចង់បានពូជបរទេស ដែលមានទិន្នផលខ្ពស់មកបង្កាត់ជាមួយពូជមាន់ក្នុងស្រុក ដើម្បីបំបាត់នូវគុណវិបត្តមួយចំនួននោះ គឺគេអនុវត្តតាមរូបមន្តបង្កាត់ កែប្រែ ។ ការបង្កាត់កែប្រែពូជនេះ គេអនុវត្តជាបណ្តើរៗ លុះនៅពេលណាការបង្កាត់នេះទទួលបានតាម គោលបំណងរបស់គេ ទើបគេឈប់បង្កាត់ ។

ឧទា : មាន់ឈ្មោល ( Plymouth ) X ញី ( មាន់គក )

↓

F1 : សាច់ច្រើន

ឈ្មោល Plymouth X F1 → F2

ឈ្មោល Plymouth X F2 → F3

F3 X F3 : បង្កាត់ដើម្បីបង្កើនទំងន់មាន់ក្នុងស្រុក

# សូមអរគុណ

# មេរៀនទី ៤ ការភ្ញាស់ស៊ុត

បច្ចុប្បន្ននេះការភ្ញាស់ស៊ុតដោយសិប្បនិម្មិតត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយ អាស្រ័យដោយ សេចក្ដីត្រូវការរបស់មនុស្សគ្រប់សញ្ជាតិ។ ដូច្នេះហើយទើបគេឃើញមានហ្វូងមាន់ជាច្រើនក្នុង១ឆ្នាំ១ ត្រូវបានផលិតចេញពីម៉ាស៊ីនភ្ញាស់។ ម៉ាស៊ីនភ្ញាស់ដោយស្វ័យប្រវត្តិ គឺជាឧបករណ៍មួយមានសារៈសំ ខាន់ណាស់ ព្រោះវាអាចផលិតបានចំនួនច្រើនក្បាល ហើយមានអាយុស្មើៗគ្នាទៀតផង។ ការភ្ញាស់ ដោយសិប្បនិម្មិតត្រូវទាមទារនូវបច្ចេកទេសខ្ពស់ និងដើម្បីទទួលទិន្នផលល្អត្រូវពឹងផ្អែកទៅលើគុណ ភាពស៊ុត និងលក្ខណៈរបស់ម៉ាស៊ីនភ្ញាស់ ។

## ១. ការជ្រើសរើសស៊ុតសំរាប់ភ្ញាស់ :

លក្ខខ័ណ្ឌដំបូងដើម្បីភ្ញាស់ស៊ុតអោយបានល្អ គឺយើងត្រូវជ្រើសរើសយកស៊ុតណាដែលមានលក្ខ ណៈជីវសាស្ត្រខ្ពស់។បន្ទាប់មកទៀត យើងត្រូវជ្រើសរើសដោយផ្អែកទៅលើទំងន់របស់ស៊ុត , រូបរាង ខាងក្រៅ និងលក្ខណៈខាងក្នុងរបស់ស៊ុត ។

១/ ទំងន់របស់ស៊ុត : ទំងន់ស៊ុតដែលទទួលលទ្ធផលល្អសំរាប់ជ្រើសរើសយកទៅភ្ញាស់ នោះគឺត្រូវមានទំងន់ពី៥២ - ៦០ក្រាម រឺ ពី ៥៥ - ៦៥ក្រាម អាស្រ័យទៅតាមពូជរបស់វា។ ទំងន់កូនមាន់ដែលទើបនឹងញាស់គឺស្មើនឹង ៧០% នៃទំងន់ស៊ុតដែលដាក់ភ្ញាស់ ។

២/ រូបរាងខាងក្រៅរបស់ស៊ុត : ស៊ុតទាំងឡាយត្រូវបានប្រដាប់បន្តពូជរបស់បក្សីញីជាអ្នកកំណត់រូបរាងអោយ ។ ដូច្នេះមេមាន់និមួយៗសុទ្ធតែបានកំណត់រូបរាងស៊ុតរបស់វារៀងៗខ្លួន។ ប៉ុន្តែរូប រាងស៊ុតដែលមានលក្ខណៈសមស្របដើម្បីយកទៅភ្ញាស់ ត្រូវបានកំនត់ដោយសមាមាត្ររវាងបណ្ដោយ និងទទឹងគឺ :

ការកំណត់រូបរាងរបស់ស៊ុត = ប្រវែងទទឹង = 9740 85 = 0,74-0,85

ប្រវែង បណ្ដោយ 1

- ពណ៌សម្បុរៈ សំបករបស់សត្វមានពណ៌ផ្សេងៗគ្នា ប៉ុន្តែពណ៌សម្បុររបស់ស៊ុតពុំមានទាក់ ទងទៅនឹងកំនកំនើតរបស់អំប្រីយ៉ុងទេ។ ប៉ុន្តែស៊ុតមានសំបកពណ៌សងាយស្រួលក្នុងការឆ្លុះជាងស៊ុតដែល មានពណ៌ផ្សេងៗ ។

- រូបរាងនៃសំបក ៖ សំបកស៊ុតមានជាតិម្សៅម៉្យាងដូចកំបោរ ហ៊ុំព័ទ្ធពីផ្ទៃខាងក្រៅនៃសំបក ស៊ុត។ យើងត្រូវជ្រើសរើសយកស៊ុតដែលមានសំបកក្រាសល្មម ហើយមានសភាពរលីងស្អាតមិនរៀច. មិនស្លួចចុងដើម ។ មិនត្រូវជ្រើសរើសយកស៊ុតដែលមានលក្ខណៈប្រេះស្រាំ និងកខ្វក់ ។

៣/ លក្ខណៈខាងក្នុងរបស់ស៊ុត: ដើម្បីអោយដឹងថា ស៊ុតមានកំណកំណើត រឺក៏គ្មាន គេអាច វាស់ស្ទង់ដោយប្រដាប់វាស់ប៉ូតង់ស្យែល (Potenciel)។ បើប៉ូតង់ស្យែលនៃស៊ុតណាខ្ពស់ នោះគឺជាវត្តមានរបស់អំប្រីយ៉ុង ក៏ប៉ុន្តែការវាស់ស្ទង់ដោយឧបករណ៍នេះវាមិនច្បាស់លាស់ ដូចជាការឆ្លុះទេ ។ រយៈពេលដែលត្រូវឆ្លុះឆាប់បំផុត គឺ ២៤ - ៣៦ ក្រោយពេលដាក់ភ្ញាស់ ។ បើស៊ុតណាមានកំណកំ ណើត ពេលឆ្លុះនោះគេ នឹងឃើញមានបណ្តាញសរសៃឈាមចាប់ដំណើរការ ។

ចំពោះស៊ុតដែលយកទៅភ្ញាស់ត្រូវពិនិត្យមើល មើលឈ្វប់ខ្យល់របស់វាជាមុនសិន បើឃ្លប់ខ្យល់ធំពេក បើពិនិត្យទៅឃើញមានសភាពសថ្លា ពីបង្ហាញថាគ្មាន
កំណកំណើត មិនត្រូវយកទៅភ្ញាស់ទេ ។ ម៉្យាងទៀតបើពិនិត្យទៅ ទេ និងចំពោះស៊ុតដែលដិតជាតដែលដិតជាមទៅដោយដុំឈាម ក៏មិនត្រូវយកទៅភ្ញាស់ដែរ ។

នៅក្នុងនោះ រនោះដែរស៊ុតដែលមានអាត្រាញាស់ខ្ពស់ ក៏អាស្រ័យដោយសមាមាត្រនៃការដាក់បង្កាត់ និងញី អាយុ ការថែរក្សា ព្រមទាំងការផ្តល់ចំណី និងទឹក ។ល ។

## ២. គុណភាពពូជការផ្តល់ចំណី និងការថែរក្សា :

ដើម្បីទទួលទិន្នផលល្អប្រសើរក្នុងការភ្ញាស់ស៊ុត គឺអាស្រ័យទៅលើការជ្រើសរើសបង្កាត់ពូជ ណភាពចំណីសំរាប់បំប៉ន និងការថែរក្សាឈ្មោល, ញី។

១/ គុណភាពពូជ : កូនមាន់បានទទួលការបន្តពូជពីមេបានូវបញ្ហាសែនទាំងឡាយ ។ សំណូមពររបស់ហ្វូងនីមួយៗដែលមានផលប្រយោជន៍ដល់សេដ្ឋកិច្ច នោះគឺត្រូវមានអាត្រាញាស់ខ្ពស់ ។ ទំនាក់ ទំនងនៃបញ្ហានេះបានត្រូវបញ្ជាក់យ៉ាងច្បាស់អំពីការថែរក្សា គឺធ្វើយ៉ាងណាដើម្បីរក្សាថាមពលសំរាប់ បញ្ចេញស៊ុត និងអាត្រាញាស់អោយបានល្អ។ មាន់ញីខ្លះអាចពងនៅពេលយប់ដូច្នេះអាត្រាញាស់ទាប និងអាត្រាកំនកំណើតក៏ទាបដែរ ដូច្នេះមិនត្រូវយកស៊ុតនៃមេមាន់នោះទៅភ្ញាស់ទេ។

គេបានធ្វើការសង្កេត និងពិនិត្យឃើញថាអាត្រាខ្ពស់នៃស៊ុតមាន់ដែលគ្មានកំនកំណើតគឺស្ថិតនៅក្នុងឆ្នាំដំបូង តែចំពោះឆ្នាំក្រោយបន្ទាប់មកអាត្រាមិនញាស់នេះនឹងត្រូវថយចុះជាលំដាប់ ហើយឆ្នាំក្រោយៗមកទៀតរឹតតែថយចុះយ៉ាងខ្លាំង ។ បញ្ហានេះក៏មានទំនាក់ទំនងទៅនឹងសមាមាត្រនៃការដាក់ឈ្មោលបង្កាត់ដែរ ។

**សមាមាត្រនៃការដាក់ឈ្មោលក្នុងការបង្កាត់គឺ :**

- មាន់ចិញ្ចឹមយកស៊ុតដើម្បីភ្ញាស់ត្រូវដាក់ឈ្មោល១ក្បាល / ញី១២ក្បាល
- មាន់ចិញ្ចឹមយកសាច់ត្រូវដាក់ឈ្មោល១ក្បាល / ញី ៨ - ១០ ក្បាល
- មាន់បារាំងត្រូវដាក់ឈ្មោល១ក្បាល / ញី ១០ - ១២ ក្បាល
- គ្មានត្រូវដាក់ឈ្មោល១ក្បាល / ញី ៥ក្បាល
- ទាត្រូវដាក់ឈ្មោល១ក្បាល / ញី ៥ - ៧ក្បាល

អាត្រាកំណកំណើតនេះ ក៏អាស្រ័យទៅនឹងគុណភាពចំណី, អាយុ អាកាសធាតុ និងសុខភាព របស់ហ្វូងពូជ។ ស៊ុតដែលយើយកទៅភ្ញាស់ ត្រូវយកក្រោយរយៈពេល១០ថ្ងៃនៃថ្ងៃដែលយើងបាន ដាក់ឈ្មោលបង្កាត់ជាមួយនឹងមេ គឺដើម្បីអោយអាត្រាញាស់ខ្ពស់ ។

២/ ការផ្តល់ចំណី : អាត្រាមានកំនកំនើត និងញាស់ខ្ពស់វាក៏មានទំនាក់ទំនងទៅនឹងចំណីអាហារ រួមទាំងការថែរក្សាដែរ ។ចំពោះគុណភាពចំណីវិញគឺប្រូតេអ៊ីន, វិតាមីន អំបិល សារធាតុរក្ខយស៊ីត និងលីពីតសុទ្ធតែមានឥទ្ធិពលយ៉ាងខ្លាំងដល់អាត្រាញាស់ ។ ចំណែកប្រូតេអ៊ីនវិញបើយើងផ្តល់ អោយមាន់ទាបពេក រឺក៏ខ្ពស់ពេកអាចធ្វើអោយថយដល់អាត្រាញាស់។ តាមធម្មតាត្រូវមានប្រូតេអ៊ីនប្រហែល ១៧%នៅក្នុងចំណីសំរាប់មាន់ពង ។

ប្រូតេអ៊ីនដែលមានដើមកំណើតពីសត្វ គឺមានតំលៃជីវសាស្ត្រខ្ពស់ជាងប្រូតេអ៊ីនដែលមានប្រភពពីរុក្ខជាតិ ។ ដូច្នេះត្រូវរក្សាគុណភាព និងចំនួន ១/៣នៃប្រូតេអ៊ីននៅក្នុងចំណីដែលមានប្រភពមក ពីសត្វ ។ ចំពោះវិតាមីន A, D, E សុទ្ធតែមានឥទ្ធិពលដល់អាត្រាញាស់ ដូច្នេះយើងត្រូវបំពេញអោយ បានគ្រប់គ្រាន់នៅក្នុងចំណី។ ការខ្វះធាតុរ៉ែ (Oligoelement) ធ្វើអោយប៉ះពាល់ដល់អាត្រាញាស់ ជាពិសេសគឺកាលស្យូម (Ca) ត្រូវមានបរិមាណគ្រប់គ្រាន់នៅក្នុងចំណីមាន់ពង ។ ចំណែកទឹកក៏ជា អង្គធាតុមួយសំខាន់ដែរក្នុងការលូតលាស់របស់សត្វ គឺត្រូវធ្វើយ៉ាងណារក្សា

និងធានានូវបរិមាណទឹកអោយបានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់សត្វ។ ទោះបីហ្វូងពូជល្អ តែការថែទាំមិនបានល្អ នោះ ការចិញ្ចឹមរបស់យើងក៏ពុំទទួលបានទិន្នផលល្អដែរ ។

៣/ របៀបរើស និងរក្សាស៊ុត : យើងត្រូវរៀបចំកំរាល និងសំបុកពងអោយបានស្អាត និងស្ងួត ជាប្រចាំ។ យើងត្រូវឧស្សាហ៍រើសស៊ុតអោយបានច្រើនដងក្នុងមួយថ្ងៃ គឺដើម្បីជៀសវាងនូវការកាយកប់ស៊ុតទៅក្នុងអង្កាម ហើយការរក្សាស៊ុត គឺត្រូវតំរៀបក្បាលស្រួចចុះក្រោមទៅលើប្រដាប់ទ្រស៊ុត ។ យើងតំរៀបដាក់ដូច្នេះ គឺសំរាប់ការពារនៅពេលយើងដឹកជញ្ជូន គឺកុំអោយមានការប៉ះទង្គិច និងហាម ជាដាច់ខាតមិនត្រូវយកស៊ុតទៅលាងទឹកទេ។ យើងត្រូវយកស៊ុតទៅរក្សានៅក្នុងបន្ទប់ដែលមាន សីតុ ភាព ពី 15 - 20 °C នឹងមានសំណើមពី ៧០ - ៧៥ % ។ តាមលក្ខណៈបច្ចេកទេសយើងមិនត្រូវរក្សា អោយហួសក្នុងរយៈពេល៧ថ្ងៃ ដើម្បីយកទៅភ្ញាស់ទេ ។

ស៊ុតដែលយើងយកទៅភ្ញាស់ត្រូវជៀសវាងនូវស៊ុតណាដែលប្រឡាក់ ប្រេ វៀច ស្តួច វែង សំបកស្តើងពេក និង គគ្រាត ។ យើងអាចធ្វើការរំងាប់មេរោគ ចំពោះស៊ុតដែលត្រូវយកទៅ ភ្ញាស់ ដោយប្រើនូវធាតុគីមីផ្សេងៗ ដែលមានកំហាប់ផ្សាយដូចជាហ័ម៉ុល (formol 0,5%) កាលស្យូមអ៊ីដ្រូកស៊ីត ($Ca(OH)_2$ 0,2%) ។ ម្យ៉ាងទៀតយើងអាចលាយអ៊ុយ៉ុត ១០ក្រាម និង ប៉ូតាស្យូមអ៊ីយ៉ូន ៥ ក្រាម លាយជាមួយ និងទឹកបិត ១០០០ មល បន្ទាប់មកយើង យកស៊ីតដាក់ លាយក្នុងសូលុយស្យុង ខាងលើ ក្នុងរយៈពេល ៣០ វិនាទី ទៅ ១ នាទី រួចហើយយើងត្រូវប្រញាប់ យកស៊ុតចេញពីសូលុយស្យុងទៅដាក់ក្នុង ប្រដាប់ទ្រស៊ុតដែលប្រើកង្ហារបក់ដើម្បីអោយស៊ុតស្ងួត គឺ ជាការស្រេច ។

ឧទាហរណ៍ អ៊ុយ៉ូត ១០ ក្រ+ KI 5g + 1000 ml ទឹកបឹត ទៅ រយៈពេលពី ៣០ -១ យកស៊ុតចេញដោយប្រើកង្ហារបក់ ។

## ៣. ប្រភេទម៉ាស៊ីនក្រាប និងភ្ញាស់កូនមាន់ : (ព្រែកសំរោង)

១/ លក្ខណៈរបស់ទូរក្រាប : ទូរក្រាបមានលក្ខណៈធំ និងមានទូរចំនួន ៦ដែលភ្ជាប់គ្នាពីរៗហៅថាទូរភ្លោះ។ទូរនិមួយៗអាចផ្ទុកបានរហូតដល់ ១២២៤០គ្រាប់ ។ នៅក្នុងទូរនិមួយៗមាន :

- ❑ កម្មាទៅសងខាងជញ្ជាំងមានចំនួនពីរ
- ❑ មានសីតុណ្ហមាត្រចំនួន ៤ដើម

ឧបករណ៏សំរាប់ដាក់កញ្ច្រែងស៊ុតមានចំនួន ១៨ ថ្នាក់ក្នុងមួយផ្នែក

- ❑ មានម៉ូទ័រចំនួនមួយគ្រឿងដាក់ពីក្រោមទូរសំរាប់ទាញបង្វិលឧបករណ៏ដាក់កញ្ច្រែងស៊ុត

មានម៉ូទ័រ - សំរាប់បញ្ចេញនូវសំណើមដែលលើសមានរន្ធសំរាប់បញ្ចូលសំណើម និងរន្ធជាច្រើនទៀតសការស្រូបយកនូវអុកស៊ីហ្សែន និងបញ្ចេញនូវឧស្ម័នCO2 ចេញមកខាងក្រៅ ។

២/ លក្ខណៈរបស់ទូរភ្ញាស់ : នៅក្នុងទូរភ្ញាស់មានឧបករណ៏សំរាប់ដាក់កញ្ច្រែង រាប់ដាក់កញ្ច្រែងស៊ុតចំនួនផ្នែក។ ផ្នែកនិមួយៗអាច ១អាចផ្ទុកកញ្ច្រែងស៊ុតបានចំនួន ៣០ នុះស្ថិតនៅក្នុងទូរទាំងមូលអាចផ្ទុកបាន ១២០ គ្រាប់ ។ នួន ១២ យក្នុងកញ្ច្រែងនិមួយៗអាចផ្ទុកស៊ុតបានចំហើយក្នុ ចផ្ទុកបាន ៧២០០ គ្រាប់ ។

៣/ ការធ្វើអនាម័យលើម៉ាស៊ី - ភ្ញាស់ ភ្ញាស់ :

ក/ ការធ្វើអនាម័យលើម៉ាស៊ីនក្រាប : ត្រូវបានរៀបចំឡើងជារៀងរាល់ពេល ដែលត្រូវបញ្ចូល ក. ស៊ុតចូលទៅក្នុងទូរ។ នៅក្នុងទូរក្រាប ការរំងាប់មេរោគត្រូវបានប្រើប្រាស់ដោយសូលុយស្យុងពៃរម៉ង់ កាណាតឌីប៉ូតាសចំនួន 50mg. ទឹកបរិសុទ្ធចំនួន នួន 40ml ដាក់លាយបញ្ចូលគ្នា រួចហើត្រូវយកទៅដាក់ នៅក្នុងទូរក្រាបផ្នែកខាងក្រោម រួចបិទទ្វារទូរអោយជិតក្នុងរយៈពេល ១៥នាទី ។

ខ/ ការធ្វើអនាម័យលើម៉ាស៊ីនភ្ញាស់ : ក្រោយពីកូនមាន់ត្រូវបានយកចេញពីទូរភ្ញាស់រួចមកមុននឹងរៀបចំស៊ុតដាក់ក្នុងទូរភ្ញាស់ម្តងទៀត ចាំបាច់ត្រូវធ្វើការលាងសំអាតជាមុនសិន ដោយប្រើសាប៊ូ ដុសលាង ហើយបោសសំអាតទឹកចេញពីក្នុងទូរ និងធ្វើការកំដៅអោយស្ងួត ទើបបញ្ចូលស៊ុតសារជាថ្មី។

## ៤. បណ្តាលក្ខខ័ណ្ឌចាំបាច់ក្នុងការភ្ញាស់ :( ម៉ាស៊ីនភ្ញាស់)

ការលូតលាស់របស់អំប្រីយ៉ុង បានចាប់ដំណើរការតាំងពីពេលដែលកោសិកាបន្តពូជស៊ុតញីនិង ឈ្មោលជួបគ្នាមកម្លេះ។ ដូច្នេះនៅក្នុងដំណើរការភ្ញាស់ដោយម៉ាស៊ីនភ្ញាស់ ត្រូវមានទំនាក់ទំនងអំពីសីតុ ណ្ហភាព, សំណើម ប្រព័ន្ធខ្យល់ និងការកែប្រែត្រលប់ស៊ុត ដែលមានលក្ខណៈដូចការភ្ញាស់ដោយធម្ម ជាតិដែរ ។

១. អំពីសីតុណ្ហភាព : សីតុណ្ហភាពមានសារៈសំខាន់ណាស់ នៅក្នុងដំណើរការភ្ញាស់ស៊ុតទៅតាមតំណាក់កាលនិមួយៗ។ សីតុណ្ហភាពខ្ពស់ រឺទាបពេក សុទ្ធតែធ្វើអោយមានឥទ្ធិពលដល់ដំណើរការ ភ្ញាស់ស៊ុត ។ នៅក្នុងដំណើរការភ្ញាស់ស៊ុត គេចែកចេញជាបីតំណាក់កាលគឺ :

ក/ តំណាក់កាលទី១ : គឺចាប់ពី ១ - ១៣ថ្ងៃ គឺត្រូវការសីតុណ្ហភាពពី ៣៧៥ - ៣៧.៨◦C និងសំណើមគឺ ៧៥% ហើយត្រូវប្រែត្រឡប់ក្នុងរយៈពេល ២ម៉ោងម្តង ។

ខ/ តំណាក់កាលទី២ : គឺចាប់ពី ១៤ - ១៨ថ្ងៃ គឺត្រូវការសីតុណ្ហភាព ៣៧ ◦C និងសំណើមលើស៧៥ % ហើយត្រូវប្រែត្រឡប់ក្នុងរយៈពេល ២ម៉ោងម្តង ។

គ/ តំណាក់កាលទី៣ : គឺចាប់ពី ១៩ - ២១ថ្ងៃ ត្រូវការសីតុណ្ហភាព 36 ◦C និងសំណើម ៧៥% ដោយមិនចាំបាច់ប្រែ រឺត្រឡប់ទៀតទេ ។

នៅក្នុងដំណើរការភ្ញាស់ ប្រសិនបើសីតុណ្ហភាពមានការខុសគ្នា ពី 2-3 ◦C ក្នុងរយៈពេលយូរ នោះការលូតលាស់របស់អំប្រីយ៉ុង ត្រូវយឺត រឺក៏ត្រូវបញ្ឈប់ទាំងស្រុង។ បើសីតុណ្ហភាពកាន់តែទាបជាង នេះទៀតនោះ គឺអំប្រីយ៉ុងមិនអាចលូតញាស់បានឡើយ។ បើសីតុណ្ហភាពឡើងដល់ 42-43 ◦C នោះអំប្រីយ៉ុងអាចស្លាប់ក្នុងរយៈពេល ពី ២-៣ ម៉ោង ។

ចំពោះមេមាន់ដែលក្រាបដោយធម្មជាតិ ការខុសគ្នាពី ៥-១០ ◦C ទោះគ្មានឥទ្ធិពលដល់ដំនើរការភ្ញាស់ទេ ព្រោះមេមាន់អាចបង្វិលស៊ុតដោយខ្លួនវា។ តែបើសីតុណ្ហភាពខ្ពស់ជាងធម្មតា នោះកូន មាន់ និងកូនទា រហ័សញាស់តែមិនស្មើគ្នា ព្រោះសរីរាង្គខ្លះលូតលាស់មិនគ្រាប់លក្ខណៈ ធ្វើអោយកូទ មាន់មានកំលាំងខ្សោយ ។

ឱ. ចំនួនលើ និងក្រោមបិទមិនជិត រឺក៏ខ្លីពេក និងដូររោមមិនគ្រប់លក្ខណៈ ។

២. រយៈពេលញាស់ :

- មាន់ ពី ១៩ - ២១ថ្ងៃ
- ទា ពី ២៨ - ២៩ថ្ងៃ
- ក្ងាន ពី ៣៥ - ៣៦ថ្ងៃ
- ទាកាប៉ា ពី ៣១ - ៣២ថ្ងៃ
- ក្រួច ពី ១៦ - ១៧ថ្ងៃ

- ព្រាប ពី ១៦ - ១៧ថ្ងៃ (VN) រឺ ពី ១៧- ១៩ថ្ងៃ ( អប់រំ )
- មាន់បារាំង ២៦ថ្ងៃ

### ៣. អំពីសំណើម :

សំណើមក៏មានតួនាទីសំខាន់ណាស់ដែរ នៅក្នុងដំណើរការភ្ញាស់ស៊ុត ។

ក/ សំណើមខ្ពស់ : ប្រសិនបើសំណើមខ្ពស់ នោះរការបំភាយទឹកចេញពីស៊ុតគឺបានតិច ដូច្នេះនពេល ដែលយើងប្តូរទៅឃើញស្អប់ខ្យល់នៅធម្មតា រឺក៏ប្រែប្រួលតិចតួចនោរ អំប្រើយ៉ុងនឹងមានសភាពខ្សោយញាស់ចេញមកពុំរួច រឺក៏ញាស់ចេញមកមានទំងន់ខុសធម្មតា មានការលូតលាស់យឺត រឺជួនកាលញាស់ ចេញមកបានកូនធំ តែមានសភាពខ្សោយដោយសារវាហើមទឹក ។

ខ/ សំណើមទាបៈ ក្នុងដំណើរការភ្ញាស់ ប្រសិនបើសំណើមទាបវិញនោះ ការបំភាយទឹកចេញពីស៊ុតបានច្រើន។ បើសំណើមកាន់តែទាបនោះ ឃ្លប់ខ្យល់កាន់តែរីកធំ ធ្វើអោយអំប្រីយ៉ុងបឺតស្រូប យកសារធាតុចិញ្ចឹមនៅក្នុងពងស និងពងក្រហមមិនបាន។

ដូច្នេះអំប្រីយ៉ុងនឹងខ្សោយ មិនគ្រប់កំលាំង ដើម្បីទំលាយសំបកចេញមកក្រៅ។ តែបើញាស់បានគឺមានទំងន់ស្រាល មាឌតូច រោមជាប់នឹងសំ បក គឺជាប់នៅកន្លែងពោះ និងខ្នង ។

### ៤. ប្រព័ន្ធខ្យល់ :

អាស្រ័យដោយបណ្តូររូបធាតុរបស់អំប្រីយ៉ុង គឺវាត្រូវការ $O_2$ ហើយបញ្ចេញនូវ $CO_2$, $H_2S$ $NH$, មកខាងក្រៅ។ នៅក្នុងដំណើរការភ្ញាស់ត្រូវរក្សាប្រព័ន្ធខ្យល់អោយបានសមស្រប ដើម្បីការលូតលាស់របស់អំប្រីយ៉ុង ។ សេចក្តីត្រូវការ $O_2$ នៅក្នុងម៉ាស៊ីនភ្ញាស់គឺ ២១% និង $CO_2$ ពី 0,04-0,15% តែបើ $O_2$ មានកំរិតក្រោម ១៥% និង $CO_2$ ឡើងដល់ 1, 5% វិញនោះ គឺបណ្តាលអោយខូចខាតដល់ ការលូតលាស់របស់អំប្រីយ៉ុង ។

### ៥. ការប្រែត្រឡប់ស៊ុត :

នៅក្នុងដំណើរការក្រាបត្រូវមានការកែប្រែត្រឡប់ស៊ុត ដើម្បីកុំអោយកូនដែលញាស់មក មានការជាប់ស្អិតទៅនឹងសំបក ញាស់ចេញមកពុំរួច រឺក៏ញាស់ចេញមកមានរូបរាងមិនធម្មតា។

បច្ចុប្បន្ន ម៉ាស៊ីនភ្ញាស់ទំនើបៗ មានការប្រែត្រលប់ស៊ុតដោយស្វ័យប្រវត្តិក្នុងរយៈពេល ១ - ២ ម៉ោងម្តង ។

## ៥. របៀបភ្ញាស់ និងការផ្ទុះស៊ុត :

១. ការភ្ញាស់ស៊ុតមានពីរយ៉ាងគឺ : ការភ្ញាស់ដោយធម្មជាតិ និងការភ្ញាស់ដោយម៉ាស៊ីន ។

ក/ ការភ្ញាស់ដោយធម្មជាតិ :

ការភ្ញាស់របៀបនេះ គឺមេមាន់ក្រាប ក្រាស់ដោយខ្លួនវា ដូច្នេះយើងត្រូវរៀបចំធ្វើសំបុកពង និងផ្តល់ចំណីអោយវាស៊ីអោយបានគ្រប់គ្រាន់ ដើម្បីធានាសុខភាពក្នុងរយៈពេលក្រាប ។

ខ/ ការភ្ញាស់ដោយម៉ាស៊ីនភ្ញាស់ :

ម៉ាស៊ីនភ្ញាស់ដោយអគ្គិសនីមានចំណុះផ្សេងៗពីគ្នា ការប្រើកំដៅ គឺប្រើដោយរេស៊ីស្តង់ និងប្រើ កង្ហារដើម្បីរក្សាលំនឹងកំដៅ កែតំរូវកំដៅដោយស្វ័យប្រវត្តិ។ ចំពោះបញ្ហាសំណើមវិញ គឺបញ្ជាដោយម៉ាស៊ីនបាញ់ចំហាយ រីឯការត្រឡប់ស៊ុត ក៏ធ្វើឡើងដោយស្វ័យប្រវត្តិដែរ។ ម៉ាស៊ីនក្រាបធំៗ អាចផ្ទុក បានស៊ុតចំនួនពី ២០០០០ - ៥០០០០ ពង។

២. ការឆ្លុះស៊ុត : ការឆ្លុះស៊ុតត្រូវធ្វើឡើងនៅក្នុងបន្ទប់ងងឹត ប្រើដោយឧបករណ៍ឆ្លុះស៊ុត (អូវ ស្កុប > មានរាងដូចបាល់ មានដៃសំរាប់កាន់ និងមានបំពង់ស៊ីឡាំង១ប៉ុនពងមាន់ដែលក្នុងនោះមានដាក់ អំពូលភ្លើងមូលមួយ ។

ក/ការឆ្លុះលើកទី១ : គឺនៅពេលដែលយើងដាក់ស៊ុតក្នុងទូរក្រាបបានរយៈពេល ៧ថ្ងៃ ។ ពេលឆ្លុះទៅឃើញមានបណ្តាញសរសៃឈាម និងសំបកស៊ុតមានពណ៌ផ្កាឈូក នោះបញ្ជាក់ថាស៊ុតមានកំណ កំណើត ។ តែបើឆ្លុះទៅឃើញពងក្រហមថ្លា នោះបញ្ជាក់ថាស៊ុតគ្មានឈ្មោល ។

ខ/ ការឆ្លុះលើកទី២ : គឺឆ្លុះនៅថ្ងៃទី ១៤។ ៤។ បើសិនជាឆ្លុះនឹងអំពូល 200w នោះយើងនឹងឃើញអំប្រីយ៉ុងកំរើកច្បាស់ ។ ករណីអំប្រីយ៉ុងលូតលាស់ ឃ្លប់ខ្យល់រីកធំជាងធម្មតា ហើយមានព្រំដែន ច្បាស់លាស់ ។ ចំពោះអំប្រីយ៉ុងដែលងាប់វិញ គេពុំឃើញមានព្រំដែនខ័ណ្ឌច្បាស់លាស់ទេ ហើយសំបក មានពណ៌ប្រផេះ រឺខ្មៅ។ ស៊ុតដែលពិនិត្យឃើញថាមិនល្អ ត្រូវយកចេញភ្លាមដើម្បីកុំអោយខូចទៅដល់ ស៊ុតផ្សេងទៀត ។

គ/ការឆ្លុះលើកទី៣ : គឺធ្វើឡើងនៅថ្ងៃទី១៨ ដើម្បីរើសកូនដែលលូតលាស់ល្អ ដាក់បញ្ចូលទៅក្នុងទូរភ្ញាស់ ។

- ចំណាំ : ស៊ុតដែលយើងជំរុះនៅថ្ងៃទី៧ យើងអាចយកទៅប្រើការបាន ប៉ុន្តែស៊ុតដែលយើងជំរុះ យកចេញនៅថ្ងៃទី ១៤ គឺមានលក្ខណៈស្អុយប្រសិនបើវាបែក នោះវាធ្វើអោយប៉ះពាល់ដល់ស៊ុតផ្សេង ទៀត ពិសេសគឺអាចចំលងជំងឺផ្សេងៗបាន ។

សូមអរគុណ

# មេរៀនទី៥   ការជ្រើសរើសទីតាំងនិងប្រព័ន្ធចិញ្ចឹមមាន់នៅក្នុងកសិដ្ឋាន

## ១.ការជ្រើសរើសទីតាំង :

កសិដ្ឋានរឺទីកន្លែងសំរាប់ចិញ្ចឹមមាន់ទោះបីជាតូចក្តីរឺធំក្តីត្រូវសាងសង់នៅលើកន្លែងទួលដែលមិនលិច  ទឹក  ហើយឆ្ងាយពីភូមិរបស់ប្រជាជន  តែត្រូវមានផ្លូវគមនាគមន៍ចេញចូលទៅមកបានងាយស្រួលនិង  ជាកន្លែងដែលអាចពន្យាទឹកសំរាប់ប្រើប្រាស់បានគ្រប់រដូវ  ហើយពុំធ្លាប់កើតជំងឺឆ្លង ។យើងត្រូវជីកអ  ល្អាងយកទឹកទៅពិសោធន៍មើលតើអាចប្រើប្រាស់បានរឺមិនបាន ។ក្រៅពីនេះយើងត្រូវយល់ដឹងទៅលើ   អាកាសធាតុគឺការជ្រើសរើសយកធាតុអាកាសមធ្យម   កុំអោយមានការប្រែប្រួលខុសគ្នាខ្លាំងពេកគឺ  រវាងពេលយប់និងពេលថ្ងៃ  ព្រោះវាអាចបណ្តាលអោយសត្វឆាប់ទទួលនូវជំងឺ ។ ជាពិសេសនៅក្រោយពេលដែលយើជ្រើសរើសទីតាំង និងសាងសង់អគាររួចត្រូវតែធ្វើរបងព័ទ្ធជុំ  វិញកន្លែងចិញ្ចឹមអោយបានកំពស់២ម   ដើម្បីការពារកុំអោយចំលងជំងឺរវាងសត្វព្រៃនិងសត្វស្រុក  ។  នៅតាមច្រកចេញចូលនៃកន្លែងចិញ្ចឹមជាពិសេសគឺច្រកផ្លូវសំរាប់យើងចេញចូលត្រូវធ្វើកន្លែងដាក់ថ្នាំ     សំរាប់សំលាប់មេរោគនិងការពាររោគរាតត្បាតផ្សេងៗនៅពេលដែលឆ្លងកាត់។ អ្វីដែលទាក់ទងទៅ នឹងអនាម័យនៃការចិញ្ចឹមត្រូវតែរៀបចំធ្វើអោយបានសព្វគ្រប់ដូចជាកន្លែងសំរាប់កបរីដុតសាកសព របស់សត្វនិងត្រូវធ្វើបន្ទប់អនាម័យសំរាប់មនុស្ស ។

## ២ ប្រព័ន្ធចិញ្ចឹមមាន់នៅក្នុងកសិដ្ឋាន

ការចិញ្ចឹមមាន់នៅក្នុងកសិដ្ឋានរឺស្ថានីយ៍គេធ្វើឡើងតាមប្រព័ន្ធពីរបែបគឺ :

### ក. ការចិញ្ចឹមមាន់នៅក្នុងទ្រុងលាត :

ការចិញ្ចឹមរបៀបនេះមាន់មានសេរីភាពក្នុងការធ្វើចលនាដើរចុះឡើង        រំរត់លោតទៅតាមចំណង់ចំ ណូលចិត្តរបស់វា ។ មាន់អាចស្រូបយកខ្យល់អាកាសបានល្អហើយវាអាចបង្កើនសមត្ថភាពរបស់វាប្រ វាំងនឹងជំងឺហើយបណ្តូររូបធាតុគីមីនៅក្នុងខ្លួនខ្ពស់ ។ផលិតស៊ុតនិងសាច់ក៏ទទួលបានក្នុងលក្ខណៈខ្ពស់ ដែរ ។ ការជ្រើសរើសយកស៊ុតយកទៅភ្ញាស់តាមការចិញ្ចឹមបែបនេះ គឺមានលក្ខណៈប្រសើរបំផុត ប៉ុន្តែចំពោះបរិមាណនៃការផ្តល់ស៊ុតវិញគឺតិចជាងការចិញ្ចឹមក្នុងទ្រុងកា។

## ខ. ការចិញ្ចឹមមាន់នៅក្នុងទ្រុងកា :

ការចិញ្ចឹមមាន់នៅក្នុងទ្រុងការនេះគឺវាគ្មានសេរីភាពក្នុងការធ្វើចលនាចុះឡើងបានឡើយ គឺវាស្ថិត នៅតែមួយកន្លែងប៉ុណ្ណោះ ព្រោះគេធ្វើទ្រុងខ័ណ្ឌពីចន្លោះមួយទៅចន្លោះមួយសំរាប់មួយក្បាលរឺសំរាប់ ពីរក្បាលតែប៉ុណ្ណោះ ។ការចិញ្ចឹមរបៀបនេះយើងអាចតាមដានពិនិត្យសុខភាពរបស់វា ជាពិសេសយើ ងអាចដឹងថាតើវា
ផ្តល់ស៊ុតរឺក៏មិនផ្តល់ស៊ុត ។

ការចិញ្ចឹមរបៀបនេះយើងត្រូវចំណាយថវិកាច្រើនទៅលើលាំងពលកម្ម

សំភារៈទ្រុងនិងការថែ រក្សា បោសសំអាតតែផលិតផលស៊ុតគឺបានច្រើន ។ការចិញ្ចឹមរបៀបនេះយើងអាចយកស៊ុតទោធ្វើអា ជីវកម្ម តែពុំអាចយកទៅភ្ញាស់បានទេ ។

- សន្និដ្ឋាន : ការចិញ្ចឹមមាន់តាមរបៀបខាងលើទាំងពីរនេះគឺមានភាពងាយស្រួលម្យ៉ាងម្នាក់ ប៉ុន្តែជា ទូទៅដើម្បីចិញ្ចឹមមាន់ទុកពូជឬយកសាច់គឺគេត្រូវចិញ្ចឹមនៅក្នុងទ្រុងលាត រីឯការចិញ្ចឹមយកស៊ុតធ្វើ អាជីវកម្មគឺត្រូវចិញ្ចឹមនៅក្នុងទ្រុងការទើបទទួលបាននូវទិន្នផលខ្ពស់ ។






## ៣.លក្ខណៈទ្រុងសំរាប់ចិញ្ចឹមមាន់ :

ទ្រុងចិញ្ចឹមមាន់ត្រូវសាងសង់ឡើងដោយបានគិតគូរអំពីអនាម័យដែលមានលក្ខណៈសន្សំសំចៃនិងនាំមកនូវភាពសុខស្រួល ។ដើម្បីសំរេចនូវគោលបំនងនេះទ្រុងមាន់ត្រូវមានលក្ខណៈដូចខាងក្រោម :

### ក/ លក្ខណៈដែលត្រូវអនុវត្ត :

- ❑ សង់នៅលើកន្លែងមិនលិចទឹក
- ❑ មានពន្លឺថ្ងៃចេញចូល
- ❑ ធានាខ្យល់អាកាសចេញចូលបានល្អ
- ❑ ងាយស្រួលដល់ការសំអាតនិងធ្វើអនាម័យ

- ពារកុំអោយចាប់រឺសត្វដទៃទៀតចូលធ្វើសំបុក
- សំភារៈសំណង់ត្រូវប្រើឈើច្រើនជាងស៊ីម៉ង់ត៍
- ដំបូលត្រូវប្រក់ហ្វីប្រូរីក៏សង្កសីហើយត្រូវធ្វើពិដានបញ្ឆោតជៀសវាងកុំអោយក្តៅខ្លាំងពេក
- ជញ្ជាំងទ្រូងត្រូវហ៊ុំព័ទ្ធដោយសំណាញ់ដែកក្រឡាញឹក ។



## ខ/ ការរៀបចំនៅក្នុងទ្រុង :

- ទ្រុងមាន់ត្រូវមានលក្ខណៈងាយស្រួលដល់ការសំអាត គួរជៀសវាងទីកន្លែងងងឹត កៀន កោះនិងពិបាកត្រួតពិនិត្យ ។ការសំអាតនិងថែរក្សាគឺជាភារកិច្ចចាំបាច់ ដើម្បីកុំអោយមានមេរោគផ្សំ តនៅលើកំរាល រឺលើសំបុកពងនិងនៅលើសំភារៈផ្សេងៗទៀត។



- ត្រូវលាបកំបោរសនៅខាងក្នុងទ្រុង ជញ្ជាំងនិងសំភារៈផ្សេងៗ ព្រោះទឹកកំបោរសអាចសម្លាប់មេរោគ ជាពិសេសការពារមិនអោយមានពពួកបារាស៊ីតនៅជាប់លើទ្រូង។
- ត្រូវជំរះស្មៅជុំវិញទ្រុងចំងាយប្រហែល២ម៉ែត្រ -
- ត្រូវរៀបចំបណ្តាញភ្លើងក្នុងទ្រុង
- ត្រូវបាញ់ថ្នា Formol । ២% រឺក្រេស៊ីល ២% ទៅលើផ្ទៃជុំវិញទ្រុង ជញ្ជាំង កំរាល និងដំបូលជាលើកទីពីរ ។
- ត្រូវក្រាលអង្កាលរឺអាចម៍រចម៍រណាក្នុងទ្រុងអោយបានកំរាស់ពី១០-១៥ស.ម ។
- ត្រូវដាក់ស្នូកទឹកសំរាប់រំងាប់មេរោគ ងាប់មេរោគ ដោយប្រើកំបោរសនៅតាមផ្លូវ ចេញចូលក្នុងទ្រុង ។
- ត្រូវដុសលាងស្នូកទឹកស្នូកចំណីរួចហើយទើបលាបលាងជាមួយសូលុយស្យុងតែម៉ង់កាណាតទៀត ដោយរក្សាទុកអោយបានស្ងួតល្អ ។
- កំរាលអង្កាមរឺអាចម៍រណាដែលក្រាលនៅក្នុងទ្រុង ទ្រុង ត្រូវឧស្សាហ៍ផ្លាស់ប្តូរជាប្រចាំ។
- ស្នូកទឹកនិងស្នូកចំណីមិនត្រូវធ្វើអំពីវត្ថុណាដែលនាំ លនាំអោយមានប្រតិកម្មបង្កើតជាច្រេះទេហើយត្រូវរៀបចំកុំអោយមាន់ឡើងជាន់បាន។
- ស្នូកចំណីត្រូវរៀបចំយ៉ាងណាអោយសមាមាត្រទៅនឹងចំនួនមាន់ គឺថានៅពេលដែលយើងដាក់ចំណីហើយមាន់ទាំងអស់នៅក្នុងទ្រុងអាចចូលស៊ីចំណីបានព្រមគ្នា ។

- ផ្ទៃក្រឡានៃទ្រុង :
- ចំពោះមាន់ចិញ្ចឹមយកស៊ុតត្រូវដាក់ពី ៥-៦ក្បាល់ ក្នុងមួយម៉ែត្រក្រឡា
- ចំពោះមាន់ចិញ្ចឹមយកសាចវិញត្រូវដាក់ពី ២.៥-៣ក្បាល ក្នុងមួយម៉ែត្រក្រឡា
- (គឺប្រហែលពី ១០-១២ Kgនៃទំងន់ ក្នុងមួយម៉ែត្រក្រឡា)
- គ/ ទីធ្លាសំរាប់មាន់រត់លេង :
- នៅក្នុងបណ្តាប្រទេសដែលជឿនលឿន ការចិញ្ចឹមគឺគេមានជីវជាតិគ្រប់គ្រាន់ក្នុងការផ្សំចំណី ដូច្នេះទីធ្លាសំរាប់លេងមិនចោទជាបញ្ហាទេ ប៉ុន្តែបើសមាសធាតុចំណីមានជីវជាតិពុំគ្រប់គ្រាន់ទេនោះ ម៉ាបាច់ត្រូវមានទីធ្លាសំរាប់មាន់រត់លេងនិងដើររកស៊ីចំណីបន្ថែម ។
- ទីធ្លាសំរាប់មាន់រត់លេងមានសារៈសំខាន់ណាស់ ព្រោះវាមានស្មៅលាស់ថ្មីៗដែលជាអាហារបន្ថែម ។
- ក្នុងទីធ្លានីមួយៗត្រូវមានដើមឈើពីបីទៅបួនដើម ដើម្បីជាម្លប់ដល់សត្វ ប៉ុន្តែមិនត្រូវទុក អោយច្រើនពេកទេ ព្រោះវាជាឧបសគ្គក្នុងការលូតលាស់របស់ស្មៅ ។ប្រសិនបើស្មៅដុះច្រើនពេកយើ ងត្រូវកាត់ចេញដើម្បីអោយវាលាស់ស្មៅខ្ចីៗដែលសំបូរទៅដោយជីវជាតិអំណោយផលដល់សត្វ ។





# សូមអរគុណ

# មេរៀនទី ៦ ការផ្តត់ផ្គង់ចំណីសម្រាប់មាន់

## I.សញ្ញាណស៊ីអំពីការរៀបចំចំណីមាន់ :

ចំណីអាហារសំរាប់មាន់ ជាទូទៅផ្សំឡើងដោយទឹក និងរូបធាតុស្ងួត។ រូបធាតុស្ងួតមួយផ្នែកជារូបធាតុអសរីរាង្គ និងមួយផ្នែកទៀតជារូបធាតុសរីរាង្គ។ នៅក្នុងរូបធាតុសរីរាង្គ យើងឃើញមាន:

- ប្រូតេអ៊ីន
- ក្លុយស៊ីត ( ជាតិស្ករ )
- លីពីត ( ជាតិខ្លាញ់ )
- វីតាមីន
- អាមីដុង (ជាតិម្សៅ)
- សែលុយឡូស ( ជាតិសរសៃ )

ឯរូបធាតុអសរីរាង្គមាន : អំបិល, កាលស្យូម និងផូស្វ័រជាដើម ។

ការចិញ្ចឹមមាន់ដោយបង្ខាំងនៅក្នុងទ្រុង ការទៅតាមរបបកំណត់របស់វា។ គេចាំបាច់ត្រូវផ្តល់ចំណីអោយមាន់នូវអ្វីដែលវាត្រូវ ហេតុដូច្នេះគេតែងតែប្រើនូវប្រភេទចំណីដែលផ្សំពីរូបធាតុសរីរាង្គ និងរូបធាតុអសរីរាង្គ សំខាន់ៗខាងលើ ដែលអាចទ្រទ្រង់អោយសារពាង្គកាយសត្វលូតលាស់បានល្អ ។

## II. ការរៀបចំចំណីមាន់ :

ចំណីផ្សំរបស់មាន់ជាប្រភេទចំណីស្ងួត មិនសូវមានជាតិទឹកទេ ដូច្នេះគេផ្តល់ទឹកអោយមាន់ដោយឡែកសំរាប់ធ្វើអោយមានភាពទៀងទាត់នូវសីតុណ្ហភាពក្នុងខ្លួន រួមចំណែកធ្វើបណ្តូរសារធាតុ ក្នុងខ្លួន សំរួលដល់ការរំលាយអាហារ និងជួយបញ្ចេញនូវជាតិពុលបានមួយចំនួន។ ប៉ុន្តែបើមានបរិ មានទឹកមិនគ្រប់គ្រាន់នៅក្នុងចំណី អា និងបណ្តាលអោយទល់លាមក ។

នៅក្នុងសារពាង្គកាយបក្សី ជាធម្មតាមានជាតិទឹកពី ៦០-៧០% ហើយនៅក្នុងស៊ុតរបស់វាមានប្រហែល ៦៥% ដែរ ។មាន់នៅក្នុងតំបន់ត្រូពិកផឹកទឹកក្នុងប្រមាណប្រហែលជា ៣ដងនៃ

បរិមាណចំណីដែលត្រូវ ផ្ដល់អោយវាស៊ី និង មាន់អត់ចំណីអាចរស់បានច្រើនថ្ងៃជាងអត់ទឹក។ ការផ្ដល់ទឹកមិនគ្រប់គ្រាន់ធ្វើ អោយមាន់មិនសូវស៊ីចំណី បន្ថយការលូតលាស់ មានការធំធាត់យឺត ។ ប្រសិនបើនៅក្នុងតំណាក់កាល មាន់កំពុងពងយើងបង្អត់ទឹក និងកុំផ្ដល់អោយក្នុងរយៈពេល ២៤ម៉ោង នោះផលិតកម្មស៊ុតត្រូវធ្លាក់ ចុះប្រហែល ៣០% ហើយដើម្បីទទួលនូវផលិតកម្មស៊ុតត្រឡប់មកកំរិតធម្មតាវិញនោះ ត្រូវការ ចំណាយរយៈពេល១ខែ រឺច្រើនជាងនេះ ។

## ១.សារជាតិនៅក្នុងចំណីមាន់ :

ដើម្បីអោយមាន់ឆាបរីកធំធាត់, មាន់ពងច្រើន ហើយចំណាយចំណីអស់តិចនោះ គេត្រូវអោយមាន់ស៊ីចំណីដែលមានជីវជាតិគ្រប់គ្រាន់ ។

### ក/ ជាតិស្ករ និងជាតិខ្លាញ់:

សារជាតិទាំងពីរនេះ គឺសំរាប់ផ្ដល់ថាមពលអោយរាងកាយមានការលូតលាស់ ។

ជាតិស្ករ : មានច្រើននៅក្នុងគ្រាប់ធញ្ញជាតិ ដូចជាពោតក្រហម. ចុងអង្ករ. ម្សៅមើម ជាដើម ។ ចំពោះកូនមាន់ ជាតិស្ករមានសារៈសំខាន់ណាស់ ព្រោះវាអាចជ្រាបចូលក្នុងសារពាង្គរ ពាង្គកាយយ៉ាងឆាប់រហ័ស និងផ្ដល់ថាមពលនៅពេលដែលកូនមាន់ហត់ ( បន្ទាប់ពីការដឹកជញ្ជូន ) ។ គេអាច ផ្ដល់អោយវា ៨០ក្រាម/ទឹក១លីត្រ សំរាប់ផ្ដល់អោយកូនមាន់នៅអាយុ ២ថ្ងៃដំបូង អាចបន្ថយអាត្រាងាប់របស់វាបាន។

- ❑ ជាតិខ្លាញ់ : ជាតិនេះ៖ ផ្ដល់ថាមពលខ្ពស់ជាងស្ករ និងជាតិសាច់ ។ ប៉ុន្តែវាមិនចាំបាច់ខ្លាំងក្នុង ចំណីប៉ុន្មានទេ ។ កាកខ្លាញ់ត្រី. កាកប្រេងសល់ពីចៀននំហើយឡើងខ្មៅ រឺកាកខ្លាញ់ជ្រូកអាចប្រើ ជំនួសគ្រាប់ធញ្ញជាតិបានខ្លះៗ ។តែចំណីលាយខ្លាញ់ទាំងនេះមិនត្រូវទុកយូរទេ ព្រោះវាអាចធ្វើអោយគុណភាពចំណីថយចុះយ៉ាងឆាប់រហ័ស ។

### ខ/ ជាតិប្រូតេអ៊ីន :

មានពីរក្រុមគឺ ប្រូតេអ៊ីនដែលបានមកពីសត្វ និងប្រូតេស៊ីដែលបានមកពីរុក្ខជាតិ ។ នៅក្នុងការផ្សំចំណី យ៉ាងហោចណាស់ត្រូវមានជាតិប្រូតេអ៊ីនដែលបានមកពីសត្វ ៤៣ ព្រោះវាជាប្រូតេអ៊ីនដែល មានគុណភាពល្អជាងប្រូតេអ៊ីនដែលបានមកពីរុក្ខជាតិ ។ ជាតិប្រូតេអ៊ីនមានតួនាទីសំខាន់

ណាស់វាជួយបង្កជាសាច់ អោយមានការធំធាត់ នាងច្រើន និងការបង្កើតជាអប់ទីគ័រដើម្បីប្រឆាំងនឹងជំងឺ ផ្សេងៗ។

ដូចនេះកាលណាសត្វមានប្រូតេអ៊ីនមិនគ្រប់គ្រាន់ នោះមាន់ដោយប្រើ ស្លែកស្លាំង ក្រិន ក្រន់ពងតិច និងបណ្តាលអោយគាត់នឹកគ្នា។ វត្ថុធាតុដើមដែលមានប្រូតេអ៊ីនច្រើនគឺត្រីហាល វចែកសៀង កាកសណ្តែកដី, កាកសណ្តែកបាយ ម្សៅឈាម ។ល។

**គ/ ជាតិសរសៃ:**

វាមានច្រើននៅក្នុងពពួកស្លឹករុក្ខជាតិដូចជា : ចំបើង ស្មៅ ហើយនៅក្នុងចំណីដែលលាយ ផ្សំដោយជាតិសាសៃមិនអោយលើសពី ៥%ទេ ប៉ុន្តែប្រសិនបើមាន់ធំយើងអាចអោយវាស៊ីច្រើនជាងនេះ។ ជាតិរសៃនេះមិនអាចចាត់ទុកថាជាជាតិផ្តល់រសជាតិដល់មាន់ទេ តែបើខ្វះជាតិនេះវា បណ្តាលអោយមាន់ទល់លាមក និងអាចបើកគ្នាទៀតផង ។ អំបិលមាននៅក្នុងរបបអាហារ អាចបង្កើននូវការប្រើប្រាស់ប្រូតេអ៊ីន។ ប្រសិនបើខ្វះអំបិល នៅក្នុងចំណី បណ្តាលអោយការស៊ីរបស់មាន់មានការថយចុះប្រហែល ៥0% ។ ធម្មតានៅក្នុងចំណី ផ្សំតែប្រើអំបិលប្រហែល 0.៥%។

**ង/ កាលស្យូម និង ផូរ: (Ca , P)**

សារធាតុទាំងពីរនេះមានតួនាទីចាំបាច់ណាស់ សំរាប់បង្កើតជាឆ្អឹង និងបង្កើតសំបកស៊ុត ។ ជាតិកាលស្យូម និងផូស្វ័រមានបរិមាណប្រើនៅក្នុងសំបកខ្យង សំបកងាវ ថ្មកំបោរ,ឆ្អឹងយកមកកិនអោយម៉ត់ល្អលាយជាមួយចំណី។ ការខ្វះជាតិកាលស្យូម និងថូស្វ័រនៅក្នុងសារពាង្គកាយសត្វ បណ្តាលអោយការផលិតស៊ុតន័យចុះយ៉ាងខ្លាំង និងបន្ថយដល់ការលូតលាស់ ។

**ច/ ជីវជាតិ:**

ជីវជាតិជំនួយអោយមាន់ឆាប់ធំធាត់ រឹងមាំ និងចូលរួមក្នុងការផលិតស៊ុតផងដែរ ថ្វីត្បិតតែបរិមាណនៃពពួកជីវជាតិទាំងនេះ សារពាង្គកាយសត្វត្រូវការតិចតួចក៏ដោយ ។ ពពួកជីវជាតិទាំងនេះ គឺមាននៅក្នុងធម្មជាតិ ដូចជារុក្ខជាតិបៃតង និងនៅក្នុងគ្រាប់ធញ្ញជាតិក៏មានច្រើនណាស់ដែរ ។

- ជីវជាតិ A : ជំនួយអោយមាន់ឆាប់ធំពងច្រើន ភ្ញាស់កូនបានល្អ។ កង្វះជីវជាតិ A បណ្តាលអោយមាន់ក្រិនក្រធំភ្នែកហើមរលាកភ្នាសស្តើង។ ចំណីសំបូរជាតិនេះមាន : ខ្លាញ់ត្រី.ថ្លើមត្រី ពោតក្រហម ល្ពៅ មើមការុត និងបន្លែរុក្ខជាតិបៃតង ។
- ជីវជាតិ B : មាន B1, B2, B6 ។ល។ កង្វះជីវជាតិ B បណ្តាលអោយមាន់មានជំងឺកន្ត្រាក់សរសៃ ថយចុះការស៊ីចំណី ការលូតលាស់យឺត ។ ជីវជាតិ B, សំបូរនៅក្នុងកន្ទក់ឯជីវជាតិ$B_2$ សំបូរនៅក្នុងបន្លែស្រស់ និងពន្លកគ្រាប់ធញ្ញជាតិ ។
- ជីវជាតិ D : សំខាន់នៅក្នុងការបង្កើនការលូតលាស់នៃឆ្អឹង និងសំបកស៊ុត ។ កង្វះជីវជាតិ D បណ្តាលអោយមាន់ក្រោះ ទន់ជើង,ចំពុះទន់ ដូចនេះទ្រុងមាន់ គេត្រូវសង់ដោយអោយមានពន្លឺ ថ្ងៃជនចូលទៅក្នុងទ្រុងនៅពេលព្រឹក ។
- ជីវជាតិ E : មានមុខងារសំខាន់ក្នុងការបង្កើតពង និងធ្វើអោយកូននៅក្នុងពងធំធាត់។

ចំណីដែលសំបូរជីវជាតិ E មាន : អង្ករ ពោត ពន្លកស្រូវ សណ្តែកបណ្តុះ ថ្លើម ផ្នែកលឿងរបស់ស៊ុត គ្រាប់កប្បាស ។ល ។ កង្វះជីវជាតិ E បណ្តាលអោយមាន់មានជំងឺសរសៃប្រសាទ សាច់ដុំមិន សូវលូតលាស់.ការភ្ញាស់កូនមានការថយចុះ ។

- ជីវជាតិ K : មាននៅក្នុងរុក្ខជាតិបៃតង,ត្រី។ កង្វះជីវជាតិ K បណ្តាលអោយមាន់ស្លេកស្លាំង និងមានការហូរឈាម ។

## III. ការផ្សំចំណី :

នៅក្នុងតំបន់ត្រូពិក ជាទូទៅកូនមាន់ស៊ីចំណីអស់ជាមធ្យមពី ៤០-៥០g/ថ្ងៃ មាន់ជំទង់អស់ ពី ៦០-៧០g/ថ្ងៃ និងមាន់ធំពេញវ័យវិញស៊ីអស់មធ្យមពី ១០០-២០០g/ថ្ងៃ ។ ហេតុនេះដើម្បី អោយមាន់ស៊ីចំណីទាំងនេះ ហើយអាចទ្រទ្រង់សារពាង្គកាយអោយធំធាត់ និងផលិតពងបានច្រើន គេត្រូវលាយផ្សំចំណីដោយប្រើវត្ថុធាតុដើមដូចជា : ពោត កន្ទក់ កាកសណ្តែកសៀង កាកសណ្តែកដី ម្សៅត្រី ម្សៅខ្យង និងអំបិល ។ មុននឹងផ្សំចំណី ត្រូវបង្កើតឡើងនូវរូបមន្តផ្សំចំណីអោយបានត្រឹមត្រូវ និងត្រូវស្គាល់អត្រាសំខាន់ៗមួយចំនួនដែលមាននៅដូចខាងក្រោម :

| ឈ្មោះវត្ថុធាតុដើម | ប្រូតេអ៊ីន% | កាលស្យូម% | ផូស្វ័រ% | ថាមពលបំលែង Kcal /Kg |
|---|---|---|---|---|
| ពោត | ៨.៨ | ០.០២ | ០.២៨ | ៣២៩៥ |
| ចុងអង្ករ | ៨.៧ | ០.០៨ | ០ | ៣៥៧២ |
| កន្ទក់ម៉ត់ | ១១ | ០.០៦ | ១.៨២ | ១៦៣០ |
| សណ្តែកសៀង | ៣៨ | ០.៣២ | ០.៦៧ | ២២៤៩ |
| ម្សៅត្រីហាល | ៤៥ | ៥.៤៩ | ២.៨១ | ២៩៦៦ |
| ម្សៅខ្យង | ០ | ៣៦.០៧ | ០.០២ | ៣៨៥ |

**ចំណីមាន់ដែលល្អត្រូវផ្សំឡើងដោយ :**

- ចំណីដែលល្អ និងពោរពេញទៅដោយជាតិរ៉ែផ្សេងៗដែលសារពាង្គកាយត្រូវការ
- ជាចំណីដែលមានតំលៃថោកល្មមគួរសម
- មិនផ្អែមរលួយ រឺដុះផ្សិត
- អាចរកបានងាយនៅជិតកន្លែងចិញ្ចឹម



# មេរៀនទី ៧ ការចិញ្ចឹមកូនមាន់

## ១. កត្តាចាំបាច់ក្នុងការចិញ្ចឹមកូនមាន់ :

កូនមាន់មានលក្ខណៈសំខាន់ពីរយ៉ាងដែលយើងត្រូវយល់ដឹងគឺ ទីមួយនៅពេលដែលវាទើបនិងញាស់ចេញមកវាត្រូវជួបប្រទះនឹងមជ្ឈដ្ឋានខាងក្រៅដែលមានសីតុណ្ហភាពខុសគ្នានិងសីតុណ្ហភាព ដែលមាននៅក្នុងម៉ាស៊ីនភ្ញាស់ ដូច្នេះយើងត្រូវរៀបចំនិងធ្វើយ៉ាងណាដើម្បីអោយមានសីតុណ្ហភាព ប្រហាក់ប្រហែលគ្នារីក៏ស្មើគ្នា ។ ទីពីរគឺការកើនឡើងទំងន់យ៉ាងឆាប់រហ័សរបស់កូនមាន់ វាអាយុបានមួយខែអាចកើនទំងន់រហូតទៅដល់១០ដង និងអាយុបានពីរខែគឺកើនឡើងពី(នៅពេល ១៥-២០ដងធៀបទៅនឹងទំងន់របស់វាដែលទើបនឹងញាស់ ) ។

**ក/ទ្រូងសម្រាប់ចិញ្ចឹមកូនមាន់:**ទ្រុងសំរាប់កូនមាន់ជាទូទៅកូនមាន់ជាទូទៅត្រូវរៀបចំអោយបានល្អជាងទ្រុងមាន់ធំព្រោះកូនមាន់នៅមានសុខភាពខ្សោយត្រូវទាមទារអោយមានការថែទាំល្អអនាម័យល្អនិងត្រូវរក្សាកំដៅអោយបានគ្រាន់ ។

**តម្រូវការចាំបាច់នៅ នៅក្នុងទ្រុងកូនមាន់គឺ :**

- ❑ ទ្រុងត្រូវរៀបចំអោយស្អាតល្អ-មានពន្លឺចេញចូលគ្រប់គ្រាន់-មានភាពងាយ រាយស្រួលក្នុងការធ្វើអនាម័យ។
- ❑ ត្រូវរក្សាសីតុណ្ហភាពនៅក្នុងទ្រុងអោយបានសមស្រប កុំអោយមានការបក់ត្រជាក់ខ្លាំងពេក ។
- ❑ ត្រូវមានជញ្ជាំងកំពស់ពី១,២០-១.៨០ម គឺដើម្បីរក្សាកំដៅក្នុងទ្រុងនិងអាចការពារកុំអោយខ្យល់បក់នៅក្នុងទ្រុងខ្លាំង ព្រមទាំងអាចការពារទប់ទល់នឹងសត្វចង្រៃមួយចំនួនទៀតផង ។
- ❑ ទ្រុងកូនមាន់ត្រូវខ័ណ្ឌជាបន្ទប់ដែលមានរាងជារង្វង់ ហើយចំនួនកូនត្រូវដាក់អោយបាន សមស្របទៅតាមក្រឡាផ្ទៃនៃទ្រូង គឺសំរាប់កូនមាន់១០០ក្បាលដែលមានអាយុ១ថ្ងៃរហូតដល់៣០ថ្ងៃត្រូវការក្រឡាផ្ទៃពី ១.៨០-២ ម៉ែត្រក្រឡា ។

## ខ/ សីតុណ្ហភាព :

សីតុណ្ហភាពនៅប្រទេសកម្ពុជាយើងគឺអាចប្រែប្រួលឆាប់រហ័សណាស់រវាងពេលថ្ងៃនិងពេលយប់ដូច្នេះនៅក្នុងកន្លែងចិញ្ចឹមត្រូវតែមានទែម៉ូម៉ែត្រសម្រាប់វាស់កម្ដៅ និងត្រួតពិនិត្យមើលវារៀងរាល់ពេលថ្ងៃនិងពេលល្ងាច ។ ចំពោះការត្រួតពិនិត្យកំដៅគឺជាការចាំបាច់បំផុត ប្រសិនបើយើងពុំបានត្រួតពិនិត្យអោយហ្មត់ចត់ទេនោះ វាអាចបណ្ដាលអោយកូនមាន់ស្លាប់បានយ៉ាងងាយជាទីផុត។

**យើងអាចធ្វើការកត់សំគាល់បានខ្លះៗ នូវលក្ខលរបស់កូនមាន់៖**

- ❑ នៅពេលសីតុណ្ហភាពឡើងខ្ពស់ខ្លាំងកូនមាន់ត្រដាងស្លាបបើកចំពុះនៅឆ្ងាយពីប្រភពកំដៅ ស៊ីចំណីអាហារតិចប៉ុន្តែផឹកទឹកច្រើន ដែលជាហេតុនាំឲ្យកំរាលម្យ៉ាងទៀតកូនមាន់ជ្រុះស្លាបច្រើនទៀតផង ។
- ❑ នៅពេលសីតុណ្ហភាពចុះទាបខ្លាំង : កូនមាន់នៅផ្តុំជិតៗគ្នា ថយចុះកម្មភាព វាលើកស្លាបគ្រប ហើយវានៅជិតប្រភពកំដៅ ។
- ❑ នៅពេលសីតុណ្ហភាពក្តៅល្មម : កូនមាន់ស៊ីចំណីនិងផឹកទឹកធម្មតា) ហើយវាមិននៅផ្តុំគ្នាឬនៅ ឆ្ងាយពីប្រភពកំដៅឡើយ ហើយម្យ៉ាងទៀតវាមានសកម្មភាពរហ័សរហួនទៀតផង ។

| អាយុ | សីតុណ្ហភាព |
|---|---|
| ១ ថ្ងៃ | ៣៣-៣៥ |
| ២ ថ្ងៃ | ៣២ |
| ១ អាទិត្យ | ៣០ |
| ២ អាទិត្យ | ៣០- ២៨ |
| ៣ អាទិត្យ | ២៨- ២៥ |
| ៤ អាទិត្យ | ២៥- ២២ |

តាមរយៈនៃការទទួលកំដៅយើងអាចសង្កេតឃើញនូវឥរិយាបទរបស់កូនមាន់ដូចខាងក្រោមៈ

- ❑ នៅពេលសីតុណ្ហភាពទាបជាងតម្រូវការរបស់កូនមាន់ ពេលនោះប្រមូលផ្តុំគ្នានៅក្រោមកន្លែងប្រភពកម្តៅ។
- ❑ នៅពេលសីតុណ្ហភាពខ្ពស់ជាងតំរូវការរបស់កូនមាន់ពេលនោះវាគេចចេញទៅឆ្ងាយពីប្រភពកំដៅ ។
- ❑ នៅពេលសីតុណ្ហភាពសមស្រប់ ពេលនោះកូនមាន់មានសកម្មភាពរស់រវើក ហើយវាពង្រាយគ្នាគ្រប់ កន្លែង ។






ដើម្បីសំរួលសីតុណ្ហភាពអោយបានសមស្របសំរាប់កូនមាន់ យើងត្រូវលើកអំពូលកំដៅអោយនៅពេលសីតុណ្ហភាពក្តៅខ្លាំង ហើយត្រូវទំលាក់អំពូលអោយទាបនៅពេលសីតុណ្ហភាពចុះទាប ។

**គ / ប្រភពកំដៅៈ** កូនមាន់ដែលមានអាយុក្រោមមួយថ្ងៃវាគ្មានកំដៅនៅក្នុងខ្លួនទេ ដូច្នេះហើយត្រូវ ទាមទារនូវកំដៅគ្រប់គ្រាន់ដើម្បីទប់ស្កាត់នូវបរិយាកាសខាងក្រៅ ។ប្រភពនៃការផ្តល់កំដៅនេះគឺប្រើ អំពូលដែលជាលទ្ធភាពមួយងាយបំផុត ។ប្រភពកំដៅនេះត្រូវតែសមស្របទៅនឹងបរិមាណកូនមាន់ នៅក្នុងកន្លែងចិញ្ចឹម គឺបរិមាណកូនមាន់ចំនួន៣០០ក្បាលយើងត្រូវដាក់អំពូលអគ្គិសនីចំនួនបី ដែល អំពូលនិមួយៗមានអានុភាព១០០វ៉ាត់ ។

- ការផ្តល់កំដៅអោយកូនមាន់ប្រសិនជានៅតំបន់ដែលមានអគ្គិសនី យើងត្រូវប្រើអំពូលដែលមានអា នុភាពដូចជា ១០០វ៉ាត់, ៧៥វ៉ាត់ និង៤០វ៉ាត់ ។
- អំពូល១០០វ៉ាត់ អាចផ្តល់កំដៅអោយកូនមាន់បានចំនួន១០០ក្បាល ។
- អំពូល៧០វ៉ាត់អាចផ្តល់កំដៅអោយកូនមាន់បានចំនួន ៧០ក្បាល ។

❑ អំពូល៤០វ៉ាត់អាចផ្តល់កំដៅអោយកូនមាន់បានចំនួន៥០ក្បាល ។

**ឃ/ អំពីពន្លឺ:** មានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យកូនមាន់ស៊ីចំណី ការលូតលាស់ ការពងរបស់វាមាន់ដែលចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម។ ពន្លឺគឺជាកត្តាកំណត់សម្រាប់បែងចែងពេលស៊ី និងពេលសម្រាកធម្មជាតិក្នុងមួយថ្ងៃ។ នៅពេលដែលយើងចាំងពន្លឺក្នុងរយៈពេលយូរ ពេលនោះមាន់ក៏ស៊ីចំណីយូរដែរ។នៅក្នុងអាទិត្យទី១ យើងត្រូវបញ្ចាំងពន្លឺអោយបាន២៤ម៉ោងក្នុងមួយថ្ងៃ។ លុះចាប់ពីអាទិត្យទី២-៤ត្រូវបន្ថយបន្តិចម្តងៗ គឺពី២៣-២០-១៤ម៉ោងក្នុងមួយថ្ងៃ។ ចាប់ពីអាទិត្យទី៥ និងទី១៧ គឺយើងពុំចាំបាច់ផ្តល់ពន្លឺ ធ្វើអោយវាទៀតទេ។

នៅក្នុងកន្លែងផ្តល់កំដៅកូនមាន់ យើងត្រូវរៀបចំអោយមានកន្លែងក្តៅ និងកន្លែងក្រោមអំពូលត្រូវមានសីតុណ្ហភាពពី ៣៣-៣៥អង្សាសេ រីឯជ្រុងម្ខាងគឺទាបជាងពី៥-៦អង្សាសេនៃសីតុណ្ហភាពនៅក្រោមអំពូលយើងត្រូវរៀបចំធ្វើដូច្នេះគឺដើម្បីអោយកូនមាន់មានលក្ខណៈបន្សាំជាបណ្តើរៗជាមួយនិងមជ្ឈដ្ឋានខាងក្រៅ ។

**ង/ អំពីខ្យល់អាកាសៈ** សេចក្តីត្រូវការអុកស៊ីហ្សែនរបស់មាន់មានកំរិតខ្ពស់ជាង គឺប្រហែលជាពីរដងនៃសេចក្តីត្រូវការរបស់សត្វដែលចិញ្ចឹមកូនដោយទឹកដោះ ។ ដូច្នេះបើសិនជាខ្វះអុកស៊ីហ្សែនអាចបណ្តាលឲ្យកូនមាន់ងាប់យ៉ាងងាយហើយត្រូវលៃធ្វើយ៉ាងណាកុំអោយខ្យល់ជះចំខ្លាំងទៅប៉ះនឹងកូនមាន់។ក្នុងករណីនេះដើម្បី
ជៀសវាងការស្លាប់នៃកូនមាន់គេអាចប្រើកង្ហាបឺតខ្យល់ចេញនិងបញ្ចូលខ្យល់រឺធ្វើជារន្ធខ្យល់នេះបង្អួតដើម្បីអោយខ្យល់ចេញចូលបានល្អ ដើម្បីនាំយកអុកស៊ីហ្សែនចូលក្នុងស៊ុលផូរីចេញទៅខាងក្រៅ ។

**ច/ ផ្ទៃក្រឡាៈ** នៃការចិញ្ចឹម ( ដងស៊ីតេ) ផ្ទៃក្រឡានៃការចិញ្ចឹមក៏ជាកត្តាមួយដែលជំរុញឲ្យយើងទទួលបានលទ្ធផលល្អក្នុងការចិញ្ចឹមដែរ ។ ចំនួនកូនមាន់ត្រូវសមស្របទៅនឹងផ្ទៃកន្លែងប្រសិនបើយើងដាក់កូនមាន់លើសបរិមាណកំណត់នោះនឹងអាចមានផលវិបាកដូចជាៈ កូនមាន់ជាន់លើគ្នាថយចុះនូវភាពធន់មានការធំធាត់កើតនិងចឹកគ្នាទៀតផង ។ ទាំងអស់នេះអាចបង្កលក្ខណៈងាយស្រួលដល់ការកកើតជំងឺមុននឹងមាន់ចូលក្នុងកន្លែងចិញ្ចឹម គួរតែគិតគូរអំពីបរិមាណនៃកូនមាន់ឲ្យបានសមស្របទៅនិងពន្លឺ។លក្ខខ័ណ្ឌនៅក្នុងកន្លែងចិញ្ចឹមតូច ដើម្បីអោយបរិមាណ

កូនមាន់សមស្របនេះសំរាប់កូនមាន់មួយក្បាលត្រូវការផ្ទៃកន្លែងពី ៤៥-៦៥ សង់ទីម៉ែត្រក្រឡា។

- ការចិញ្ចឹមកូនមាន់នៅលើទ្រនើគឺ ៥០ក្បាលក្នុងមួយម៉ែត្រក្រឡា(គឺអាយុចាប់ពី ០–២ អាទិត្យ )
- ការចិញ្ចឹមកូនមាន់លើកំរាលគឺ ៣០ក្បាល ក្នុងមួយម៉ែត្រក្រឡា ( គឺអាយុចាប់ពី ០–២ អាទិត្យ ) ការចិញ្ចឹមនៅលើកំរាល កូនមាន់អាចដាក់បានច្រើនបំផុតពី ២០-៣០ក្បាល ក្នុងមួយម៉ែត្រក្រឡា រហូតដល់ពេលអាយុពី ១-៤អាទិត្យ គឺនៅពេលដែលពុំទាន់បំបែកឈ្មោលនិងញីចេញពីគ្នា ។នៅក្រោ យពេលដែលយើងបំបែកញីនិងឈ្មោល (គឺអាយុពី៤-៦អាទិត្យ) យើងអាចចិញ្ចឹមបានពី ១២-១៥ ក្បាលក្នុងមួយម៉ែត្រក្រឡា។

ការចិញ្ចឹមកូនមាន់ជាលើកដំបូងយើងត្រូវបំបែកជាក្រុមតូចៗសិន គឺក្នុងអាទិត្យដំបូងយើងអាច ដាក់វាពី៥០-២០០ក្បាលក្នុងមួយក្រុម ។ក្នុងករណីដែលទ្រុងពុំទាន់បានចែកជាឡូតូចៗ យើងអាចប្រើ ក្រដាសរឹងខ័ណ្ឌជាឡូតូចៗ ។

លុះដល់ពេលវាអាយុបានប្រហែលពី ៣-៤ អាទិត្យទើបយើងបញ្ចូលវាជាហ្វូងធំ ។

### ឆ/អំពីស្នូកទឹក និងស្នូកចំណី :

- អំពីស្នូកទឹកៈគេអាចធ្វើស្នូកទឹកបានច្រើនរបៀបណាស់ ប៉ុន្តែស្នូកទឹកដែលល្អសំរាប់គឺរៀបចំ ធ្វើដូចតទៅ : គឺគេចោះរន្ធតូចៗនៅសងខាងកំប៉ុងគឺប្រហែលបីភាគបួននៃគែមមាត់កំប៉ុង (ចំងាយ នេះក៏អាស្រ័យលើកំពស់នៃថាសទំរ ) ។ បន្ទាប់មកគេដាក់ទឹកក្នុងកំប៉ុងនោះ ៖ និងដាក់ថាសគ្រប បគ្របពីលើ វាអោយជិតហើយផ្កាប់កំប៉ុងនោះចុះក្រោមយ៉ាងឆាប់រហ័ស ពេលនោះទឹកនឹងហូរចេញមកក្នុងថាស តាមរន្ធទាំងពីរនោះរហូតដល់កំពស់ទឹកខ្ពស់ជាងរន្ធចោះបន្តិច ពេលនោះទឹកឈប់ហូរ ។នៅពេលដែល មាន់ផឹកស្រកទឹកនឹងហូរចេញមកបន្តបំពេញក្នុងថាសទៀត ។

ស្នូកទឹកដែលត្រូវផ្តល់អោយកូនមាន់គឺត្រូវផ្តល់ទៅតាមចំនួននិងទៅតាមអាយុរបស់វា បើមិនដូច្នោះទេវានឹងធ្វើអោយមានការខូចខាត ដូចជាការកំពប់ជាដើម ។ ដូច្នេះចំពោះស្លឹកទឹកដែលល្អសម្រាប់កូនមាន់១០០ក្បាលត្រូវមាន :

- ប្រវែង ៥០ស-ម សំរាប់កូនមាន់ដែលមានអាយុ២អាទិត្យដំបូង ។

❑ ប្រវែង១០០-១៥០សម សំរាប់កូនមាន់ដែលមានអាយុពី៣-១០អាទិត្យ ។

ចំពោះកូនមាន់ដែលទើបញាស់ភ្លាមយើងត្រូវបង្រៀនអោយវាចេះផឹកទឹកសិនគឺ :

❑ យើងត្រូវអោយទឹកស្អាតវាផឹក គឺក្រោយរយៈពេល១២ម៉ោងបន្ទាប់ពីញាស់ភ្លាម ។

❑ យើងត្រូវអោយទឹកអេឡិចត្រូលីត្រវាផឹកក្រោយពេលញាស់បានរយៈពេល៤៨ម៉ោង ។

❑ អំពីស្នូកចំណី យើងត្រូវរៀបចំដាក់ចំនួនស្នូកចំណីអោយបានគ្រប់គ្រាន់ ដែលកូនមាន់អាចស៊ីចំ ណីបានគ្រប់ៗគ្នានៅក្នុងពេលតែមួយ ។ចំនួនស្នូកចំណីនិងទំហំរបស់វាអាចប្រែប្រួលទៅតាមអាយុរប សំមាន់ដែរ គឺស្នូកប្រវែង៣ស.មសំរាប់កូនមាន់ដែលមានអាយុ១ថ្ងៃនិងប្រវែង៦ស.មសំរាប់កូនមាន់ អាយុ ៨អាទិត្យ ។ ចំណីដែលផ្តល់អោយកូនមាន់ត្រូវមានទំរង់ជាម្សៅម៉ត់ ហើយចំណីនេះត្រូវ ដាក់ ត្រឹមកំណត់តែ ១/៣នៃមាឌរបស់ស្នូក ព្រោះនៅពេលដែលយើងដាក់ចំណីច្រើនពេកបណ្តាលអោយ កំពប់ដែលនាំឱ្យ មានការខ្ជះខ្ជាយចំណី ។

ម៉្យាងទៀតចំណីគួរដាក់នៅក្នុងថាសដែលមានតែមរាក់ៗចំពោះកូនមាន់ដែលមានអាយុ១ថ្ងៃហើយ ថ្ងៃក្រោយមកទៀតត្រូវដាក់ចំណីទៅក្នុងស្នូកចំណីជាធម្មតាវិញ។ យើងត្រូវធ្វើរបៀបនេះអាចជំរុញ អោយកូនមាន់ស៊ីចំណីបានច្រើន។

**តម្រូវការស្នូកទឹកនិងស្នូកចំណីដែលសមស្របសម្រាប់កូនមាន់**

| ចំនួនកូនមាន់ | ស្នូកទឹក | ស្នូកចំណី |
|---|---|---|
| ៥០ក្បាល | ២-៣ | ២-៣ |
| ៥០-១០០ក្បាល | ៣-៤ | ៣-៤ |
| ១០០-២០០ក្បាល | ៤-៥ | ៤-៥ |

**ជ/ការកាត់ចំពុះ** គេធ្វើការកាត់ចំពុះកូនមាន់នៅពេលវាមានអាយុពី៦-៨អាទិត្យព្រោះវាងាយស្រួលក្នុងការទាប់កាន់និងមានស្រ្តេសតិចតួច ។ការកាត់ចំពុះនេះគឺធ្វើឡើងដើម្បីបន្ថយនូវការបើកគ្នា និងការខ្ជះខ្ជាយចំណី ហើយការកាត់នេះគឺមិនត្រូវអោយហួសពី១/៣នៃចុងចំពុះទេ ហើយមិនត្រូវឱ្យ មាន់ស៊ីចំណីរយៈពេល៤ម៉ោងមុនពេលកាត់ចំពុះគឺដើម្បីជៀសវាងនៅពេលដែលយើងកាត់ហើយមមានការហូរឈាមច្រើន។

ការកាត់ចំពុះត្រូវទាមទារនូវវិធានការមួយចំនួនគឺ :

- នៅមុនពេលកាត់ -ត្រូវធានានូវហ្វូងមាន់អោយមានសុខភាពល្អ
- អោយកូនមាន់ស៊ីចំណីតិចតួច ព្រោះលីតែទទេអាចមានស្រួលតិចត្រូវ
- មិនត្រូវចាក់វ៉ាក់សាំងមុនពេលកាត់ចំពុះ
- ត្រូវរៀបចំអោយបានល្អរវាងមាន់ដែលបានកាត់ចំពុះរួចហើយនិងមាន់មិន
- ទាន់កាត់ចំពុះ ។
- ត្រូវមានកាំបិតមុត ហើយធ្វើការកាត់ចំពុះនៅក្នុងទ្រុងរឺនៅក្បែរទ្រូង។
- ត្រូវផ្តល់វិតាមីន K

ក្រោយពេលកាត់-មិនត្រូវផ្តល់ចំណីអោយវាស៊ីបន្ទាប់ពីកាត់ចំពុះភ្លាម ព្រោះចំពូរមានការលើចាប់ច្រើនថ្ងៃ ។

- ត្រួតពិនិត្យការផឹកទឹកអោយបានម៉ត់ចត់
- ត្រូវបន្ថែមវិតាមីននិងអង់ទីប៊ីយូទិចខ្លះទៅក្នុងចំណីក្នុងរយៈពេល១អាទិត្យ( វីតាមីនទាំងនោះមាន វីតាមីនអា បេកំផ្លេច និង K ) ។
- ត្រូវផ្តល់ពន្លឺបន្ថែមដើម្បីអោយមាន់ស៊ីចំនីបានយូរ ដែលអាចជួយដល់សុខភាពរបស់វាបាន ។

ត្រូវជ្រលក់ចំពុះបក្សីដែលមានឈាមហូរចូលទៅក្នុងចំណីអាហារ

ការកាត់ចំពុះគឺគេកាត់ប្រហែល ១/៣នៃខាងចុងចំពុះចេញចំពោះកូនមាន់ផ្តល់សាច់ ចំណែកមាន់ ផ្តល់ស៊ុតវិញគឺត្រូវកាត់១/៣ទៅ២/៣ នៃចំពុះខាងលើនិង១/៤ទៅ១/៣នៃចំពុះខាងក្រោម ព្រោះ វារស់រយៈពេលយូរ ។

ម៉្យាងទៀតផលប្រយោជន៍នៃការកាត់ចំពុននេះចំពោះមាន់ពង វាអាចបន្ថយនូវការស៊ីពងបានមួយចំនួនទៀតផង ។

## ២.របៀបចិញ្ចឹមកូនមាន់:

- ការអនុវត្តក្នុងការចិញ្ចឹមកូនមាន់មានចីររបៀបគឺ :
- ការចិញ្ចឹមលើកំរាល

- ❑ ការចិញ្ចឹមលើទ្រនើ
- ❑ ការចិញ្ចឹមលើទ្រនើផងនិងលើកំរាលផង។

**ក/ការចិញ្ចឹមលើកំរាល :**

ការចិញ្ចឹមរបៀបនេះត្រូវបានគេអនុវត្តច្រើនក្នុងការចិញ្ចឹមកូនមាន់ ក៏ប៉ុន្តែកូនមាន់ត្រូវមានអាយុដំណាលគ្នា បើសិនជាអាយុខុសគ្នាវាងាយនឹងកើតជំងឺតាមផ្លូវដង្ហើមនិងផ្លូវះអាហារសត្វធាតុដែលសម្រាប់យកទៅធ្វើជាកំរាលនោះមាន : សំបកបាវ អង្កាម ចំបើង អាចម៍រណាផ្សងកម្តៅលាមកសត្វ ។ល ។

ការចិញ្ចឹមលើកំរាលគេអនុវត្តតាមពីររបៀបគឺ ការចិញ្ចឹមលើកំរាលផ្លាស់ប្តូរនិងមិនផ្លាស់ប្តូរះ

- ❑ ការចិញ្ចឹមលើកំរាលផ្លាស់ប្តូរ ការចិញ្ចឹមរបៀបនេះត្រូវបានគេអនុវត្តជាច្រើនគឺការប្រើកំរាលកំរាស់ ៥ស.ម ហើយត្រូវការផ្លាស់ប្តូរជាញឹកញាប់ ជូនកាលមួយដងរឺក៏ពីរដងក្នុងមួយសប្តាហ៍ ការអនុវត្ត របៀបនេះទោះបីជាមានអនាម័យស្អាតក៏ដោយ ក៏នៅតែផ្តល់នូវគុណវិបត្តិខ្លះៗដែលគឺជាការរក្សាកម្តៅ មិនធានានិងការចំណាយវត្ថុធាតុក៏ច្រើន ការប្រើកំលាំងពលកម្មក៏ច្រើន។

ការចិញ្ចឹមលើកំរាលមិនផ្លាស់ប្តូរៈការចិញ្ចឹមរបៀបនេះគឺធ្វើឡើងដើម្បីសន្សំសំចៃកម្លាំងពលកម្មវត្ថុធាតុកំរាលនិងថវិកាចំណាយ ការចិញ្ចឹមរបៀបនេះកំរាលត្រូវមានកំរាស់២០-៣០ស.មគឺដើម្បីរក្សាកំដៅកូនមាន់បានល្អ ។ម៉្យាងទៀតការចិញ្ចឹមរបៀបនេះមានលក្ខណៈសមស្របជាមួយតំបន់ដែលមានសីតុណ្ហភាពទាប តែបើតំបន់ដែលមានសីតុណ្ហភាពខ្ពស់វាអាចធ្វើឲ្យកើនកម្តៅនៅក្នុងខ្លួនសត្វ។

**ខ/ ការចិញ្ចឹមនៅលើទ្រនើ**





**ការចិញ្ចឹមរបៀបនេះគឺមានផលប្រយោជន៍មួយចំនួនគឺ :**

- ការប្រើប្រាស់ក្រឡាផ្ទៃទ្រុងអស់តិច តែយើងអាចចិញ្ចឹមបានចំនួនច្រើន
- ការរក្សាកំដៅកូនមាន់គឺបានល្អមិនធ្វើអោយមានការថប់ដង្ហើម
- មានលក្ខណៈងាយស្រួលក្នុងការសំអាតលាមក
- អាចជៀសវាង នូវជំងឺឆ្លងផ្សេងៗបានល្អ
- យើងអាចចិញ្ចឹមកូនមាន់ទៅតាមអាយុផ្សេងៗពីគ្នា
- យើងអាចធ្វើការតាមដាននូវសុខភាពរបស់មាន់ ល្អជាងការចិញ្ចឹមនៅលើកំរាល។

**ទន្ទឹមនឹងផលប្រយោជន៍ខាងលើវាក៏ផ្តល់នូវផលវិបាកមួយចំនួនដែរគឺៈ**

- ត្រូវចំណាយអស់ថវិកាច្រើន (សំភារៈ កំលាំងពលកម្ម )
- ត្រូវប្រើប្រាស់អគ្គិសនីអស់ច្រើន ដើម្បីរក្សាកំដៅអោយបានល្អ
- ត្រូវទាមទារនូវលក្ខណៈបច្ចេកទេសអោយបានគ្រប់គ្រាន់ ដើម្បីអោយខ្យល់អាកាសចេញចូលបាន ល្អ។

**ចំពោះទ្រុងសំរាប់ចិញ្ចឹមកូនមាន់នៅលើច្រនីគឺមានពីរយ៉ាង :**

១/ ទ្រុងសំរាប់កូនមាន់អាយុពី១-៣អាទិត្យ

- ក្រឡាសំណាញ់១,៥ម.ម និងទំហំទ្រូង១.២ម x២.៥ម
- កំពស់ពីដី 0,៦ - 0.៨ម
- ស្នូកទឹកនិងស្នូកចំណីត្រូវដាក់ខាងក្នុងទ្រុង
- ការផ្តល់ចំណីគឺ២៤ម៉ោង

២/ ទ្រូងសំរាប់កូនមាន់អាយុពី ៣-៨ អាទិត្យ

- ក្រឡាសំណាញ់ ២0-២៥មមនិងទំហំទ្រូង ១.៨ម x ២.៥ម
- កំពស់ពីដី 0,៨-១ម
- ស្នូកទឹកនិងស្នូកចំណីត្រូវដាក់ខាងក្រៅទ្រុង
- ត្រូវបន្ថយរយៈពេលអោយស៊ីក្នុងមួយថ្ងៃបន្តិចម្តងៗរហូតអោយវាស៊ីតែពេលថ្ងៃ ។
- គ/ការចិញ្ចឹមនៅទ្រនើផងនិងលើកំរាលផងៈ

- ការចិញ្ចឹមរបៀបនេះមុនដំបូងគឺគេចិញ្ចឹមនៅលើទ្រនើ រហូតដល់ពេលវាអាយុបានប្រហែលបីអា ទិត្យទើបគេដាក់វាចុះមកចិញ្ចឹមនៅលើកំរាលវិញម្តង។

**៣.ការជ្រើសរើសកូនមាន់និងរបៀបដឹកជញ្ជូន :**

- ការជ្រើសរើសខ្នាតគំរូរបស់កូនមាន់សំរាប់យកមកចិញ្ចឹម គឺពុំមែនស្ថិតតែនៅក្នុងកិច្ចការចិញ្ចឹមថែ រក្សាដ៏ល្អនោះទេ គឺរួមទាំងស្ថានភាពសុខភាពរបស់ហ្វូងពូជតាំងពីកំណើតទៀតផង ។

ដូច្នេះដើម្បីចិញ្ចឹមអោយមានលក្ខណៈល្អប្រសើរ យើងត្រូវជ្រើសរើសយកកូនមាន់ ពីបណ្តាកន្លែង ភ្ញាស់ដែលពូជមានលក្ខណៈល្អនិងពូជដែលគេបានកំណត់។ ជាពិសេសយើត្រូវជំរុះចោលចំពោះ៖ កូន មាន់ ដែលមានលក្ខណះខ្សោយខុសពីធម្មតា ដូចជាខ្វាក់,ខ្វិន, ដំណើរពុំត្រង់ និងមានមាឧតូចខុសគេ ។ល។

ក/របៀបជ្រើសរើសកូនមាន់ :

យើងត្រូវជ្រើសរើសយកកូនមាន់ដែលមានលក្ខណៈដូចតទៅៈ :

- ចំពោះពូជស្រាល នៅពេលវាអាយុបាន១ថ្ងៃទំងន់របស់វាគឺ ៣៥-៣៨ក្រ
- ចំពោះពូជធ្ងន់ នៅពេលវាអាយុបាន១ថ្ងៃទំងន់របស់វាគឺ ៣៨ - ៤២ក្រ
- រោមស្ងួតហើយត្រសុស និងមិនមានជាប់សំបកទៅនឹងរោម
- រោមគ្របដណ្តប់ជិត ទៅនឹងខ្លួន
- មានកែវភ្នែកភ្លឺថ្លានិងសកម្មភាពរហ័សរហួន
- ចំពុះលើនិងក្រោមបិទជិត
- មានក្បាលតូចល្មមនិងកវែង
- ជើងរបស់វាមូលស្មើល្អ និងដំណើរត្រង់។
- ខ/របៀបដឹកជញ្ជូនកូនមាន់ :

- ❑ នៅក្នុងកន្លែងចិញ្ចឹមដែលគ្មានម៉ាស៊ីនភ្ញាស់ គឺគេត្រូវទិញកូនមាន់ពីកន្លែងផ្សេងដើម្បីយកមកចិញ្ចឹម ដូច្នេះការដឹកជញ្ជូនត្រូវមានបញ្ហាចោទឡើង។ សំភារៈសំរាប់ដឹកជញ្ជូនត្រូវធ្វើឡើងដើម្បីការពារ នឹងបរិយាកាសខាងក្រៅ ។ យើងត្រូវធ្វើទ្រុងនិងកេសក្រដាសសំរាប់ដឹកជញ្ជូនកូនមាន់ ដើម្បីអោយមានការងាយស្រួល ។
- ❑ មុននឹងដាក់កូនមាន់ចូលទៅក្នុងទ្រុង រឺក្នុងឡាំងដឹកជញ្ជូន យើងត្រូវដាក់ក្រដាសរឹង ក្រាលឬដាក់ រាលជាមុនសិន គឺក្នុងមួយបន្ទប់ត្រូវដាក់កូនមាន់ពី២៥០ក្បាលដើម្បីងាយស្រួលក្នុងការដឹកជញ្ជូន ហើយមិនត្រូវដាក់កូនមាន់នៅក្នុងបន្ទប់នោះអោយហួសពី៤ម៉ោងទេ។ ចំណែកការដឹកជញ្ជូនត្រូវធ្វើ ត្រូវធ្វើឡើងនៅពេលព្រឹក និងពេលល្ងាចគឺដើម្បីបន្ថយនូវការស្លាប់របស់កូនមាន់ ។

## ៤. ការបញ្ចូលកូនមាន់ទៅក្នុងទ្រុង :

មុននឹងបញ្ចូលកូនមាន់ចូលទៅក្នុងទ្រុង យើងត្រូវរៀបចំតាមលក្ខណៈបច្ចេកទេសដូចខាងក្រោម :

- ❑ ត្រូវកំដៅកំរាលចោលមុនក្នុងរយៈពេល២៤ម៉ោង
- ❑ ជំរះស្មៅជុំវិញទ្រុងចំងាយ២ម៉ែត្រ
- ❑ ត្រូវបោសសំអាតខាងក្នុងនិងខាងក្រៅទ្រុង
- ❑ ត្រូវរៀបចំបណ្តាញភ្លើងក្នុងទ្រុង -ត្រូវ
- ❑ ត្រូវ ត្រូវបាញ់ហ្វ័រម៉ុល (Formol ) ២%លាយជាមួយទឹក រឺទឹកក្រេស៊ីល (Crezyle)២% ទៅលើផ្ទៃចិញ្ចឹមជុំវិញទ្រុង ជញ្ជាំង និងដំបូលទ្រុង ។
- ❑ ត្រូវក្រាលអង្កាមរឺកំទេចអាចម៍រណាអោយបានកំរាស់ពី១០-១៥ស.ម
- ❑ ត្រូវលាបទឹកកំបោរជុំវិញទ្រុងនិងជញ្ជាំងទ្រុង
- ❑ ត្រូវរៀបចំដាក់របាំងជុំវិញបរិវេណទ្រុងដើម្បីការពារភ្លៀង ខ្យល់ និងអាកាសធាតុត្រជាក់
- ❑ ត្រូវបាញ់ហ្វ័រម៉ុល និងក្រេស៊ីលសារជាថ្មីឡើងវិញ

- ត្រូវដាក់ស្នូកទឹក រឺក៏ធ្វើជាអាងសំរាប់រំងាប់មេរោគ ដោយប្រើកំបោរសដាក់នៅតាមផ្លូវចេញចូលក្នុងទ្រុង និងតាមផ្លូវចេញចូលក្នុងកន្លែងចិញ្ចឹមទាំងមូល ហើយត្រូវធ្វើការផ្លាស់ប្តូរជាប្រចាំ ។
- ត្រូវឧស្សាហ៍ដុសលាងស្នូកចំណី និងលូកទឹក ហើយក្រោយមកទើបលាងជាមួយនឹង សូលុយស្យុងពែម៉ង់កាណាត (KMnO4)០,៣% ដោយរក្សាទុកអោយបានស្ងួតល្អ ។
- ត្រូវឧស្សាហ៍ផ្លាស់កំរាល។

**៥.ការផ្តល់ចំណី :**

- ដើម្បីអោយកូនមាន់មួយក្បាល រស់ដល់អាយុ៨អាទិត្យ គេត្រូវការចំណាយ ចំណីផ្សំស្រេចអស់ប្រហែលជាង ២Kg ។ នៅក្នុងចំណីនោះ ត្រូវមានប្រូតេអ៊ីន ២២% . P: ០.៦% និង គ្រាប់ធញ្ញជាតិ៥០% ។ នៅក្នុងនោះត្រូវមានវិតាមីនបន្ថែម,សារធាតុ Cellulose >៣% និង ពពួកអង់ទីប៊ីយូទិច(Antibiotique) ។
- រូបមន្តនៃការលាយចំណីសំរាប់កូនមាន់អាយុ១ថ្ងៃ-១៣អាទិត្យ (១០០ Kg )

| ល.រ | វត្ថុធាតុដើម | (Kg) |
|---|---|---|
| ១ | ពោតក្រហម | ៣០ |
| ២ | ចុងអង្ករ | ១០ |
| ៣ | កន្ទក់លេខ១ | ២០ |
| ៤ | សណ្តែកសៀង | ១៨ |
| ៥ | ម្សៅត្រី | ២០ |
| ៦ | អំបិល | ០.៥០ |
| ៧ | សំបកគ្រែង | ១ |

នៅក្នុងនោះមាន :

- ប្រូតេអ៊ីន ១៨%
- កាលស្យូម ១-១.១%
- ផូស្វ័រ 0.៤៨%
- ថាមពលបំលែង ២៨00 Kcal/Kg

ចំណីដែលល្អសំរាប់កូនមាន់ត្រូវផ្សំឡើងដោយចំណីត្រឹមត្រូវ និងពោរពេញទៅដោយជាតិរ៉ែដែលសារពាង្គកាយត្រូវការ ម៉្យាងទៀតចំណីទាំងនោះមិនត្រូវផ្ទុមរលួយ រឺដុះផ្សិត ។ ដើម្បីអោយកូនមាន់ធំធាត់ស្មើគ្នាត្រូវរៀបចំស្នូកចំណី និងស្នូកទឹកអោយវាស៊ី និងផឹកអោយ បានគ្រប់ៗក្បាល ។ថ្ងៃដំបូងត្រូវប្រើស្នូកសំប៉ែត, ថាសរឺក៏ប្រើជាក្រដាសរឹងសំរាប់ដាក់ចំណីអោយវាស៊ី ។លុះដល់ពេលវាចេះចឹកចំណីស៊ីយើងត្រូវប្តូរស្នូករាងវែងដាក់អោយវាស៊ីវិញ ។ការផ្តល់ចំណីគឺអោ គឺត្រូវដាក់១/២រឺ ១/៣នៃស្នូក ។ចំណែកស្លឹកទឹកយើងអាចប្រើស្នូករាងសាជីសំរាប់ដាក់ទឹកអោយវា ផឹក។

## ៦. ការធ្វើអនាម័យនិងការចាក់ថ្នាំការពារ:

ក/ការធ្វើអនាម័យនិងថែរក្សា: នៅកន្លែងចិញ្ចឹមកូនមាន់ត្រូវតែស្អាត នឹងត្រូវរំងាប់មេរោគដោយប្រើស្នូលុយស្បុងហ្វ័រម៉ុល (Formol) មុនពេលដែលបញ្ចូលកូនមាន់ ប៉ុន្តែមិនត្រូវប្រើច្រើនពេ កទេ ។ការបញ្ចូលកូនមាន់មកពេលត្រជាក់ រឺ ពេលក្តៅពេកយើងត្រូវឧស្សាហ៍តាមដាននិងត្រួតពិនិត្យ សីតុណ្ហភាពនៅក្នុងទ្រុង ។ត្រូវជំរុះចោលនូវកូនមាន់ដែលមានសុខភាពមិនល្អចេញពីហ្វូង និងត្រូវបិទបាំងទ្រុងអោយ បានត្រឹមត្រូវនិងជិតល្អ ជៀសវាងភ្លៀងសាចចូលនិងការពារធាតុអាកាសត្រជាក់ ។ត្រូវការពារកុំឱ្យ បក្សីផ្សេងៗចូលធ្វើសំបុកពងក្នុងទ្រុង និងត្រូវកាត់ចំពុះកូនមាន់នៅពេលវាមានអាយុ២អាទិត្យដើម្បី ជៀសវាងការចឹកគ្នានិងដើម្បីអោយវាស៊ីចំណីបានស្រួល។

រាល់សំភារៈប្រើប្រាស់ទាំងឡាយដូចជាស្លូកទឹក ស្នូកចំណីត្រូវធ្វើការរំងាប់មេរោគទីធ្លានៃកន្លែងចិញ្ចឹមទាំងក្នុង ទាំងក្រៅក៏ត្រូវតែសំអាតហើយធ្វើការរំងាប់មេរោគដែរ គឺដើម្បីទប់ស្កាត់នឹងការយាយីពីសត្វល្អិតចង្រៃ (ចៃស្រមើ ) ។ត្រូវឧស្សាហ៍ប្រមូលលាមកចេញដើម្បីជៀសវាងការចំ

លងមេរោគផ្សេងៗ ហើយលាមកនោះត្រូវយកទៅដាក់គរមួយកន្លែងអោយឆ្ងាយពីទ្រុងនិងផ្ទាប់ដើ ម្បីរំងាប់មេរោគ ។

ដើម្បីទប់ស្កាត់នឹងការរាលដាលនៃជំងឺ យើងគួរតែមានវិធានការមួយចំនួនគឺៈ

- ❑ មិនត្រូវអោយកូនមាន់មានជំងឺចូលកន្លែងចិញ្ចឹម ប្រសិនបើក្នុងហ្វូងមាន់មានកូនមាន់ឈឺយើងត្រូវរហ័សបំបែកវាចេញ។
- ❑ ហាមឃាត់រាល់ការផ្លាស់ប្តូរញឹកញាប់បុគ្គលិក,កម្មករនិងសំភារៈពីអគារមួយទៅអគារមួ
- ❑ អ្នកធ្វើការក្នុងកន្លែងចិញ្ចឹមត្រូវមានសំលៀកបំពាក់និងស្បែកជើងសំរាប់ផ្លាស់ប្តូរមុនពេលចូលកន្លែងចិញ្ចឹម ។
- ❑ នៅមាត់ច្រកនៃកន្លែងចេញចូលនៃអគារនិមួយៗ ត្រូវមានទាំងរីក៏អាងតូចៗសំរាប់ដាក់សូលុយស្យុងដើម្បីសំលាប់មេរោគនៅពេលដែលយើងឆ្លងកាត់។

ហាមឃាត់ចំពោះវត្តមានមនុស្សចំលែកចេញចូលក្នុងកន្លែងចិញ្ចឹម ។

ខ/ការចាក់ថ្នាំការពារ : (Vaccine)

ការធ្វើវ៉ាក់សាំងគឺជាការងារចំបងមួយក្នុងការចិញ្ចឹមមាន់ វាអាចជួយទប់ស្កាត់នូវការរាលដា ងឺឆ្លងបានមួយចំនួនធំ ហើយការធ្វើវ៉ាក់សាំងនេះគឺធ្វើទៅតាមអាយុរបស់សត្វគឺៈ

- ❑ កូនមាន់អាយុមួយថ្ងៃ ត្រូវធ្វើវ៉ាក់សាំងប្រឆាំងនឹងជំងឺ Marek ដោយចាក់នៅខាងក្រោមស្បែកតាមបទដ្ឋាន 0.២cc នៅក្នុងកូនមាន់មួយក្បាល ។
- ❑ បន្ទាប់មកក្នុងរយៈពេលបីថ្ងៃដំបូងត្រូវផ្តល់ពពួកអង់ទីប៊ីយូទិច (Antibiotique ) hi នៅក្នុងទឹករីលាយនៅក្នុងចំណីអោយវាស៊ី គឺការពារប្រឆាំងនឹងជំងឺរលោកផ្លូវដង្ហើមរឺជំងឺ CRD ដែលបង្កឡើងដោយបាក់តេរីឈ្មោះ៖ Mycoplasma Gallisepticum ។

ឧទាហរណ៍ : Chloramphenicol :1g/១លីត្រទឹក

Tetracycline រឺ Sulfamide : 1g/១លីត្រទឹក

ជាមួយគ្នានេះដែរត្រូវផ្តល់ពពួកវីតាមីន A.D.E.B អោយកូនមាន់ក្នុងរយៈពេលបីថ្ងៃជាប់គ្នាដែរ ។

ឧទាហរណ៍ៈ ត្រូវប្រើវីតាមីនចំនួន 2000 U.I/ក្បាល ដោយលាយទៅក្នុទឹកអោយវាផឹក។

- នៅពេលវាអាយុបានបីថ្ងៃត្រូវធ្វើវ៉ាក់សាំង ប្រភេទ F ដើម្បីប្រឆាំងការពារនឹងជំងឺ Newcastle ដោយបន្តក់មួយរឺ ពីរតំណក់នៅភ្នែករំច្រមុះ ។
- នៅពេលវាអាយុបាន៧-១០ថ្ងៃ ត្រូវធ្វើវ៉ាក់សាំងប្រឆាំងនឹងជំងឺ Gumboro ដោយដាក់ រាយជាមួយទឹកអោយវាផឹកនិងបន្តក់តាមភ្នែកនៅពេលវាមានអាយុ២៨ថ្ងៃ។
- កូនមាន់អាយុបាន១៥ថ្ងៃ ត្រូវធ្វើវ៉ាក់សាំងប្រឆាំងនឹងជំងឺអុតមាន់ (Fowl pox) ដោយចាក់ចំណុះក្នុងស្លាបមាន់ ។
- កូនមាន់អាយុបាន៣អាទិត្យឡើងទៅត្រូវធ្វើវ៉ាក់សាំងប្រភេទ Mដើម្បីប្រឆាំងការពារនឹងជំងឺ Newcastle ជាលើកទីពីរ ។
- កូនមាន់អាយុ៨អាទិត្យ ត្រូវធ្វើវ៉ាក់សាំងប្រឆាំងនឹងជំងឺ Pasteurellosis ដោយចាក់នៅក្រោមស្បែកតាមបទដ្ឋាន 1cc សំរាប់មាន់មួយក្បាល។ ក្រោយមករយៈពេល 4-6 ខែត្រូវចាក់ជា លើកទីពីរ ។

# ចប់

# មេរៀនទី ៨ ការចិញ្ចឹមមាន់ជំទង់

នៅក្នុងតំណាក់កាលនេះ យើងអាចជ្រើសរើសដឹងកូនញីនិងកូនឈ្មោលដើម្បីបំបែកយកទៅ ចេញ ពិសេសគឺកូនមាន់ឈ្មោលយើងត្រូវជ្រើសរើសចំនួនដែលត្រូវចិញ្ចឹមទុកពូជ នៅសល់ប៉ុន្មាន ចិញ្ចឹមផ្សេងគ្នា។ យើងត្រូវជ្រើសរើសយកកូនល្អមកចិញ្ចឹម ហើយត្រូវជំរុះចោលនូវកូនមាន់ដែលអង់ផ្សេងទៀតត្រូវបញ្ចូលទៅក្នុងទ្រុងយកសាច់ ។

ការចិញ្ចឹមមាន់ជំទង់សំរាប់ធ្វើជាមេមាន់ពងអាជីវកម្ម រឺមេមាន់ពងសំរាប់ពូជគឺរបៀបចិញ្ចឹមដូចគ្នា គ្រាន់តែខុសគ្នាអំពីការដាក់ឈ្មោលតែប៉ុណ្ណោះ ។

## ១.របៀបចិញ្ចឹម :

### ក/ការចិញ្ចឹមលើទ្រនើ :

នៅក្នុងពេលវាមានអាយុ ២-៣ខែ ត្រូវដាក់ពី ១៥-២០ក្បាល/ $m^2$

នៅក្នុងពេលវាមានអាយុ ៣-៤ខែ ត្រូវដាក់ពី ៨-១០ក្បាល/ $m^2$

នៅក្នុងពេលវាមានអាយុ ៤-៥ខែ ត្រូវដាក់ពី ៤-៥ ក្បាល/ $m^2$

### ខ/ការចិញ្ចឹមនៅលើកំរាល :

ការចិញ្ចឹមរបៀបនេះយើងអាចរៀបចំអោយមានទីធ្លាសំរាប់មាន់រត់លេង និងធ្វើរបងព័ទ្ធជុំវិញលើសពី ២ម៉ែត្រហើយត្រូវដាំដើមឈើដើម្បីធ្វើជាម្លប់ ។យើងត្រូវរៀបចំធ្វើជាទ្រនំ រឺបង្គងដើម្បីអោយវាដេកនៅពេលយប់ ហើយនៅក្នុងហ្វូងនិមួយៗមិនត្រូវបញ្ចូលកូនមាន់ដែលមានអាយុមិនស្មើ គ្នាទេ ។យើងអាចចិញ្ចឹមកូនមាន់ជំទង់ ១២-១៤ក្បាល/ម៉ែត្រក្រឡា ហើយនោះដូវក្តៅអាចដាក់បាន ពី ៩-១០ក្បាល/ម៉ែត្រក្រឡា ។

## ២.ការចិញ្ចឹមនិងការថែរក្សា

ក/អំពីទ្រុង គឺជាសំណង់ដែលមានខ្យល់អាកាសចេញចូលល្អ និងចែកជាល្វែងព្រមទាំងខ័ណ្ឌដោយសំណាញ់លោហធាតុ ។

ល្វែងនីមួយៗ ត្រូវមានផ្លាសំរាប់មាន់រត់លេង ទ្រុងត្រូវស្ថិតនៅលើដី ខ្ពស់ ប៉ុន្តែមិនត្រូវសន្ទឹងអោយចំសន្ទុះនៃចរន្តខ្យល់ទេ ។ នៅលើផ្ទៃល្វែងនីមួយៗ ត្រូវមានកំរាល
អង្កាមដែលមានកំរាស់ ពី៥-១០ស.ម។ ចំពោះស្នូកទឹក ស្នូកចំណី ចង្កៀងបំភ្លឺត្រូវត្រៀមទុកជាស្រេច ចំណែកទ្រូងនិងសំភារៈផ្សេងៗទៀតត្រូវរំងាប់មេរោគហើយជាស្រេចមុន នឹងបញ្ជូនមាន់មកដល់ ។

ខ/សីតុណ្ហភាព សំណើម ពន្លឺ :

ត្រូវមានសីតុណ្ហភាពជាមធ្យម ២៥ អង្សាសេ សំណើម៧០%និងពន្លឺធម្មជាតិ ។ពេលយប់ត្រូវមានចង្កៀង រឺអំពូលបំភ្លឺដើម្បីអោយមាន់ស្រួលរកទឹកនិងចំណី ។

គ/អំពីស្នូកទឹកនិងស្នូកចំណី :

ស្នូកចំណីយើងអាចធ្វើអំពីឈើបំពង់ឬស្សី, ជ័រប្លាស្ទិក រឺអំពីវត្ថុអ្វីផ្សេងៗទៅតាមចំណង់ចំ ណូលចិត្តរបស់អ្នកចិញ្ចឹមរបស់អ្នកចិញ្ចឹម។
ស្នូកចំណីទោះបីជាប្រភេទណាក៏ដោយ យើងត្រូវរៀប ចំធ្វើយ៉ាងណាកុំអោយមាន់ឡើងជាន់បាន។ ចំណែកស្នូកទឹកវិញ ត្រូវប្រើបំពង់ផ្កាប់លើចានសំប៉ែតដែលមានចំណុះទឹក ៣លីត្រ ។

ឃ/ការផ្តល់ចំណី និង ការថែរក្សា :

- ការផ្តល់ចំណី :

ចំណីចាំបាច់សំរាប់ផ្តល់អោយមាន់ជំទង់គឺ ត្រូវផ្សំឡើងដោយគ្រាប់ធញ្ញជាតិ សាច់. អំបិល សំបកឆ្អឹង. វិតាមីន និងពពួកអង់ទីប៊ីយូទិក (Antibiotique ) ។ ចំណីត្រូវមានថាមពល ២៥០០ Kcal/Kg ចំណី. ប្រូតេអ៊ីន ១៨%. សែទ្បាយលូស ៥%, Ca: ២%. P : 0.៧%. NaCl : 0.៥% និងពពួកវិតាមីនផ្សេងៗទៀត។
ចំណីត្រូវកិនកំទេចជាគ្រាប់ល្អិតៗ ហើយក្នុងមួយថ្ងៃ មាន់ជំទង់មួយក្បាលត្រូវការចំណីផ្សំ ស្រេចអស់ប្រហែល ១០០ g និងស្មៅខ្ចី រឺ បន្លែស្រស់បន្ថែម។ ដើម្បីកុំអោយខ្វះខ្វាយចំណី ត្រូវអោយវាស៊ី ពី ៣ - ៤ ដង/ថ្ងៃ ។

| ល.រ | វត្ថុធាតុដើម | (Kg) |
|---|---|---|
| ១ | ពោតក្រហម | ៤៤% |
| ២ | ចុងអង្ករ | ១២.៤៥% |
| ៣ | កន្ទក់លេខ១ | ១៦.៧៦% |
| ៤ | សណ្តែកសៀង | ១៦% |
| ៥ | ម្សៅត្រី | ៨% |
| ៦ | អំបិល | 0.៥% |
| ៧ | សំបកគ្រែង | ២% |

❖ ការថែរក្សា :

យើងត្រូវធ្វើការតាមដាន និងត្រួតពិនិត្យជារៀងរាល់ថ្ងៃអំពីអនាម័យ កន្លែងរស់នៅ អនា ម័យ ចំណីនិងទឹក ស្ថានភាពសុខភាពរបស់សត្វ ។ ស្នូកទឹកត្រូវដុសលាងព្រឹកល្ងាចទៅតាមសភាព ជាក់ ស្តែង ដើម្បីកុំអោយធំក្លិនស្អុយ ។

ក្នុងរយៈពេលមួយអាទិត្យ ត្រូវកើបលាមកចេញអោយបាន ១ - ២ដង ចំពោះការចិញ្ចឹម ដាក់នៅក្នុងទ្រុងកា (Cage ) ។ មាន់ដែលឈឺត្រូវយកវាចេញទៅចិញ្ចឹមដោយឡែក ដើម្បីងាយ ស្រួលក្នុងការតាមដានជំងឺរបស់វា។ ចំណែកសាកសពមាន់ត្រូវយកទៅកប់ចោល រឺត្រូវទុកដើម្បីធ្វើ ការវះកាត់ត្រួតពិនិត្យ រឺបញ្ជូនទៅកាន់មន្ទីរពិសោធន៍ដើម្បីធ្វើការវិនិច្ឆ័យរោគ ។

ង/វិធានការការពារ :

ដើម្បីជៀសវាងការចំលងមេរោគពីខាងក្រៅចូលមកខាងក្នុង ត្រូវហាមជាដាច់ខាតមិន អោយអ្នកចំឡែកចូលទៅក្នុងកន្លែងចិញ្ចឹមមាន់។ អ្នកចិញ្ចឹមត្រូវមានកន្លែងផ្លាស់ប្តូរសំលៀកបំពាក់និងនៅពេលចុះធ្វើការក្នុងទ្រុងមាន់ម្តងៗ ត្រូវធ្វើការរំងាប់មេរោគនៅបាតជើង ដោយដើរជាន់កំបោរ ដែលដាក់ក្នុងឡាំង រឺអាងនៅតាមផ្លូវចេញចូលទៅក្នុងទ្រុង។

❑ ការប្រើប្រាស់ថ្នាំការពារ :

- ត្រូវប្រើថ្នាំ Erytromycine ម្សៅលាយក្នុងទឹកអោយវាផឹកក្នុងរយៈពេល១ខែ

ម្តង ។ ត្រូវប្រើថ្នាំ Streptomycine 1g លាយទឹក 10 លីត្រ អោយមាន់ផឹកដើម្បីការពារនឹងជំងឺ Pasteurellose និងជំងឺ Poullorose ។

- នៅមុនពេលរដូវភ្លៀង រឺនៅខែទី ៤ ត្រូវវ៉ាក់សាំងជំងឺ Newcastle សារជាថ្មីម្តងទៀត ។

# ចប់

# មេរៀនទី ៩ ការចិញ្ចឹមមាន់ពង

ដោយសេចក្តីរបស់មនុស្សអំពីបញ្ហាចំណីអាហារពីមួយថ្ងៃទៅមួយថ្ងៃកាន់តែកើនឡើងស្រប នឹងបច្ចេកទេសខាងផ្នែកចិញ្ចឹមសត្វស្លាបត្រូវបានគេអនុវត្តពាសពេញនៅលើពិភពលោក ធ្វើអោយ ការចិញ្ចឹមសត្វស្លាបរបៀបប្រពលវប្បកម្មកាន់តែរីកចំរើនឡើង។ អាយុ ៥ខែឡើងមេមាន់ចាប់ផ្តើម ពង ហើយតាមសំណូមពរ បច្ចេកទេសចិញ្ចឹមគឺត្រូវចិញ្ចឹមរស់អោយបាន ៩០% និង ទិន្នផលស៊ុតឱ្យ បាន ៧០%ឡើង ។

១/ គោលបំណង : ការចិញ្ចឹមមាន់ពង គឺយើងចិញ្ចឹមដើម្បីយកស៊ុតទៅធ្វើអាជីវកម្ម រឺដើម្បី យកស៊ុតទៅភ្ញាស់ដើម្បីបន្តពូជ ។

២/ អំពីទ្រុង : គឺជាសំណង់ដែលមានខ្យល់អាកាសចេញចូលល្អ ចែកចេញជាល្វែង និងខ័ណ្ឌដោយសំណាញ់ដែក ។

ល្វែងនមួយៗត្រូវមានផ្លាសំរាប់មាន់រត់លេង គឺក្នុងលក្ខណៈដែលយើងអាចធ្វើ ទៅបាន។ គេធ្វើទ្រុងមាន់ផ្តល់ពងនៅជិតវាលស្មៅធំទូលាយ និងមានម្លប់សំរាប់អោយមាន់ជ្រក ។ យើងអាចចិញ្ចឹមមាន់ពងនៅលើកំរាល (ការចិញ្ចឹមជាហ្វូង ) និងនៅក្នុងទ្រុងកា (Cage) ដែលសង់ ឡើងជាច្រើនថ្នាក់ និងខ័ណ្ឌចែកជាប្រលោះតូចៗសំរាប់តែមាន់មួយក្បាល រឺពីរក្បាលតែប៉ុណ្ណោះ ។

៣/ ការជ្រើសរើសពូជ :

ដើម្បីរក្សាអោយសមាមាត្រនៃការផ្តល់ស៊ុតមានការទៀងទាត់នោះ យើងត្រូវធ្វើការជ្រើស រើសយកមេមាន់នៅក្នុងតំណាក់កាលដែលវាមានអាយុ ១៩អាទិត្យ និងក្រោយរយៈពេលដែលវាពងរួចបានបីខែ។

ក. ទិន្នផលស៊ុត :

ក្នុងរយៈពេល ៩០ថ្ងៃក្រោយពេលដែលវាពង យើងត្រូវធ្វើការជ្រើសរើសយកមេមាន់ណា ដែលផ្តល់ទិន្នផលស៊ុតបានច្រើន គឺលើសពី ៥០ក្នុងរយៈពេល ៩០ថ្ងៃ ។

ខ.សមាមាត្រនៃការផ្តល់ស៊ុត :

មេមាន់ចាប់ផ្តើមពងនៅពេលវាមានអាយុពី ៤ - ៥ខែ ពេលនោះអាត្រាពងអាចផ្តល់ពី ២៥-៥០% ហើយក្រោយរយៈពេល ៩០ថ្ងៃដែលវាពងនោះអាត្រារបស់ហ្វូងទាំងមូលអាចផ្តល់ស៊ុត ពី

៦០ - ៧០% ហើយវាអាចផ្តល់ស៊ុតកំរិតអតិបរមាតីពី ៨០ - ៩០%គឺក្នុងរយៈពេលពី ៤ - ៥ខែ បន្ទាប់ ហើយចាប់ពីអាទិត្យទី៤២ រហូតទៅដល់អាទិត្យទី៧៤ សមាមាត្រនៃការផ្តល់ស៊ុតគឺនៅប្រហែល ៦០% រឺក៏អាចនៅក្រោមនេះ។ នៅរដូវក្តៅមេមាន់ពុំសូវផ្តល់ស៊ុតទេ ប៉ុន្តែនៅរដូវរំហើយអាកាសធាតុល្អ មាន់អាចផ្តល់ស៊ុនូវអាត្រាខ្ពស់បំផុត ។

ចំពោះមេមាន់ដែលផ្តល់ទិន្នផលស៊ុតតិច យើងត្រូវធ្វើការត្រួតពិនិត្យឡើងវិញ ដោយមានតា រាងតាមដានសុខភាព, គុណភាពពង រឺកត់ពីអាត្រាពងដើម្បីពិសោធន៍សម្ថភាពរបស់មេមាន់និមួយៗ ជាពិសេសយើងត្រូវជំរុះចោលនូវមេមាន់ណា ដែលផ្តល់ស៊ុតមានលក្ខណៈខុសពីធម្មតាដូចជា : សំបក ទន់ . ស៊ុតតូចពេក រឺក៏ស្ងួចសងខាង ។

គ. រូបរាងខាងក្រៅរបស់មេមាន់ :

ក្រោយរយៈពេលដែលពងបាន ៣ខែ ឈើអាចធ្វើការប្រៀបធៀបរវាងមេមាន់ដែលពងបានល្អ និងមេមាន់ដែលពងមិនសូវល្អគឺ :

- ចំពោះមេមាន់ដែលពងបានល្អ គឺពោះរបស់វាធំ ហើយទន់. ត្រគាកវាសាយ និងរន្ធក្លូអាក់រីកធំ ។ មេមាន់ពងកាន់តែច្រើន សារធាតុការតែន (Carotene) ដែលមាននៅចំពុះ គល់ចំពុះ ស្បែក. ជើង ម្រាមជើង នឹងត្រូវបាត់បង់កាន់តែខ្លាំង។

មេមាន់ដែលពងបានល្អ គឺវានៅក្បែរ ឈ្មោល ហើយព្រមនឹងឈ្មោលជានិច្ច ( កាលណាយើងយកដៃទៅដាក់ពីលើខ្នងរបស់វា គឺវាអោនក្រាបចុះ ) ។

- ចំពោះមេមាន់ពងមិនសូវល្អ គឺពោះរបស់វាមានលក្ខណៈរឹង ហើយរន្ធក្លូអាក់តូច ពុំសូវមានចលនា ។ វាធ្វើចលនាដោយលោតចុះឡើង ដោយពុំព្រមជាមួយឈ្មោលទេ ។ ដើម្បីទទួលបានទិន្នផល ស៊ុតល្អ យើងត្រូវធ្វើការជំរុះវាជារៀងរាល់ខែ (ជាមធ្យមគឺប្រហែល ២% ក្នុងរយៈពេល១ខែ ) ។ ៤/ ការផ្តល់ចំណី - ថែរក្សា - ការប្រមូលស៊ុត :

ក. ការផ្តល់ចំណី : យើងត្រូវធ្វើការផ្តល់ចំណីអោយវាស៊ីអោយបានគ្រប់គ្រាន់ ដើម្បីអោយ វាផ្តល់ស៊ុត និងរក្សាទំងន់របស់វា។ យើងត្រូវផ្តល់ចំណីដែលមានបរិមាណប្រូតេអ៊ីនពី ១៦ - ១៧%

ថាមពលបំលែង ២៨៥០ Kcal / 1Kg ចំណី. Ca: 3,5%. P: 0,7%. Metionine: 0,55% Cellulose: 5-6%. Vitamin A: 12000-15000 UI / 1Kg ចំណី. Vitamin D3 :1500 - 2000 UI/1Kg ចំណី។

ចំពោះមាន់ឈ្មោល ( ពូជ) ត្រូវបន្ថែមបន្លែស្រស់. ម្សៅស្មៅ ពោតលឿង ដើម្បីជួយបំ ពេញដល់ស៊ុតក្រហមអោយមានលក្ខណៈជីវសាស្រ្តខ្ពស់ ព្រោះស៊ុតក្រហមមានឥទ្ធិពលដល់ការរីក ចំរើនរបស់អំប្រីយ៉ុង។

យើងត្រូវធ្វើការកំនត់ បរិមាណនៃសមាសធាតុផ្សេងៗនៅក្នុងចំណី អោយបានគ្រប់គ្រាន់ ហើយត្រូវជៀសវាងការផ្លាស់ប្តូរភ្លាមៗនូវប្រភេទចំណី ដែលជាហេតុធ្វើអោយបរិមាណស៊ុតត្រូវថយ ចុះ ។ ចំពោះមាន់ផ្តល់ស៊ុតត្រូវកំណត់ចំណីអោយវាស៊ីពី ១១០ - ១២០ក្រាម/ក្បាល/ថ្ងៃ។ ចំណែក មាន់ផ្តល់សាច់ត្រូវអោយវាស៊ីពី ១៥០ - ១៦០ក្រាម/ថ្ងៃ/ក្បាល ។ មិនត្រូវប្រើប្រាស់ចំណីដែលមានក្លិនខាខ្លាំងដូចជា : ម្សៅត្រី ប្រេងថ្លើមត្រី. កន្ទក់ ព្រោះ វាមានឥទ្ធិពលអាចធ្វើអោយមានការប្រែពណ៌របស់ស៊ុតក្រហម និងបណ្តាលអោយខូចខាតដល់ការ លូតលាស់របស់អំប្រីយ៉ុង។

ដើម្បីកុំអោយខ្វះខ្វាយចំណី ត្រូវដាក់អោយវាស៊ី ២ រឺ ៣ដង /ថ្ងៃ។ ត្រូវឧស្សាហ៍ដុសលាងស្នូកទឹក និងស្នូកចំណីអោយបានជាប្រចាំ។

រូបមន្តសម្រាប់ក្នុងការផ្សំចំណីសម្រាប់មាន់ពង ( ១០០ គក្រ )

រូបមន្តសម្រាប់ក្នុងការផ្សំចំណីសម្រាប់មាន់ពង ( ១០០ គក្រ )

| ល.រ | វត្ថុធាតុដើម | គិតជា គក្រ |
|---|---|---|
| ១ | ពោតក្រហម | ៤៩ |
| ២ | ចុងអង្ករ | ៥.៧៥ |
| ៣ | កន្ទក់លេខ១ | ៥.៤ |
| ៤ | សណ្តែកសៀង | ១៥ |

| | | |
|---|---|---|
| ៥ | ម្សៅត្រី | ១៧ |
| ៦ | អំបិល | 0.៥ |
| ៧ | សំបកគ្រែង | ៥ |
| ៨ | មេត្យូនីន | 0.១ |

ខ. ការថែរក្សា : អ្នកថែរក្សានៅក្នុងទ្រុងមាន់ត្រូវមានសភាពទន់ភ្លន់ កុំស្រែកឡូឡា មិនត្រូវមានសំឡេងអ៊ូអរ និងជៀសវាងប្រើនូវវត្ថុណាដែលមិនមែនជាទំលាប់ធម្មតានៅក្នុងទ្រុង។ មិនត្រូវប្រើពណ៌ក្រហម រឺលាបថ្នាំក្រហមនៅលើចំពុះមាន់ទេ ព្រោះអាចបណ្តាលអោយមាន់ចឹកគ្នា ទៅលើស្នាមពណ៌ក្រហម ដែលជាហេតុនាំជាហេតុនាំអោយមាន់ងាប់។ ត្រូវជៀសវាងចំពោះប្រការ ខាងលើនេះ ព្រោះកាលណាមាន់ផ្អើល បរិមាណស៊ុតត្រូវថយចុះ ។

គ. ការប្រមូលស៊ុត : ត្រូវឧស្សាហ៍ប្រមូលស៊ុតអោយបាន ពីរដងក្នុងមួយថ្ងៃ ។ ស៊ុតដែល ប្រមូលត្រូវដាក់លើប្រដាប់ទ្រស៊ុត ដើម្បីជៀសវាងកុំអោយបែក។ ចំពោះបញ្ហាស៊ុតបែកច្រើនគឺ បណ្តាលមកពី :

- ❑ មាន់ពងលើកំរាលអង្កាមស្តើងពេក
- ❑ មាន់ពងលើទ្រនើដែលមានប្រហោងធំ -
- ❑ សំបុកពងតិចពេក បណ្តាលអោយមាន់ប្រជ្រៀតគ្នា ។

៥/ លក្ខខ័ណ្ឌផ្សេងៗក្នុងការចញ្ចឹមមាន់ពង :

ក. អំពីសីតុណ្ហភាព : សីតុណ្ហភាពដែលសមស្របក្នុងការចិញ្ចឹមមាន់ពង គឺ ២៥ អង្សារ ។

ខ. សំណើម : សំណើមដែលសមស្របក្នុងការចិញ្ចឹមមាន់ពង គឺ ៧៥% ប្រសិនបើទាបពេក នោះធ្វើអោយមាន់ផឹកទឹកច្រើន, ស៊ីតិច និងធ្វើអោយបរិមាណនៃកំទេចកំទីផ្សេងៗដែលមាននៅ ក្នុងទ្រុងមាន់កើនឡើងខ្ពស់ ដែលជាហេតុធ្វើអោយមាន់មានការពិបាកក្នុងការដកដង្ហើម ហើយងាយនឹងទទួលនូវជំងឺ C.R.D និងជំងឺផ្លូវដង្ហើមផ្សេងៗទៀត ។

នៅពេលដែលសំណើមខ្ពស់ខ្លាំង (>85% ) នោះធ្វើអោយការដកដង្ហើមរបស់មាន់មានចំនួន ១៥0ដង/នាទី។ ម៉្យាងទៀតបរិមាណទឹកក្នុងបរិយាកាសខ្ពស់ នាំអោយបណ្តូរនៃប្រព័ន្ធ

ខ្យល់ចូលទៅក្នុងសួតមាន់ពុំបានគ្រប់គ្រាន់។ ដូច្នេះនៅពេលដែលសំណើមខ្ពស់ពេក ក៏ងាយនឹងទទួលនូវ ជំងឺ C. R.D ដែរ ។

គ. អំពីពន្លឺ: មានសារៈសំខាន់ណាស់ក្នុងការចិញ្ចឹមមាន់យកស៊ុត។ ត្រូវផ្តល់ពន្លឺអោយបាន ត្រឹមត្រូវ គឺនៅពេលដែលមាន់មានអាយុ ២១អាទិត្យឡើងទៅត្រូវផ្តល់ពន្លឺពី ១៦ - ១៧ម៉ោង/ថ្ងៃ ការផ្តល់ពន្លឺបានត្រឹមត្រូវ គឺអាចបំផុសផលិតកម្មស៊ុតបានពី ៥ - ១០% តែប្រសិនការផ្តល់ ពន្លឺពុំបានទៀងទាត់ទេ នោះនឹងធ្វើអោយផលិតផលស៊ុតត្រូវថយចុះ។ ចំណែកមាន់ឈ្មោល (ពូជ ) វិញ ការផ្តល់ពន្លឺអាចធ្វើអោយគុណភាពន្ថែមត្រូវចុះខ្សោយ អាស្រ័យដោយថាមពលរបស់ពន្លឺរំ ញោចដល់ការកកើតស្ពែមកើនឡើងខុសលក្ខណៈធម្មតា។

ចំពោះប្រភពពន្លឺ យើងយកអំពូលភ្លើង ដែលមានអនុភាព 40W ដោយព្យួរកំពស់ជាង 2mពីផ្ទៃកំរាល ហើយប្រភពពន្លឺនេះសំរាប់ផ្ទៃ $9m^2$ ក្នុងតំណាក់កាលដែលមាន់កំពុងផ្តល់ស៊ុត យើងមិនត្រូវផ្លាស់ប្តូររយៈពេលផ្តល់ពន្លឺឆាប់រហ័ស ពេកទេ ហើយការផ្តល់ពន្លឺត្រូវអនុវត្តនៅពេលព្រឹក និងពេលយប់ ជាពិសេសនៅរដូវត្រជាក់។ អាំង តង់ស៊ីតេនៅក្នុងកន្លែងចញ្ចឹម គួរតែភ្លឺច្បាស់ល្អ គឺអាចអានកាសែតបាន។ ពន្លឺពណ៌ស និងពណ៌ទឹក ក្រូចជួយបំផុសអោយមាន់ផ្តល់ស៊ុតបានច្រើនបញ្ឈប់ដល់ដំណើរការពង ។

## ៦/ វិធានការការពារ :

ត្រូវអនុវត្តអនាម័យអោយបានត្រឹមត្រូវ ដូចជាសំអាតទ្រុងមាន់ និងសំភារៈប្រើប្រាស់ផ្សេងៗ។ ចង្អូរទឹកមិនត្រូវទុកអោយធំក្លិនស្អុយ ។ល។ ចំពោះកំរាលអង្កាមត្រូវផ្លាស់ប្តូរពី ២-៣ខែម្តង ។

- ថ្នាំការពារ :
  - ត្រូវប្រើថ្នាំ Erytromycine ម្សៅប្រើលាយទឹកអោយវាផឹក ក្នុង១ខែម្តង
  - ដើម្បីការពារនឹងជំងឺ Pasteurellose និង Pullorose ត្រូវប្រើថ្នាំ Streptomycine1g លាយជាមួយទឹក 10L អោយមាន់ផឹក ។

- ដើម្បីការពារប្រឆាំងនឹងជំងឺ Newcastle យើងត្រូវចាក់ថ្នាំការពារ ២ដង គឺនៅពេលវាអាយុបាន ១៩អាទិត្យ និងក្រោយរយៈពេលរយៈពេល ៦ខែ គឺនៅពេលដែលវាអាយុបាន១២ខែ ។យើងប្រើថ្នាំ Imopestប្រភេទទឹកគឺ 1cc/ 3 ក្បាល ។
- ចំពោះមាន់ពងដែលចិញ្ចឹមនៅលើកំរាល រឺនៅលើដីផ្ទាល់ត្រូវបញ្ចុះព្រូនក្នុងរយៈពេល ៣ខែម្តង ។ គឺប្រើ Piperazine : 3mg / 1kg ចំណី ។

# ចប់

# មេរៀនទី ១០ ការចិញ្ចឹមមាន់ពងពូជ

១/ គោលបំណង : ការចិញ្ចឹមហ្វូងមេមាន់ពង ( ពូជ គឺដើម្បីយកស៊ុតដែលមានកំណ ទៅភ្ញាស់ សំរាប់បង្កើតជាហ្វូងមាន់ជំនាន់ក្រោយដែលមានសុខភាពល្អ និងផ្តល់នូវបរិមាណស៊ុតខ្ពស់។

២/ រយៈពេលជ្រើសស៊ុតយកទៅភ្ញាស់ :

មេមាន់ផ្តល់ស៊ុតចាប់ផ្តើមពង នៅពេលវាមានអាយុចាប់ពី ៤ - ៥ខែឡើងទៅ ។ ប៉ុន្តែនៅក្នុងតំណាក់កាលដែលវាចាប់ផ្តើមពងជាលើកដំបូង គឺយើងពុំទាន់ធ្វើការជ្រើសរើសយកស៊ុតទៅភ្ញាស់ ទេ តរបស់វាមានលក្ខណៈតូច ហើយអាត្រាដែលមានកំណកំណើត និងអាត្រាញាស់នៅមានកម្រិតទាប។

តាមលក្ខណៈបច្ចេកទេស តំណាក់កាលដែលយើងត្រូវធ្វើការជ្រើសរើសយកស៊ុតទៅភ្ញាស់ គឺកាប់ពីខែ ទី៧ឡើងទៅរហូតទៅដល់ខែ ទី ១៦ - ១៧ (មានរយៈពេលពី ៩ - ១០ខែ ) ។ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង ដោយផ្អែកទៅលើលក្ខណៈ
បច្ចេកទេសនោះ គឺនៅពេលដែលមេមាន់មាន អាយុ ១៥ខែឡើងទៅ គឺគេចាប់ផ្តើមធ្វើការជំរុះវាជាបណ្តើរៗ រហូតដល់ខែទី១៧ ព្រោះនៅក្នុងតំ លណាស់កាលនេះ អាត្រានៃការញាស់ កាន់តែថយចុះ ។

៣/ ផ្ទៃក្រឡាសំរាប់ចិញ្ចឹម :

យើងត្រូវរៀបចំកន្លែងចិញ្ចឹមមេមាន់ពង ( ពូជ)អោយបានត្រឹមត្រូវទៅតាមលក្ខណៈបរទេស។ ប្រសិនបើយើងចិញ្ចឹមវា ដោយពុំបានគិតអំពីលក្ខណៈបច្ចេកទេស ដូចជា ចង្អៀតពេកនោះនឹងអោយការលូតលាស់របស់មេមាន់ពុំស្មើគ្នា ហើយការផ្តល់ស៊ុតត្រូវថយចុះ។ ដូច្នេះយើងដោយធ្វើការកំណត់ចំនួនក្បាលទៅនឹងផ្ទៃក្រឡាគឺ :ពី ៥ - ៦ក្បាល / $m^2$( យកស៊ុតពូជ )

ពី ២.៥ - ៣ ក្បាល / $m^2$( យកសាច់ )

គឺប្រហែលពី ១០ - ១២ Kg នៃទំងន់ / $m^2$)

៤/ របៀបដាក់ឈ្មោល :

យើងត្រូវជ្រើសរើសយកឈ្មោល ( បា ) ដែលមានសុខភាពល្អ មានរាងធំធាត់, រឹងម៉ា និង មានទំងន់ចាប់ពី 2,5 Kg ឡើងទៅ ហើយត្រូវមានអាយុ ៩ខែ តែមិនត្រូវលើសពី ៣ឆ្នាំ ។

- ឈ្មោល / ញី (ស៊ុតពូជ) : ១ / ១២ក្បាល ។
- ឈ្មោល / ញី (សាច់) : ១ / ៨ - ១០ក្បាល ។

## ៥/ អំពីចំណី :

យើងត្រូវរៀបចំណីសំរាប់មាន់ពងពូជ ដោយអោយវាស៊ីអោយបានគ្រប់គ្រាន់។ តែត្រូវកំ ណត់អោយវាស៊ីពី ១០០ - ១១០ក្រាម/ថ្ងៃ/ក្បាល។ ត្រូវមានស្នូកបន្ថែមដាក់ Ca និង P សំរាប់ មេមាន់ ។ យើងត្រូវរៀបចំស្នូកទឹក និងស្នូកចំណីអោយបានគ្រប់គ្រាន់ ប្រសិនបើពុំគ្រប់គ្រាន់ទេនោះ មាន់ធំ និងចឹកមេដែលតូចជាងវា។ធ្វើអោយការធំធាត់មិនស្មើគ្នា។

## ៦/ការប្រមូល និងរក្សាស៊ុត :

យើងត្រូវឧស្សាហ៍ប្រមូលស៊ុតជាបន្តបន្ទាប់ គឺក្នុងរយៈពេល ១ - ២ម៉ោងម្តង ( ការចិញ្ចឹម នៅលើកំរាល ) ។ យើងត្រូវធ្វើការជ្រើសរើសយកស៊ុតដែលមានលក្ខណៈល្អទុកសំរាប់ភ្ញាស់ និងត្រូវជំរុះចោលនូវស៊ុតដែលមានលក្ខណៈមិនល្អចេញ។ ត្រូវយកកន្សែង រំក្រដាសស្តើងទៅជូតសើៗ នៅ លើសំបកស៊ុតដែលកខ្វក់ និងហាមដាច់ខាតមិនត្រូវយកស៊ុតទៅលាងស៊ុត ។ ចំពោះស៊ុតដែលប្រឡាក់ ឈាម ត្រូវជំរុះចោល។ ស៊ុតត្រូវរក្សាទុកក្នុងបន្ទប់ ដែលមានសីតុណ្ហភាព ពី ១៥ អាចទុកបានរយៈ ពេលពី ២ - ៣អាទិត្យ ។

# ចប់

# មេរៀនទី ១១ ការចិញ្ចឹមមាន់ពងអាជីវកម្ម

**១. គោលបំណង :** ការចញ្ចឹមហ្វូងមេមាន់ពង ( អាជីវកម្ម ) គឺដើម្បីយកស៊ុតទៅធ្វើអាជីវ កម្មនៅលើទីផ្សារ ដើម្បីបំរើសេចក្តីត្រូវការរបស់អតិថិជន ។

**២. រយៈពេលធ្វើអាជីវកម្ម :**

មេមាន់ចាប់ផ្តើមពង នៅពេលវាមានអាយុ ពី ៤ - ៥ខែឡើងទៅ។ នៅអាទិត្យទី២២ ទិន្ន ផលស៊ុតរបស់វា ផ្តល់បានប្រហែល ៣០% ហើយទិន្នផលស៊ុតនេះ នឹងត្រូវកើនឡើងជាបណ្តើរៗ ហើយត្រូវថយចុះមកវិញ នៅពេលវាមានអាយុ ៤២អាទិត្យ ។ លុះដល់ពេលវាមានអាយុ៧៤ អាទិត្យ គឺវានៅផ្តល់ទិន្នផលស៊ុតបានប្រហែល ៦០% (នៅពេលនោះគេចាប់ផ្តើមលក់វាចេញ ) ។ តែប្រសិន បើគេចាប់ផ្តើមធ្វើការជំរុះវាជាបណ្តើរៗ នៅពេលវាមានអាយុ ៥០អាទិត្យឡើង នោះគេអាចចិញ្ចឹម វារហូតទៅដល់អាយុ ២៤ខែ (ការធ្វើអាជីវកម្មស៊ុតនៅតែមានចំណេញ ) ។ ទិន្នផលនៃការផ្តល់ស៊ុត នៅឆ្នាំទី II ត្រូវថយចុះប្រហែល២៥% បើប្រៀបធៀបទៅនឹងឆ្នាំទី 1 ។



ក្រាហ្វិចសមាមាត្រនៃការផ្តល់ស៊ុតខាងលើនេះ គឺទទួលបានក្នុងកំរិតមួយដែលហ្វូងមាន់មានសុខភាពល្អ និងមានជីវជាតិគ្រប់គ្រាន់នៅក្នុងចំណី។ ប្រសិនបើសមាមាត្រនៃការផ្តល់ស៊ុតមានការ ថយចុះ រំខុសពីចំណុចណាមួយនៃក្រាហ្វិក នោះយើងត្រូវធ្វើការត្រួតពិនិត្យទៅលើគុណភាពចំណីនិងបណ្តាជំងឺឆ្លងផ្សេងៗ ។

## ៣. អំពីទ្រុងសំរាប់ចិញ្ចឹម :

ក/ ការចិញ្ចឹមនៅក្នុងទ្រុងកា (Cage) : ការចិញ្ចឹមមាន់ពងនៅក្នុងទ្រុងកា គឺយើងមានលទ្ធ ភាពក្នុងការតាមដានសកម្មភាព មាន់ណាដែលផ្តល់ស៊ុត និងមាន់ណាដែលពុំសូវផ្តល់ស៊ុត ។ ម៉្យាងទៀតការចិញ្ចឹមរបៀបនេះ ពុំសូវកើតមាននូវជំងឺឆ្លងផ្សេងៗ និងស៊ុតដែលយើទទួលបាន គឺមានសភាពល្អ ។

ខ/ ការចិញ្ចឹមនៅលើកំរាល រំនៅលើដីផ្ទាល់ : ការចិញ្ចឹមមាន់ពងនៅលើកំរាល រំនៅលើដីផ្ទាល់ គឺងាយនឹងទទួលនូវជំងឺឆ្លងផ្សេងៗ ។ យើងពុំអាចធ្វើការត្រួតពិនិត្យ និងតាមដានចំពោះមេមាន់ ណា ដែលផ្តល់ស៊ុតបានច្រើន ហើយមេណាដែលពុំសូវពង។ ការចំណាយចំណី គឺច្រើនជាងការចញ្ចឹម នៅក្នុងទ្រុងកា។ ស៊ុតដែលទទួលបានគឺមានសភាពកខ្វក់ ហើយរយៈពេលរក្សាស៊ុតគឺមានរយៈពេល ខ្លី។

## ៤. ការប្រមូលស៊ុត :

ត្រូវធ្វើការប្រមូលស៊ុតអោយបាន ២ដង/ថ្ងៃ។ ស៊ុតដែលប្រមូលបានហើយ ត្រូវរៀបដាក់លើប្រដាប់ទ្រស៊ុត ដោយដាក់ផ្នែកដែលស្រួចចុះក្រោម ។ មុនពេលចែកចាយស៊ុតទៅលើទីផ្សារយើង អាចធ្វើការរំងាប់មេរោគបាន ដោយលាងស៊ុតទៅក្នុងទឹកអំបិល, ទឹកកំបោរ $Ca(OH)_2$ រំទឹកសាវែល ។ នៅពេលលាងរួច ត្រូវប្រើកង្ហាបក់ជាជំនួយដើម្បីអោយឆាប់ស្ងួត ។



# មេរៀនទី ១២ ការចិញ្ចឹមមាន់សាច់

១.គោលបំណង : ការចិញ្ចឹមមាន់សាច់ គឺដើម្បីបង្កើនទិន្នផលសាច់សំរាប់បំរើសេចក្ដីត្រូវការរបស់មនុស្ស ។

២. ការវាយតំលៃ : មាន់សាច់ត្រូវបានគេវាយតំលៃថាល្អ នៅពេលដែលស្បែករបស់វាមាន ពណ៌លឿង និងកំរិតធំធាត់របស់វាមានការជាក់លាក់។ សាច់ត្រូវមានលក្ខណៈស្រស់ ស្ងួត មាន ពណ៌ស រំពណ៌ផ្កាឈូកស្លែត ហើយមានលក្ខណៈផុយ ។ ជាធម្មតាគុណភាពរបស់សាច់មាន់ក៏អាស្រ័យទៅនឹងករណីផ្សេងៗ នៃការសំឡាប់វាដែរដូចជា :

- ត្រូវជ្រលក់ទឹកក្ដៅអោយបានសព្វ
- ស្បែកគ្មានដាច់
- គ្មានជាំឈាម

៣. រយៈពេលចញ្ចឹម :

ការចញ្ចឹមមាន់សាច់ គឺមានរយៈពេលខ្លី ។

- Plymouth រយៈពេលសមស្រប 8 w
- Hybro រយៈពេលសមស្រប 7 w
- ការចញ្ចឹមមាន់សាច់ ប្រសិនបើយើងអូសបន្លាយពេលវេលា នោះការចញ្ចឹមរបស់យើងកាន់តែចំណាយចំណីច្រើនឡើងៗ ( នាំអោយខាត ) នេះក៏អាស្រ័យដោយទីផ្សារមានការប្រែ ប្រួល។ ជួនកាលការចិញ្ចឹម ក៏ត្រូវមានរយៈពេលយូរបន្តិចដែរ ព្រោះពេលដែលយើងរហ័សបញ្ចេញលក់ គេថាមាន់មានជំងឺ។
- ៤. របៀបចិញ្ចឹម :
- នៅពេលវាមានអាយុពី ១ - ៤ w ការចិញ្ចឹមបំប៉ន គឺដូចគ្នានឹងកូនមាន់ចិញ្ចឹមយកពងដែរក៏ ប៉ុន្តែ វាត្រូវការសីតុណ្ហភាពខ្ពស់ជាងកូនមាន់ចិញ្ចឹមយកពងបន្តិច។

កំរិតនៃការលូតលាស់របស់មាន់សាច់មានការរីកចំរើន និងកើនទំងន់យ៉ាងឆាប់រហ័ស ដូច្នេះ តំរូវការប្រូតេអ៊ីននៅក្នុងចំណី ក៏ត្រូវទាមទារអោយមានកិរិតខ្ពស់ដែរ។ នៅក្នុងតំណាក់កាលដំបូងចំណីត្រូវមានប្រូតេអ៊ីន ២២% ដើម្បីបង្កើតជាសាច់ទ្រូង និងសាច់គូទ ។

- ❑ នៅពេលវាមានអាយុពី ៤ - ១០អាទិត្យ ត្រូវបំប៉នចំណីអាហារដែលសំបូរទៅដោយជាតិ ស្ករ និងបន្ថយនូវកំរិតប្រូតេអ៊ីន ដើម្បីអោយវាធំធាត់ឆាប់រហ័ស ។
- ❑ ចំពោះថាមពលវិញគឺផ្ទុយគ្នា ព្រោះនៅបណ្ដាអាទិត្យដំបូង គឺបណ្ដូរថាមពលនៅរក្សាកិរិត 3000 KCal /kgចំណី ប៉ុន្តែនៅអាទិត្យក្រោយបន្តបន្ទាប់ វានឹងកើនឡើងរហូតទៅដល់ 3400KCal/kgចំណី នៅក្នុងតំណាក់កាលចុងក្រោយ។

រូបមន្តចំណីសម្រាប់មាន់យកសាច់ ( ១០០ គក្រ )

រូបមន្តចំណីសម្រាប់មាន់យកសាច់ ( ១០០ គក្រ )

| ល.រ | វត្ថុធាតុដើម | អាយុ ០ - ៣ w | អាយុ ៣ - ៦ w | អាយុ ៦ - ៩ w |
|---|---|---|---|---|
| ១ | ពោត | ៤៨% | ៤៦% | ៤៤% |
| ២ | ម្សៅត្រីលេខ១ | ៣២% | ២៧% | ២៣% |
| ៣ | កន្ទក់លេខ១ | ១៥% | ២០% | ២៣% |
| ៤ | ចុងអង្ករ | ៥% | ៧% | ១០% |
| ៥ | អំបិល | 0.៥% | 0.៥% | 0.៥% |
| ៦ | ប្រេមិក | 0.២% | 0.២% | 0.២% |
| ៧ | សំបកគ្រែង | 0.0% | 0.0% | 0.0% |

| សរុបៈ | ប្រូតេអ៊ីន | ២២% | ២០% | ១៨% |
|---|---|---|---|---|
| | សែលុយឡូស | ៣% | ៣.៦% | ៣.៦% |
| | Ca | ១.៧% | ១.៥% | ១.៣% |

ក/ ការចិញ្ចឹមនៅលើទ្រនើ :

ការចិញ្ចឹមមាន់សាចនៅលើទ្រនើយើងអាចសន្សំសំចៃបាននូវផ្ទៃក្រឡាសំរាប់ចិញ្ចឹមជាពិសេស យើងអាចធ្វើការត្រួតពិនិត្យទៅលើផ្នែកអនាម័យ ។

ដង់ស៊ីតេនៃការចិញ្ចឹមនៅលើទ្រនើគឺ : ពី ២០ - ២៥ Kg/$m^2$ ប៉ុន្តែនៅរដូវក្តៅ ជាមធ្យមគឺ 15 Kg/$m^2$

ការចិញ្ចឹមនៅលើទ្រនើ គឺត្រូវមានកំរិតប្រូតេអ៊ីន និងថាមពលកំដៅគ្រប់គ្រាន់តាមសំណូមពរ។

ខ/ ការចិញ្ចឹមនៅក្នុងទ្រុងលាត :

ការចិញ្ចឹមមាន់សាច់នៅក្នុងទ្រុងលាត យើងត្រូវកំណត់ចំនួនក្បាលទៅនឹងក្រឡាផ្ទៃសំរាប់ចិញ្ចឹមអោយបានសមស្រប : ជាមធ្យមគឺ 15Kg នៃទំងន់/$m^2$ និងនៅរដូវក្តៅជាមធ្យមគឺ 12Kg នៃទំងន់ /$m^2$ ។ ថាមពលត្រូវខ្ពស់ ហើយប្រូតេអ៊ីនត្រូវផ្តល់អោយបានគ្រប់គ្រាន់តាមសំណូមពរដើម្បីបំពេញតាមសេចក្តីត្រូវការនៃសកម្មភាពលូតលាស់របស់មាន់ ។

គ/ ការផ្តល់ចំណី, ការថែរក្សា និងការធ្វើវ៉ាក់សាំង :

ការធ្វើវ៉ាក់សាំងសំរាប់មាន់យកសាច់ :

| Weeks | ប្រភេទ | ផ្លូវផ្តល់ |
|---|---|---|
| ១ | ND + DB | ផឹក ឬ បន្តក់ |
| ២ | Gumboro | ផឹក ឬ បន្តក់ |
| ៣ | Coryza | ចាក់ DM / 0.៣ml |
| ៤ | Lasota | ផឹក |

ដើម្បីអោយមាន់សាច់មានការធំធាត់ឆាប់រហ័ស យើងត្រូវផ្តល់ចំណីអោយវាស៊ីថែមទៀតនៅពេលយប់ ត្រូវផ្តល់ពន្លឺអោយវា និងត្រូវរៀបចំយ៉ាងណាកុំអោយពន្លឺចាំងភ្នែកវា ដែលជាមូលហេតុបណ្តាលអោយញោចដល់ប្រព័ន្ធប្រសាទ បង្កើតជាបាតុភូតទឹក រឹជល់ និងស៊ីរោមគ្នា។ គប្បីកាត់ចំពុះអោយវា និងត្រូវគិតគូរអំពីសមាសធាតុដែលមាននៅក្នុងចំណីអោយវាស៊ីអោយបានគ្រប់គ្រាន់ ។ នៅពេលដែលមាន់ធ្វើចលនាបានតិចតួច វាក៏ធ្វើអោយមាន់ឆាប់ធំធាត់ដែរ ។ យើងត្រូវលៃយ៉ាងណាអំពីកន្លែង អោយវាឈរស៊ីចំណីអោយបានគ្រប់ក្បាលក្នុងពេលតែមួយ និងស្នូកទឹកត្រូវដាក់កន្លែងដែលងាយស្រួលដល់ការដើរទៅផឹក ។

# មេរៀនទី ១៣ ការចិញ្ចឹមមាន់គ្រៀវ

**១. ការចញ្ចឹមមាន់គ្រៀវ :** កូនមាន់នៅពេលវាមានអាយុចាប់ពី១ខែឡើង ទើបយើងឃើញ លក្ខណៈញី រំឈ្មោលរបស់វាច្បាស់លាស់។ ចំពោះមាន់ឈ្មោលដើម្បីអោយវាធំធាត់ឆាប់រហ័សនោះ គឺយើងធ្វើការភ្ញៀវវា និងបំប៉នចំណីវា។

ការគៀវ គឺជាមាន់ឈ្មោលដែលគេវះយកពងស្វាសវាចេញ ដើម្បីកុំអោយមានការរីកចំរើនផ្នែកភេទ ។ ក្រោយពីគ្រៀវវារួច សិរនិងចែរបស់វាស្លេករួញ បាត់បង់នូវភាពក្លាហាន មានភាពសាំមានខ្លាញ់ជាប់ស្បែកពោះ និងតាមសាច់ដុំកាន់តែច្រើនឡើងៗ សាច់មានរសជាតិ ហើយការធំធាត់ គឺមានកំរិតខ្ពស់ ។ ចំណែកមាន់ញីវិញគេមិននិយមភ្ញៀវទេ ព្រោះវាផ្តល់ផលតិចជាងកាទុកពង ។

**១.១ ប្រការគួរយល់ដឹងនៅមុនពេលគ្រៀវ :**

ក/យើងត្រូវជ្រើសរើសយកមាន់ដែលមានអាយុចាប់ពី៤ខែឡើងមកគៀវ ព្រោះមាន់មានអាយុ ៤ខែនេះ វាមានពងស្វាសតូចល្មម គឺប្រហែលប៉ុនកូនដៃ ដែលយើងអាចលូកទាញបានដោយ ស្រួលជាងមាន់ដែលមានអាយុ ៦ខែឡើង ព្រោះពងស្វាសរបស់វាកាន់តែធំឡើងមានការពិបាកលូត ទាញយកដោយវាស្វិតពេក ដែលបណ្តាលអោយមានការប៉ះពាល់ដល់សួត រំខួរឆ្អឹងខ្នង នាំអោយមាន គ្រោះថ្នាក់។ ម៉្យាងទៀត មាន់ដែលមានអាយុលើសពី ១.៥ឆ្នាំ ក៏មិនត្រូវយកមកគៀវដែរ ព្រោះ ពងស្វាសរបស់វាស្អិតជាប់ទៅនឹងសាច់ដុំ ពេលយើងទាញចេញនឹងបណ្តាលអោយដាច់សរសៃឈាម មាន់អាចស្លាប់ភ្លាម ។

មុននឹងគ្រូវយើងត្រូវបង្ខាំងមាន់ទុកនៅក្នុងទ្រុង ហើយត្រូវបង្អត់ ចំណី និងទឹកចំនួនពិ ២៤ ៣៦ម៉ោងយ៉ាងយូរ។ បើមិនធ្វើការបង្អត់ចំណីវាទេ នោះពោះវៀនអាចបាំងពងស្វាសពិបាករក ធ្វើអោយការគ្រៀវមានការពិបាក។ ការដែលយើងមិនអោយទឹកវាផឹក គឺដើម្បីការពារកុំអោយឈាមហូរច្រើនពេក នៅពេលដែលយើងគៀវ ។

- ❑ កាំបិតសំរាប់វះ
- ❑ ដង្កៀបចាប់ម្ជុលដេរ
- ❑ កាំបិតសំរាប់កាត់ខ្សែ និងពងស្វាសមាន់

- ❑ ស្លាបព្រាសំរាប់ទាញយកពងស្វាសមកក្រៅ

## ២. របៀបគ្រៀវមាន់ :

ការគ្រៀវមាន់មានបីរបៀបគឺ :

- ❑ ការគ្រៀវពីចំហៀង
- ❑ ការគៀវពីក្រោមគូទ
- ❑ ការគ្រៀវដោយបញ្ចូះអ័រម៉ូន

❑ ក/ របៀបគ្រៀវពីចហេ ហៀង :

❑ មុនដំបូងយើងត្រូវវះពីចំហៀ ហៀងខាងមុខ នៃឆ្អឹងជំនីចន្លោះទី ៦ ៧។ បន្ទាប់មកយើងប្រើ រឿងស្ថិតនៅជាប់នឹងជួរឆ្អឹងខ្នង។ ការយកពងស្វាសចេញ ដង្កៀបរុកទៅរកពងស្វាស ដែលមានពណ៌លឿងឥ គឺត្រូវប្រើដោយស្លាបព្រា ហើយពេលនោះយើង យើងត្រូវមានការប្រុងប្រយ័ត្ន ។

❑ ក្រោយពេលយកពងស្ល រស្វាសទាំងពីរចេញរួច យើងត្រូវដេរភ្ជាប់ឡើងវិញ និងត្រូវអោយមាន់ ហកមុខរបួសអាចជាឡើងវិញ នៅសប្តាហ៍ទី ១ រឺទី២ ។ ផឹកទឹក, ស៊ីចំណីជាធម្មតាឡើងវិញ។ ចំណែកមុខរបួសអាចជាឡើយវិញ នៅសប្តាហ៍ទី១ ឬទី២។

ខ/ របៀបគ្រៀវពីក្រោមគូទ:

❑ ត្រូវសម្អាតម្រាមដៃជាមួយអាល់កុល. ទឹកសាប៊ូ រឺទឹកអំបិល។ ត្រូវកាត់ក្រចកដៃអោយ ត្រូវសំអាតស្អាត រឺប្រសិនបើមានប្រេ រឺមានស្រោមដៃប្រើជាការល្អ។

❑ ត្រូវប្រើកាំបិតស្អាត ដោយស្ងោរ រឺជូតអាល់កុល។ ត្រូវវះទទឹងក្រោមគូទ ចំងាយប្រហែល១ - ២ សម រឺឯទំហំវះ គឺប្រ ទំហំវះ៖ គឺប្រហែល ១ធ្នាប់ដៃ (ល្មមលូកចង្អុលដៃ និងចង្អុលកណ្តាលចូល ) ។

❑ ត្រូវលូកដៃថ្នមៗតំរង់ទៅរកពងស្វាស ដែលស្ថិតនៅជាប់ជួរឆ្អឹងខ្នង ។ - ត្រូវលូ

ការទាញយកពងស្វាសចេញត្រូវប្រុងប្រយ័ត្ន ព្រោះកាលណាយើងលូកចូលទៅជ្រៅពេក អាចធ្វើអោយរបួសដល់សរីរាង្គផ្សេងៗដែលស្ថិតនៅខាងក្នុង ជាពិសេសគឺសួត និងតំរងនោម ។ការបេះយកពងស្វាសចេញ គឺត្រូវយកចេញអោយអស់ ជៀសវាងនូវការសេសសល់ដែលជាហេតុ បណ្ដាលអោយវានៅតែរកញីបន្តទៀត ។

- ពេលដែលយកពងស្វាសចេញហើយ ត្រូវនេះកន្លែងវះនោះឡើងវិញ ហើយត្រូវលាបធ្យូង លាយនឹងស្ករ ។
- ក្រោយរយៈពេលពី ១២-២៤ម៉ោង ទើបអោយចំណីវាស៊ីធម្មតា។
- ការគ្រៀវនេះ៖ គឺច្រើនអនុវត្តនៅពេលព្រឹក គឺនៅម៉ោង ៧ ៩ រឺនៅពេលមួយត្រជាក់ដើម្បីជៀសវាង នូវការហូរឈាមច្រើន ហើយការគ្រៀវនេះគួរតែមានមនុស្សពីរនាក់ដើម្បីជួយស្ឦរ។

## គ/ របៀបភ្ញៀវដោយប្រើអ័រម៉ូន :

ការគ្រៀវរបៀបនេះ គេពុំចាំបាច់ធ្វើការវះកាត់ទេ គឺគេយកគ្រាប់អ័រម៉ូន (Hormone) ដែលមន្ទីរពិសោធន៍បានធ្វើ មានទំហំប៉ុនថ្នដែកកេះ៖ មកចាក់បញ្ចូលនៅនឹងសេលើក្បាលមាន់ គឺជាការស្រេច ។ ការធ្វើរបៀបនេះ មានការងាយស្រួលជាងការគ្រៀវដោយវះកាត់ ព្រោះធ្វើអោយមាន់ គ្មានការឈឺចាប់ រឺមាន់អន់ ព្រមទាំងគ្មានគ្រោះថ្នាក់គៀតផង។

ប៉ុន្តែតាមបទបញ្ញតិរបស់បសុពេទ្យ គឺហាមមិនអោយសំឡាប់វាក្នុងរយៈពេលពី ១-៣ខែ ក្រោយពេលបញ្ចុះអ័រម៉ូន ព្រោះបើយើងយកសាច់ទៅធ្វើម្ហូបអាហារ វាបណ្ដាលអោយប៉ះពាល់ដល់ សុខភាពមនុស្ស ។

## II. ចំណីសំរាប់មាន់គ្រៀវ :

មាន់ដែលយើងចង់ភ្ញៀវ ត្រូវជ្រើសរើសនៅពេលវាមានអាយុចាប់ពី ១ខែឡើងទៅ។ យើងត្រូវចាប់បំបែកចេញជាហ្វូងញី រឺឈ្មោល។ ចំពោះមាន់ឈ្មោលយើងត្រូវចិញ្ចឹមបំប៉នដើម្បីអោយវាឆាប់ធំធាត់រហ័សយកទៅគៀវ។ កូនមាន់ដែលមានអាយុពី ១-២ខែ ត្រូវផ្ដល់ចំណីដែលមានប្រូតេអ៊ុនពី ១៨-១៩% និងនៅពេលវាមានអាយុលើសពី ២ខែ ត្រូវផ្ដល់ចំណីដែលមានប្រូតេអ៊ីនទាបជាងនេះ ។

ចំណីសំរាប់មាន់គ្រៀវត្រូវលាយនឹងវត្ថុធាតុដើមដូចជា :

- ពោតលាយចុងអង្ករ ១៥%
- កន្ទក់លេខ ១ ៤៥%
- សណ្តែកសៀង ៣៥%
- ស្លឹកកកន្ធំថេត ៣%

មាន់គ្រៀវរួច ចាប់ពី ៤ - ៦ខែ មាន់ពេញសាច់បរិភោគបាន សាច់មានរសជាតិឆ្ងាញ់ ផុយនិងសំបូរទៅដោយខ្លាញ់ ។

# មេរៀនទី ១៤ ករណីដែលត្រូវយល់ដឹងក្នុងការចិញ្ចឹមមាន់

## ១. ការងារជាប្រចាំនៅក្នុងទ្រុងមាន់ :

- ❑ ត្រូវធ្វើការត្រួតពិនិត្យជារៀងរាល់ថ្ងៃ អំពីស្លឹកទឹក និងស្នូកចំណីតើគ្រប់គ្រាន់ដែររឺទេ ។
- ❑ ត្រូវលាងសំអាតស្លុកទឹក និងស្នូកចំណីជាប្រចាំដើម្បីកុំអោយធំក្លិន ។
- ❑ ផ្តល់ចំណីអោយវាស៊ីអោយបានគ្រប់គ្រាន់ គឺពី ៣-៤ដង /ថ្ងៃ ។
- ❑ ឧស្សាហ៍ប្រមូលស៊ុតអោយបានច្រើនដង (២-៣ដង/ថ្ងៃ) ។
- ❑ មាន់ឈឺ រឺងាប់ត្រូវយកចេញ ដើម្បីកុំអោយឆ្លងទៅមាន់ផ្សេងទៀត ។
- ❑ ចំពោះមាន់ដែលចិញ្ចឹមនៅក្នុងទ្រុងកា (Cage) ពេលប្រមូលលាមករួច ត្រូវរោយកំបោរតិចៗពីខាងក្រោមទ្រុង ។

## ២. ដើម្បីជៀសវាងនូវកត្តាស្រ្តេស (Stress):

- ❑ មិនត្រូវផ្លាស់ប្តូរទំលាប់ប្រចាំថ្ងៃភ្លាមៗទេ។
- ❑ ត្រូវមានកម្មវិធីផ្តល់ទឹក និងចំណីអោយច្បាស់លាស់ ។
- ❑ ត្រូវផ្តល់ស្នូកទឹក-ស្នូកចំណី និងសំបុកពងអោយបានគ្រប់គ្រាន់។
- ❑ ទ្រុងត្រូវរៀបចំ អោយមានខ្យល់ចេញចូលល្អ ។
- ❑ ត្រូវផ្តល់ពន្លឺអោយបានគ្រប់គ្រាន់ ។ (15-164/day!
- ❑ មិនត្រូវស្រែកឡូឡាធ្វើអោយមាន់ផ្អើល ។

## ៣. បញ្ហាស៊ុតតូចខុសពីធម្មតា :

- ❑ ការខ្វះប្រូតេអ៊ីននៅក្នុងចំណី
- ❑ ការខ្វះវិតាមីន E នៅក្នុងចំណី
- ❑ តំណាក់កាល មេមាន់ពងដំបូង

## ៤. ការចឹកស៊ីរោមគ្នា :

គឺបណ្តាលមកពីមូលហេតុផ្សេងៗដូចជា :

- ❑ ទ្រុងចិញ្ចឹម មានលក្ខណ:ចង្អៀតពេក ( មាន់លើសចំនួន ) ។
- ❑ ខ្វះប្រូតេអ៊ីននៅក្នុងចំណី ។

- ❑ ការប្រើថ្នាំក្រហមទៅលើសត្វ ។
- ❑ ការខ្វះអំបិលនៅក្នុងចំណី ។
- ❑ ការខ្វះសារធាតុខនិជ និងបន្លែស្រស់ ។

## ៥. ការទន់ជើង និងវៀចឆ្អឹងទ្រូង :

គឺបណ្តាលមកពី :

- ❑ ការខ្វះវិតាមីន D ។

ការខ្វះសារធាតុ Ca និង P ។

## ៦. សំបកស៊ុតទន់ :

គឺបណ្តាលមកពីខ្វះជាតិ Ca, P និង Mn ។

## ៧. លាមករាគពណ៌លឿង :

គឺបណ្តាលមកពីលើសប្រូតេអ៊ីន និងអំបិលច្រើនហួស ។

## ៨. តែមិនរលាយ :

គឺបណ្តាលមកពីខ្វះជាតិសំណើម ដែលមានជាតិអាស៊ីតសំរាប់រំលាយអាហារ ។ ការព្យាបាលគឺយើងត្រូវបញ្ចូលទុយោអោយដល់តែ រួចបញ្ចូលទឹកក្តៅឧណ្ហៗអោយពេញតែនិងចាប់មាន់យូរជើង ឡើងលើ សំយុងក្បាលចុះក្រោម ហើយច្របាច់ចំណីទំលាក់ចេញ។

## ៩. ការថែថានៅរដូវក្តៅ :

នៅរដូវក្តៅធាតុអាកាសក្តៅខ្លាំង ធ្វើអោយការស៊ីរបស់សត្វមានការថយចុះ។

ដូច្នេះដើម្បី រក្សាគុណភាពសំបកស៊ុត យើងត្រូវបន្ថែមសំបកខ្យង រឺសំបកគ្រែងអោយវាស៊ីនៅក្នុងស្នូកផ្សេង។

១០/ការព្យាបាល :

- ❑ ប្រើ Piperazine : 2,5-3Kg / លាយទៅក្នុងចំណី១តោន។ ដោយអោយវាស៊ីរយៈពេល ២ថ្ងៃជាប់គ្នា។ រឺក៏លាយទឹកក្នុងកំរិត : ២-៤ក្រ/៤លីត្រទឹក ដោយអោយវាផឹករយៈពេល២ថ្ងៃជាប់គ្នា ។
- ❑ ប្រើ Phenothiazine: 0,5 - 1,5g/1Kgទំងន់ ។

# មេរៀនទី ១៥ ជំងឺមួយចំនួនដែលតែងតែជួបនៅលើសត្វមាន់

## ១. ជំងឺញូកាស : (Pestis avium - Newcastle disease)

ជំងឺញូកាសគឺជាជំងឺឆ្លង ដែលបង្កឡើងដោយវីរុស Tortor Furens ។ ក្នុងចំណោមជំងឺដ៏សាហាវទាំងបួនរបស់មាន់ ជំងឺញូកាសជាជំងឺមួយដែលឆ្លងរាលដាលយ៉ាងរហ័ស និងបង្កអោយស្លាប់ យ៉ាងសាហាវដល់ហ្វូងមាន់។ ការចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម និងពាក់កណ្តាលឧស្សាហកម្ម ជំងឺ ញូកាសច្រើនបូកផ្សំនឹងជំងឺផ្សេងទៀត ដូចជាជំងឺ C.R.D 1 Chronic Raspiratory Dise ជំងឺនេះអាចឆ្លងរាលដាលយ៉ាងរហ័សពីតំបន់មួយ ទៅតំបន់មួយទៀត តាមរយៈការដឹកជញ្ជូនមាន់ចេញចូល ឆ្លងតាមខ្យល់ តាមវត្ថុផ្សេងៗ រឺតាមមនុស្សដែលចេញចូលក្នុងទ្រុងចិញ្ចឹម ។ ជំងឺ នេះច្រើនកើតនៅរដូវរំហើយដែលមានអាកាសធាតុត្រជាក់ស្ងួត ។

### ក/ រោគសញ្ញា:

រោគសញ្ញារួមជាដំបូងមាន : ចំនួនមាន់ក្នុងហ្វូងមានសភាពខ្សោយ សំកុក ធ្លាក់ស្លាប ចឹកស៊ីបន្តិចបន្តួច រឺក៏មិនស៊ី និងផឹកទឹកច្រើន។ កំដៅឡើងដល់ ៤២-៤៣ °C ចំពោះមាន់ឈ្មោលឈប់រងាវ និងមេមាន់ញីថយពង រួចឈប់ពងតែម្តង ។

- ពិបាកក្នុងការដកដង្ហើម ហាមាត់ដូចស្លាប និងមានហៀរសំបោរ។ មាត់ហៀរទឹករំអិល ហើយនៅក្នុងតែមានទឹកពេញ។
- លាមករាគមានពណ៌ខៀវ ហើយប្រែបន្តិចម្តងៗទៅជាពណ៌សដូចកំបោរ និងមានឆ្នូតឈាមមានក្លិនឆ្អាប ។
- មាន់ឈរជើងមិននឹង ញ័រជើង កន្ត្រាក់ខ្លួន និងរមូលក ។
- ពងរាងមិនធម្មតា ( សំបកទន់ រឺក៏អត់សំបក និងស៊ុតសរាវ ) ។

កូនមាន់ និងមាន់ជំទង់ងាប់ច្រើនជាងមាន់ធំ ។

### ខ/ ការការពារ និងព្យាបាល :

ជំងឺញូកាសបង្កឡើងដោយវីរុស ដូចនេះយើងពុំទាន់មានថ្នាំព្យាបាលទេ។ ប៉ុន្តែតាមបទពិសោធន៍របស់អ្នកចិញ្ចឹមមាន់មួយចំនួន កាលណាកើតជំងឺនេះ គេអោយមាន់ផឹកស្រាត្រាំក្លែប (៣-៤cc /ក្បាល ) រឺក៏អោយផឹកទឹកខ្ទឹមសបុកលាយជាមួយខ្ទី។

ការព្យាបាលតាមបែបខាងលើនេះ ពុំសូវមានប្រសិទ្ធិភាពប៉ុន្មានទេ វិធីការពារល្អគឺត្រូវធ្វើវ៉ាក់សាំងការពារ ។

## ២. ជំងឺរាគឈាម : (Coccidiosis avium)

ជំងឺរាគឈាម បណ្តាលមកពីប៉ារ៉ាស៊ីតម៉្យាងរាងមូល (Eimeria tenella និង Eimera necatrix) តោងជាប់នៅក្នុងពោះវៀន ។ ជំងឺនេះបណ្តាលអោយមាន់ងាប់ពី ៥០-៧០% ។ ការកើតមានជំងឺនេះ គឺអាស្រ័យទៅលើកំដៅ និងសំណើមនៃបរិយាកាសខាងក្តៅ។ ក្តៅហើយសំណើមខ្ពស់ ងាយនឹងកើតជំងឺនេះ។ មេរោគអាចឆ្លងតាមរយៈមនុស្ស កណ្តុរ សត្វចាបសត្វរុយ ។ល ។

### ក/ រោគ ពតសញ្ញា និងស្លាកស្នាម :

សត្វចុះស្គម មានរោមបះ ខ្នងកោង ក្បាលសំយ៉ុង ភ្នែកបិទ ញ័រញាក់ សត្វងាប់ច្រើនជាពិសេសមាន់ដែលមានអាយុតិចជាង ៣០ថ្ងៃ ។

- ❑ មាន់ចុះខ្សោយ មិនឃ្លានចំណី
- ❑ លាមករាគឈាម មានពណ៌ក្រហមព្រលែត និងតូទប្រឡាក់ទៅដោយឈាម ។ នៅពេលវះកាត់ដើម្បីពិនិត្យគេសង្កេតឃើញ
- ❑ មានចំនុចក្រហមៗនៅថ្នក់ពោះវៀន ហើយពោះវៀនរីកធំ និងមានឈាមកក ។
- ❑ នៅពោះវៀនតូច មានការហូរឈាមក្រោមភ្នាស។
- ❑ ជញ្ជាំងពោះវៀនហើម ។

### ខ/ ការការពារ និងការព្យាបាល :

មធ្យោបាយដែលប្រសើរបំផុត គឺកិច្ចការអនាម័យ ។ ប៉ុន្តែអនាម័យតែមួយមុខមិនអាចរាំងខ្ទប់ការឆ្លងរាលដាលនៃជំងឺនេះបានទេ គឺត្រូវតែចាក់ថ្នាំការពារទើបមានប្រសិទ្ធភាព។

#### វិធានការការពារជំងឺរាគឈាម :

- ❑ កុំចិញ្ចឹមកូនមាន់នៅក្នុងទ្រុង ដែលបានចិញ្ចឹមមាន់ចំរួចហើយ ។
- ❑ បើមានមាន់ឈឺ រឺសង្ស័យថាឈឺនៅក្នុងហ្វូង ត្រូវយកទៅដាក់កន្លែងផ្សេង ។
- ❑ គួរចិញ្ចឹមមាន់នៅលើទ្រនើ ខ្ពស់ពីដី ដើម្បីកុំអោយមាន់ស៊ីលាមកគ្នាវា។

បើចិញ្ចឹមនៅលើផ្ទៃរាប ត្រូវទ្រាប់អង្កាម រឺអាចម៍រណា។ ហើយបើឃើញសើម ត្រូវប្តូរចេញភ្លាម ។

- ព្យាបាល : 3g លាយក្នុងទឹកក្តៅមួយលីត្រ ( ក្រឡុកអោយសព្វ ) អោយមាន់ផឹកដោយសេរី ( រយៈពេលបីថ្ងៃជាប់គ្នា ) ។
- ប្រើថ្នាំ Sulfamerazine:
- ការពារ : លាយ 2-5g/Kg ចំណី អោយក្នុងរយៈពេល ៦ថ្ងៃជាប់គ្នា ។
- ព្យាបាល : លាយ 4-5g /Kg ចំណី អោយក្នុងរយៈពេល ៣-៥ថ្ងៃ ។

ប្រយ័ត្ន : កាលណាប្រើថ្នាំការពារ និងព្យាបាលជំងឺរាគឈាមនេះ ត្រូវបន្ថែមវីតាមីន A និងវីតាមីនក្រុម B ក្នុងចំណី រឺទឹកផឹកផង ដើម្បីជួយបង្កើនកំឡាំងអោយមាន់។

ចំពោះមាន់ពង រឺមាន់ពូជ ពុំគប្បីប្រើថ្នាប្រភេទ Sulfamide អូសបន្លាយពេលយូរពេកទេ ។

៣.ជំងឺរលាកផ្លូវបង្ហើម : (Chronic Respiratory Disease) (C.R.D)

ជំងឺរលាកផ្លូវដង្ហើម ជាជំងឺដែលកើតមានច្រើនបំផុតនៅលើ ហើយវាក៏ជាជំងឺដ៏សាហាវមួយនៅក្នុងចំណោមជំងឺសាហាវទាំងបួនរបស់មាន់។

ជំងឺនេះបណ្តាលមកពីមេរោគឈ្មោះ Mycoplasma Gallisepticum ។ ជំងឺនេះឆ្លងពី មាន់ឈឺទៅមាន់ជា រឺក៏ឆ្លងតាមសំភារៈប្រើប្រាស់ ។ល។ ពិសេសទៅទៀត ជំងឺនេះអាចចំលងទៅ តំណក្រោយតាមរយៈស៊ុតដែលមានជំងឺ ហើយក្នុងការអនុវត្តជាក់ស្តែង បញ្ហានេះអាចកើតមាន ច្រើនណាស់ ។

ក.រោគសញ្ញា :

ជំងឺនេះ ច្រើនកើតនៅលើមាន់ ដែលមានអាយុពី ៤-៦ អាទិត្យ និង នៅលើ មាន់ជិតពង (អាយុ ៤-៥ខែ ) ។ រោគសញ្ញាដែលយើងឃើញដំបូងគឺ មាន់មិនសូវស៊ីចំណី ហើយពិបាកក្នុងការដកដង្ហើម, គ្រលាស់ក្បាល និងស្លាប ដកដង្ហើមចេញចូល លឺសូរដូចកើតហឺត។ មាន់មួយចំនួនហៀរសំបោរ ហើមមុខ មាន់ពងមានការថយពង និងមាន់សាច់លែងធំ ចុះទំងន់ ។

ខ.ការការពារ:

- ស៊ុតដែល យើងយកទៅភ្ញាស់ ត្រូវយក់ទៅត្រាំនៅក្នុងសូលុយស្យុង ពពួកអង់ទីប៊ីយូទិចដូចជា : Tylosin, Tiamulin, Lincomycin, Gentamycin.

❑ យើងយកស៊ុតជ្រលក់ចូល ក្នុងសូលុយស្យុង ចំនួន១០នាទី មុននឹងយកទៅភ្ញាស់ ។ ប្រើពពួកអង់ទីប៊ីយូទិច លាយចូលទៅក្នុងចំណី រឺទឹកផឹក Tiamulin (Tiotilin) ។

កំរិតប្រើ : លាយទឹក 1cc / 1លីត្រទឹក

កូនមាន់ និងមាន់សាច់ ផឹក ៣ថ្ងៃ / ១អាទិត្យមានពង អោយផឹក ១អាទិត្យ / ១ខែ ជាប់គ្នា ។

❑ ប្រភេទ Premix ម្សៅ ១០% :

ប្រើលាយក្នុងចំណីកិរិត lg / 2Kg ចំណី រឺប្រើ Norfloxillin លាយ 2ml /-1 លីត្រទឹក៣ថ្ងៃជាប់គ្នា។

រឺប្រើ Tri-alplucine លាយ 1-24 / ១លីត្រទឹក ដោយអោយវាផឹក រយៈពេល ៣-៤ថ្ងៃជាប់គ្នា ។

« តែបើប្រើសំរាប់ព្យាបាលវិញ គឺប្រើក្នុងកំរិត២ដងនៃកំរិតដែលប្រើសំរាប់ការពារ ។

ប្រើសំរាប់ការពារ : លាយទឹកក្នុងកំរិត 1g /4 លីត្រទឹក ។

ប្រើលាយរនៅក្នុងចំណី : 1g / 3kg ចំណី ។

កូនមាន់. មាន់សាច់ ប្រើក្នុងរយៈពេល ៣-៤ ថ្ងៃ / ១អាទិត្យ ។

មាន់ពង : ប្រើក្នុងរយៈពេល ៥-៧ថ្ងៃ / ១ខែ។

- តែបើប្រើសំរាប់ព្យាបាលវិញគឺប្រើក្នុងកំរិត២ដងនៃកំរិតដែលប្រើសំរាប់ការពារ ។ Suanovil ប្រភេទម្សៅ ប្រើលាយក្នុងកំរិត 1g / 2,5 ទឹក/១ថ្ងៃ។ ដោយអោយ វាផឹក ៣-៤ថ្ងៃ / ១អាទិត្យ ។
- Espiravet : ប្រើការពារក្នុងកំរិត : លាយទឹក Icc / 1 លីត្រទឹក ។ ដោយប្រើរយៈពេល៣-៤ថ្ងៃ /១អាទិត្យ ។
- ការធ្វើវ៉ាក់សាំងការពារជំងឺ Mycoplasma Gallisepticum រឺ (C.R.D)
- លើកទី ១ : គឺនៅពេលវាអាយុបាន ៣អាទិត្យ ដោយប្រើក្នុងកំរិត ០.២cc/ ១ក្បាល ។
- លើកទី២ : គឺនៅមុនពេលដែលវាចាប់ផ្តើមពង ពី ២-៤អាទិត្យ ។ ដោយប្រើក្នុងកំរិត ០.៥cc/ ១ក្បាល ។

គ.ការព្យាបាល :

បណ្តាថ្នា ដែលមានប្រសិទ្ធភាព សំរាប់ព្យាបាលជំងឺ C.R.D មានដូចជា :

- Tiotilin ១0% ប្រើសំរាប់ចាក់ Ice / 4-6kg ទំងន់/ ១ថ្ងៃ។ ប្រើរយៈពេល ២-៣ថ្ងៃជាប់គ្នា។
- Tylan (50)ប្រើសំរាប់ចាក់ 1cc / 2-3 kg ទំងន់ ១ថ្ងៃ។ ប្រើរយៈពេល ២- ៣ថ្ងៃជាប់គ្នា ។
- Suanovil (5) ប្រើសំរាប់ចាក់ lee / 1 kg ទំងន់ ១ថ្ងៃ ។ ប្រើរយៈពេល ២-៣ថ្ងៃ

ថ្ងៃជាប់គ្នា ។

## ៤. ជំងឺហ្គែមបូល្ល (Infection Bursal Disease) ( I.B.D ) Gumboro Disease)

ជំងឺហ្គែមបូរជាជំងឺឆ្លង ច្រើនកើតនៅលើកូនមាន់ ដែលមានអាយុពី ៣-៦អាទិត្យ ។ បច្ចុប្បន្ន វាជាជំងឺដែល កំពុងរាលដាលខ្លាំងក្នុងវិស័យចិញ្ចឹមមាន់។ ជំងឺនេះកើតមុនដំបូង នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ ១៩៦២ នៅកសិដ្ឋានមួយក្នុងភូមិ Gumboro ។ ជំងឺនេះបង្កឡើងដោយសារវីរុសឈ្មោះ Birna viridae ដែលឆ្លងរាលដាលយ៉ាងរហ័ស តាមរយៈចំណី ទឹកជីក និងស្រមើល ហើយអាត្រា ងាប់អាចដល់ ៣0-៤0% ។ មេរោគនេះធ្វើអោយរលាកថង់ Fabricius ដែលជាអ្នកបង្កើតអង្គប្រ យុទ្ធ ប្រឆាំងនឹងជំងឺនានា ។

ជំងឺនេះច្រើនកើត នៅលើកូនមាន់ដែលមានអាយុ ពី៣-៤អាទិត្យ ។ វីរុសបង្កជំងឺ អាចចំលងតាមខោអាវ ស្បែកជើង ឧបករណ៍ប្រើប្រាស់ ចំណី និងអង្កាមក្រាលទ្រុង ។

### ក/រោគសញ្ញា :

មាន់សំកុក. មិនស៊ីចំណី, លាមករាគពណ៌ស បន្ទាប់មកមានពណ៌ត្នោត លាមកស្អិតជាប់ នៅជុំវិញគូទ.ពិបាកដើរ.បះរោម និងហេវហត់ ។ សាច់ទ្រូងនិងសាច់ភ្លៅ មានឆ្អូតឈាមពណ៌ ក្រហម។ ក្នុងកំរិតធ្ងន់យើងធ្វើការវះពិនិត្យ យើងឃើញ ស្រទាប់ស្បែក កន្លែងភ្ជាប់កោះ និងដើមកោះ មានចំនុចចេញឈាមតូចៗ ។ ចំណែកថង់ Fabricius ហើមធំ លើសធម្មតា។

### ខ/ការការពារ:

ត្រូវធ្វើអនាម័យទ្រុង.រោងចិញ្ចឹមអោយបាន ជាប្រចាំរៀងរាល់ខែ។ និងត្រូវចាក់ថ្នាំការពារតាមពេលកំណត់ ។

ជំងឺនេះគ្មានថ្នាំព្យាបាលទេ ប៉ុន្តែស្ថិតក្នុងការអនុវត្តជាក់ស្តែង គេអាចប្រើនូវបណ្តាថ្នាផ្សេងៗ សំរាប់បង្កើនកំលាំង និងឃាត់ឈាម ដោយប្រើក្នុងរយៈពេលពី ៣-៥ថ្ងៃដើម្បីបន្ថយនូវអាត្រាស្លាប់របស់មាន់ ។

- Glucoza 5%: 3-5ml/1ក្បា /1 ថ្ងៃ
- Vitamine C.500: 0,5-1ml/1ក្បា /1 ថ្ងៃ
- Vitamine B12 .1000 : ១អំពូល/១០ក្បា/១ថ្ងៃ
- B. complex : ១អំពូល/១០ក្បា/១ថ្ងៃ
- Vitamine K : ១អំពូល/១០ក្បា/១ថ្ងៃ

យើងត្រូវចាប់ផ្តើម ចាក់ភ្លាមចាប់តាំងពីថ្ងៃដំបូង ដែលមានរោគសញ្ញាបះរោម ។

## ៥. ជំងឺអុតមាន់ : (Fowl Pox) (Variola avium)

ជំងឺនេះកើតមានច្រើននៅលើមាន់ ដែលបណ្តាលមកពីមេរោគជាវីរុសឈ្មោះ Borreliota avium .

### ក/រោគសញ្ញា :

- គេឃើញមានដុំពក ពងខ្ទុះ និងក្រមរ នៅលើត្របកភ្នែក លើក្បាល និង់សិរ ។
- ភ្នែកឡើងប៉ោង។
- មានខ្ទុះនៅក្នុងរន្ធច្រមុះ ។
- ក្បាលហើម និងជូនកាលខ្វាក់ភ្នែក
- ក្នុងករណីធ្ងន់ធ្ងរ ដុំពក និងពងខ្ទុះអាចកើតនៅលើជើង រឺ ស្បែកនៃដងខ្លួន ។

### ខ/ ការការពារ :

ការធ្វើអនាម័យ គឺជាការសំខាន់ :

- ជួសអុតការពារ ទៅតាមកម្មវិធីដែលបានកំណត់ ។
- ត្រូវសំឡាប់ មូស និង រុយ ដែលជា ភ្នាក់ងារចំលងមេរោគ។

### គ/ការព្យាបាល :

គ្មានថ្នាំព្យាបាលទេ ព្រោះជំងឺនេះបង្កឡើងដោយ វីរុស ។ ប៉ុន្តែគេអាចប្រើពពួកអង់ទីប៊ីយូទិច ដូចជា : Chlotetrasol, Neodexin, Neocycline, Terramycine និង Ampicilline ។ដោយអោយវាផឹក រឺ ចាក់ក្នុងរយៈពេល ៣-៤ថ្ងៃជាប់គ្នា ។

ម៉្យាងទៀតយើងអាចប្រើ Bleu de Methylen 2% រឺ អាល់កុលអ៊ីយ៉ូត ១០% ដោយ លាបទៅលើក្រមរ អុតដែលកើតនៅលើមាន់។ តែបើក្រមរអុត កើតនៅលើមាត់ និងភ្នែកត្រូវប្រើ អាស៊ីតខ្សោយ ដូចជាអាស៊ីត បូរិច (boric 1-3%) រឺ ទឹកក្រូចឆ្មារ លាងដោយថ្នមៗ ។
ត្រូវបំពេញ វិតាមីន A.D.E ទៅក្នុងចំណី រឺ ទឹកផឹក ដើម្បីអោយក្រមរឆាប់ជា។

### ៦. ជំងឺអាសន្នរោគមាន់ : (Cholera avium, Fowl cholera)

ជំងឺនេះបណ្តាលមក ពីមេរោគឈ្មោះ Pasteurella multocida ហើយមិនសូវកើតមាន នៅលើមាន់ចិញ្ចឹម ជារបៀបឧស្សាហកម្មទេ ព្រោះមាន់ដែលគេចិញ្ចឹមជាឧស្សាហកម្ម គឺមានអនា ម័យល្អ ហើយតែងតែចាក់ថ្នាំការពារ នូវជំងឺផ្សេងៗ។

#### ក/រោគសញ្ញា:

មាន់សំកុក អត់ផឹក អត់ស៊ី ឈរមួយកន្លែង កំដៅក្នុងខ្លួនក្តៅខ្លាំង សិរជា នៅច្រមុះ និង ចំពុះមានចេញទឹករំអិល ពិបាកដកដង្ហើម ជុះច្រើន និងលាមក មានពណ៌លឿងព្រលែត ។ ក្នុងកំរិតធ្ងន់ធ្ងរ មាន់ងាប់ដោយគ្មានរោគសញ្ញាអ្វីទាំងអស់។ ជួនកាលកំពុងដើររកស៊ី ក៏ងាប់ ភ្លាម និងជួនកាលងាប់នៅក្នុងទ្រុងពេលយប់។ ជំងឺនេះកើតឡើងតែក្នុងរយៈពេល ពីរថ្ងៃ រឺក៏ជួន កាលប៉ុន្មានម៉ោងប៉ុណ្ណោះ ។ ការស្លាប់របស់មាន់មានលក្ខណៈឆាប់រហ័ស និងមិនឃើញមានរោគ សញ្ញា ។
នៅតាមជនបទ យើងឃើញមានជំងឺនេះច្រើនណាស់ ។

#### ខ/ការការពារ:

បញ្ហាអនាម័យ និង ការពារជំងឺ ដោយធ្វើវ៉ាក់សាំង គឺជាការចាំបាច់ណាស់ ។

#### គ/ការការពារ :

- ប្រើ Oxytetracycline គឺមានប្រសិទ្ធភាពខ្ពស់ : ប្រើ ៣០០-៦០០ក្រ/១តោនចំណី ។

- ប្រើ Streptomycine ចាក់សាច់ដុំ ១៥០-២០០ម.ក្រ/១គ.ក្រទំងន់មាន់ ។ ដោយប្រើរយៈពេល ៥-៦ថ្ងៃជាប់គ្នា ។

៣. ជំងឺព្រូនចង្កឹះ : (Ascaridiosis)

ក្នុងចំណោមព្រូនមូល ព្រូនចង្កឹះសំបូរជាងគេ និងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះមាន់ ។ វាធ្វើ អោយមាន់ចុះស្គម ថយកំលាំង ធ្វើអោយ របួសពោះវៀន. បញ្ចេញ ជាតិពុលដល់មាន់ និងបង្ក លក្ខណៈងាយស្រួល អោយជំងឺដទៃទៀតរាតត្បាត ។

ព្រូនចង្កឹះ Ascaridia Galli ជាប្រភេទព្រូនមូល ដែលមានទំហំធំជាងគេ។ វាមានប្រវែងពី ៣-១១ស.ម ។

ក/រោគសញ្ញា :

វាធ្វើអោយមាន់ខ្វះឈាម បាក់កំលាំង ចុះស្គម រោមបះ មិនសូវស៊ីចំណី ចិញ្ចឹមក្រធំ មេមាន់ថយពង ចុះទំងន់ និងរាគ។ ក្នុងករណីដែលមានព្រូនចង្កឹះច្រើន. អាចបណ្តាលអោយស្ទះពោះវៀន ស្ទះបំពង់នាំទឹកប្រមាត់ និងបណ្តាលអោយមាន់ងាប់ ។ ចំពោះកូនមាន់ដែលមានព្រូនច្រើន ងាយងាប់ណាស់ ចំនែកមាន់ធំក្រងាប់ជាង។

ពេលវះពិនិត្យឃើញមានព្រូនជាច្រើន នៅក្នុងពោះវៀន។ ពោះវៀនអាចមានដំបៅរលាកចេញឈាម ។

ខ/ការការពារ :

ត្រូវចិញ្ចឹមកូនមាន់ ដោយឡែកពីមាន់ធំ។ អនុវត្តការបញ្ចុះព្រូនតាមកាលកំណត់

ផ្តល់ចំណីអោយបានគ្រប់គ្រាន់ និងសំបូរជីវជាតិ ។

# មេរៀនទី ១៦ ការចិញ្ចឹមក្រួច

## ប្រភពដើម និងផលប្រយោជន៍ចំពោះសេដ្ឋកិច្ច

សត្វក្រួចត្រូវបានគេយកមកផ្សាំង និង ចិញ្ចឹមនៅក្នុងប្រទេសជប៉ុន ចាប់តាំងពីសតវត្ស ទី ១១ ។ និយាយរួម ការចិញ្ចឹមគ្រួចជាដំបូង មានប្រភពនៅទ្វីបអាស៊ី ដែលជាតំបន់មានអាកាសធាតុសមស្រប គឺក្តៅ ហើយសើម ។

លុះរហូតមកដល់សតវត្សទី ១៨ ទើបសត្វក្រួចត្រូវបានពង្រីកយ៉ាងទូលំទូលាយ ដើម្បីផលិតចេញជាសាច់ និងស៊ុត សំរាប់បំរើសេចក្តីត្រូវការហូបចុក នៅលើបណ្តាប្រទេសជាច្រើននៅលើពិភពលោក ។

បច្ចុប្បន្ននេះនៅក្នុងប្រទេសជប៉ុន ក្នុងមួយថ្ងៃៗគេផលិតបានស៊ុតចំនួន ១.៥លានគ្រាប់ និងប្រហែល ៨០០០០០កូនគ្រួចសាច់ ។ ចំណែកឯបណ្តាប្រទេសផ្សេងៗទៀត ផលិតបាននៅក្នុងកំរិត ទាបជាងប្រទេសជប៉ុន ។

ឧទា : បារាំងក្នុងមួយថ្ងៃៗ ផលិតបានជិត ៣០០០០០គ្រាប់ ។ ចំណែកប្រទេសអេហ្ស៊ីបវិញ ក្នុងមួយឆ្នាំៗ នាំចេញកូនក្រួចសាច់ចំនួន ៣លានក្បាល ។

សព្វថ្ងៃនេះ មានពូជគ្រួចផ្សេងៗគ្នាជាច្រើន ដូចជា :

- Bobwhile
- Singing quil
- Pharaoh, cotusnix, japonica ( ជប៉ុន ) និងនៅមានពូជក្រួចមួយចំនួន ផ្សេងទៀត របស់បារាំង .អាមេរិក. ហ្វីលីពីន និងម៉ាឡេស៊ី ។

ការចិញ្ចឹមគ្រួច គឺងាយស្រួលជាងការចិញ្ចឹមមាន់ឧស្សាហកម្ម (ពូជមាន់នាំចូល ) ។ គ្រួចញីមានមាឌធំ ពងច្រើន មានជំងឺតិចតួចជាងមាន់ សារធាតុចិញ្ចឹម(ស៊ុត ) ខ្ពស់ជាងមាន់។ ការចំណាយទុន គឺតិច ចំណែកការប្រមូលដើមមកវិញគឺរហ័សជាងមាន់ (មាន់ញីចិញ្ចឹម ៥ខែទើបពង និងពងជាបន្តបន្ទាប់ចំនួន ៤ខែទើបប្រមូលគ្រប់ទុន ដែលចំណាយដំបូង។ ប៉ុន្តែការចិញ្ចឹមគ្រួចវិញ តែ៤០ ថ្ងៃគឺវាពង ហើយការពងវិញតែ ១៥-២០ថ្ងៃ គឺគ្រប់ទុនដែលយើងបានចំណាយដំបូង ។

## ការចិញ្ចឹមគ្រូច

I.ការចិញ្ចឹមគ្រូចពង : គ្រូចញីមួយក្បាលអាចពង ពី៣០០-៣៦០ស៊ុតក្នុងមួយឆ្នាំ បាយ ដើម្បីផលិត សជាច្រើននៅលើគីពី និងមាន គ្រូចញីខ្លះទៀតអាចពងបានលើស ពី៤០០ ស៊ុតក្នុងមួយឆ្នាំ។ សមាមាត្រនៃការពងជាមធ្យម ៧៥-៩០% និង ទំងន់របស់ស៊ុតគឺ ពី១២-១៦ ក្រាម។ កូនក្រូចចិញ្ចឹមក្នុងរយៈពេល ៤០ថ្ងៃគឺវាចាប់ផ្តើម ពង ហើយនៅពេលដែលវាចាប់ផ្តើម ទំងន់របស់គ្រូចញីជាមធ្យមគឺ ១១០ក្រ ។ លុះដល់ពេលវាអាយុ បាន ៦ខែ ទំងន់របស់វាឡើងដល់ ១៥០-១៧០ក្រាម និងមានប្រភេទខ្លះទៀត ទំងន់របស់វារហូត ទៅដល់ ២៥០ក្រាម (ពូជគ្រូចបារាំង) ប៉ុន្តែសមាមាត្រ នៃការផ្តល់ស៊ុតរបស់វា គឺទាបជាង។ សមាមាត្រនៃការផ្តល់ស៊ុតឡើងខ្ពស់បំផុត គឺនៅឆ្នាំដំបូង លុះដល់ឆ្នាំទី២ សមាមាត្រនៃ ការផ្តល់ស៊ុតថយចុះ នៅត្រឹម ៦០%។ រយៈពេលដែលគ្រូចញីផ្តល់ស៊ុតជាមធ្យម គឺ១៤-១៨ខែ បន្ទាប់មកយើងត្រូវជំរុះវាចោល ។

## ការជ្រើសរើសពូជ និងការថែរក្សាកូនក្រូច

កូនគ្រូចដែលទើបនឹងញាស់ មានទំងន់ពី ៦-១០ក្រាម មានរោមពណ៌លឿងលាយបង្គង់ពណ៌ខ្មៅ និង កូនគ្រូចមានសុខភាពល្អ ហើយរហ័សជាងកូនមាន់។ ក្រោយពេលកូនគ្រូចទើបញាស់ យើងត្រូវជំរុះចោល នូវកូនដែលមានលក្ខណៈមិនល្អចេញដូចជា : ខ្វិនជើង ចំហផ្សិត មានសភាព ខ្សោយ និងរញីរញ៉ូវ ក៏ត្រូវយកវាចេញដែរ។ ប្រសិនបើយើងដឹកជញ្ជូនកូនគ្រូចទៅកន្លែងឆ្ងាយ ត្រូវ ដាក់វានៅក្នុងចុង រីឡាំងក្រដាស ដែលមានចោះប្រហោងតូចៗ និងគ្របអោយជិតការពារកុំអោយ
ត្រូវភ្លៀង និងខ្យល់ ។ A/ការថែរក្សាកូនគ្រូចដែលមានអាយុពី។១-២៥ថ្ងៃ

### ១.សីតុណ្ហភាពកំដៅ :

យើងត្រូវដាក់កូនគ្រូចចូលទៅរួ ក្តៅជាមុនក្នុង កំដៅភ្លាម។ មុនពេលដាក់កូនគ្រូចចូលទ្រុងកំដៅ យើងត្រូវដាក់ចង្កៀងកំដៅអោយក្តៅជាក្រោយពេលដែលបានធ្វើការជ្រើសរើសរួចហើយរយៈពេលពី ១៥-៣០នាទី ។

សីតុណ្ហភាពនៅក្នុងទ្រុងកំដៅ ៣ថ្ងៃដំបូងគឺ 35°C ។ ក្រោយមកយើងត្រូវបន្ថយ បន្តិច ម្តងៗ មកនៅត្រឹម 28°C ។ លុះចូលមកដល់អាទិត្យទី២ គឺនៅត្រឹម 25°C ។ ចូលមកអាទិត្យទី៣ និង

ទី៤ យើងពុំចាំបាច់កំដៅទៀតទេ ប្រសិនបើសីតុណ្ហភាពក្នុងរោងចិញ្ចឹមមិននៅក្រោម 20°C ។ ពេលដែលយើងផ្តល់កំដៅ ត្រូវដាក់ចង្កៀងជាប្រចាំទាំងយប់ទាំងថ្ងៃ ពីព្រោះកូនគ្រួចពុំអាចទ្រាំទ្រ គ្រួចត្រូវស្លាប់ ។នឹងភាពត្រជាក់បានទេ។ ប្រសិនបើការផ្តល់កំដៅអោយវាពុំគ្រប់គ្រាន់ទេ នោះ អាចធ្វើអោយកូនក្នុងរយៈពេលផ្តល់កំដៅអោយកូនក្រួច យើងចាំបាច់ត្រូវតាមដាន និងសង្កេត មើលប្រសិនបើកូនគ្រួចផ្តុំចូលគ្នានៅកន្លែងជ្រុងមួយនៃទ្រុង រឺ ក្បែរកន្លែងដាក់ចង្កៀងកំដៅ នោះ បង្ហាញអោយឃើញថា វាត្រជាក់ខ្លះកំដៅ ។

ប្រសិនបើយើងកំដៅកូនគ្រួចដោយអគ្គិសនី នោះត្រូវប្រើអំពូលភ្លើងមូល 75W ប្រើសំ រ៉ាប់១ ទ្រុងកំដៅ ដែលមានផ្ទៃ 0,5m² ។ បញ្ហាចំបងនៃសីតុណ្ហភាពក្នុងទ្រុងកំដៅ គឺយើងត្រូវធ្វើ ដោយ របៀបលើកឡើង រឺទំលាក់ចុះអំពូលភ្លើង អាស្រ័យដោយលក្ខខ័ណ្ឌសីតុណ្ហភាពនៃមេឃខាង ក្រៅ។ ប្រសិនបើមេឃភ្លៀងត្រជាក់នៅពេលយប់នោះ "ត្រូវតែទំលាក់អំពូលអោយទាប ប៉ុន្តែនៅ ពេលដែលមេឃក្តៅនៅពេលថ្ងៃនោះ យើងត្រូវតែលើកអំពូលភ្លើងឡើងអោយខ្ពស់។ ក្រៅពីអំពូ ល ភ្លើងអគ្គិសនី យើងអាចប្រើចង្កៀងប្រេងដើម្បីកំដៅ ។

## ២.ទ្រុងកំដៅ និងទ្រុងចិញ្ចឹម :

### ក/ទ្រុងកំដៅ :

- ប្រវែងទទឹង ១ម.បណ្តោយ ១.៥ម និងកំពស់ 0.៥ម ។
- បាតទ្រុងកំដៅធ្វើអំពីលួសសំណាញ់ ដែលមានទំហំ ១ស.ម ។ជុំវិញទ្រុង យើងអាច ប្រើបន្ទះរនូតឈើ រឺ ឬស្សីជុំដែកគោល ដែលមានចន្លោះ ១ស.ម។ ប្រសិនបើប្រើលួ សសំណាញ់ ដូចបាតខាងក្រោមកាន់តែល្អ ។
- ពេលកំដៅត្រូវទ្រាប់ក្រដាសនៅបាតទ្រុង រយៈពេល ២-៣ថ្ងៃដំបូង ដើម្បីកុំអោយកូន គ្រួច ផុងជើង និងការពារទប់ទល់នឹងខ្យល់បក់។ នៅជុំវិញទ្រុងកំដៅ ត្រូវតែបាំងក្រ ដាស់ រឺបាវនីឡុងគ្រប អោយជិត ។
- ទ្រុងត្រូវមានជើងហើយមានកំពស់ពីផ្ទៃដី0.៤-0.៥មដើម្បីការពារពីសត្វកណ្តុរ ។



ខ/ទ្រុងចិញ្ចឹម : លក្ខណៈពិសេសរបស់កូនក្រួច គឺធម្មតាវាចេះហើរ និងលោត។ អាស្រ័យ ហេតុនេះ ទ្រុងចិញ្ចឹមគ្រួចត្រូវតែមានលក្ខណៈសមស្រប ជាមួយសរីរៈរបស់កូនគ្រួច ។ -

ទ្រុងចិញ្ចឹមកូនគ្រួចដែលសមស្របបច្ចុប្បន្ននេះ គឺទ្រូងដែលមានថ្នាក់ៗ។ សំណូមពររបស់ទ្រុងចិញ្ចឹម ផ្នែកបាតខាងក្រោមត្រូវធ្វើអំពីលួសសំណាញ់ ដែលមានផ្ទៃក្រឡា ១ស.ម ដូចជាទ្រុងកំដៅដែរ និង គំរបទ្រុងចិញ្ចឹមធ្វើអំពីសំណាញ់នីឡុង។ ប្រវែងចន្លោះ ពីគំរបទ្រុងទៅនឹងបាតប្រហែល ២០-២៥ស.ម ។

ទ្រុងចិញ្ចឹមគ្រួច យើងអាចធ្វើពី ៣-៥ថ្នាក់។ កូនក្រួចដែលទើបញាស់ យើងដាក់ចិញ្ចឹមនៅទ្រុងខាងក្រោមជិតប្រភពកំដៅ ដើម្បីអោយបានទទួលកំដៅ ចំណែកកូនក្រួចធំយើងដាក់ចិញ្ចឹមនៅជាន់ខាងលើ។ ថ្នាក់និមួយៗ យើងអាចធ្វើជាចន្លោះតូចៗ ដែលចន្លោះនិមួយៗមានទំហំ 30cm x 30cm.កូនក្រួចដែលមានអាយុ ១អាទិត្យ យើងអាចដាក់បានចំនួន ៣០ក្បាលកូនគ្រួចដែលមាន អាយុ យុ ២អាទិត្យយើងអាចដាក់បាន ២០ក្បាល កូនក្រួចដែលមានអាយុ ៣អាទិត្យឡើងយើងអាច ដាក់បានចំនួន ១៥ក្បាល។ គឺក្នុង ១ម៉ែត្រក្រឡាយើងអាចដាក់បាន ២៥០

ក្បាល/អាយុ១អាទិត្យ, ១៧០ក្បាល/អាយុ២អាទិត្យ និង ១២៥ក្បាល/អាយុ៣អាទិត្យឡើង។ ទ្រុងចិញ្ចឹមកូនគ្រួច យើងអាចធ្វើពីអំពីឈើ ឫស្សី រឺដែក ។



៣.ការផ្តល់ចំណីសំរាប់កូនគ្រួចអាយុពី ១-២៥ថ្ងៃ :

ចាប់ពីអាយុ ១-២៥ថ្ងៃ យើងត្រូវផ្តល់ចំនី ដែលមានជីវជាតិគ្រប់គ្រាន់ទៅអោយវា។ សារ ធាតុចំណីដែលផ្តល់ទៅអោយកូនក្រួច គឺខ្ពស់ជាងកូនមាន់។ ប្រសិនបើកូនមាន់ត្រូវការសមាមាត្រ ក្នុងចំនីដែលមានប្រូតេអ៊ីន ពី២០-២១% នោះកូនគ្រួចត្រូវការ ពី២៦-២៨%។ ពេលយើងចិញ្ចឹម កូនគ្រួច យើងអាចប្រើចំណីដូចកូនមាន់ក៏បានដែរ តែចាំបាច់ត្រូវបន្ថែមម្សៅត្រីពី ៤-៥% និងសណ្តែកសៀង ពី៤-៥%ដើម្បី

បង្គ្រប់ ។

សមាសភាពចំណីផ្តល់ឲ្យកូនក្រួចមានប្រូតេអ៊ីន ពី២៦- ២៨%

| ល.រ | សមាសភាពចំណីផ្សំ | រូបមន្តទី១ (១០ គក្រ) | រូបមន្តទី២ ( ១០ គក្រ ) |
|---|---|---|---|
| ១ | ពោតក្រហម | ៣. ០ គក្រ | ១. ០ គក្រ |
| ២ | ចុងអង្ករ | ១. ០ គក្រ | ៣. ០ គក្រ |
| ៣ | កន្ទក់ម៉ត់ | ១. ០ គក្រ | ១. ០ គក្រ |
| ៤ | ម្សៅត្រី | ២.០ គក្រ | ២.០ គក្រ |
| ៥ | ម្សៅសណ្តែកខៀវ | ១. ០ គក្រ | ១. ០ គក្រ |
| ៦ | ម្សៅសណ្តែកសៀង | ១.៧ គក្រ | ១.៧ គក្រ |
| ៧ | ម្សៅខ្យល ឬឆ្អឹង | ០. ២ គក្រ | ០. ២ គក្រ |
| ៨ | premix រ៉ែ | ០.០៥ គក្រ | ០.០៥ គក្រ |
| ៩ | premix វីតាមីន | ០.០៥ គក្រ | ០.០៥ គក្រ |
| ១០ | Vitamine A. D. E (១កញ្ចប់១០g ) | ៤ កញ្ចប់ | ៦ កញ្ចប់ |

- រូបមន្តទី១ : ប្រើសំរាប់តំបន់ដែលសំបូរពោត និងមានតំលៃថោកជាងចុងអង្ករ រឺកន្លក់។
- រូបមន្តទី២ : ប្រើសំរាប់តំបន់ដែលសំបូរចុងអង្ករ និងកន្ទក់ ដែលមានតំលៃថោកជាងពោត។ ពេលយើងប្រើរូបមន្តទី ២នេះត្រូវបំពេញបន្ថែមនូវ Vitamine A ពីព្រោះនៅក្នុងចុង អង្ករមាន Vitamine A តិចជាងនៅក្នុងពោត។ ការខ្វះ Vitamine, A នឹងធ្វើអោយគ្រូចមាន, ការធំធាត់យឺត ជ្រុះរោម ខ្វាក់ភ្នែក និងពងតិច ។

B/ការជ្រើសរើស, និងការថែរក្សាគ្រូចពង :

ពេលកូនក្រួចមានអាយុលើសពី ២០ថ្ងៃ យើងអាចធ្វើការបែងចែកអំពីកូនឈ្មោល រឺ កូនញី បាន ឆ្លងតាមពណ៌សំបុររបស់វា។ ពេលយើងចិញ្ចឹមវាបានអាយុ ២៥ថ្ងៃនោះត្រូវធ្វើការជ្រើសរើស ដើម្បីទុកធ្វើជាក្រួចសាច់ រឺកូនល្អដើម្បីទុកធ្វើពូជ។

១.ការជ្រើសរើសក្រួចឈ្មោល : យើងត្រូវជ្រើសរើសបណ្តាកូនដែលមានរាងស្រាវ .ស្មារីកមាន សុខភាពល្អ ភ្លៀវភ្លា និងរោមទ្រូងមានពណ៌លឿង។ តាមធម្មតា ក្រួច មានទំងន់ ស្រាលជាងក្រួចញី និង ជាមធ្យមនៅពេលអាយុបាន ២០ថ្ងៃ កូនក្រួច មានទំងន់ពី ១០០- ១៤០ក្រាម ។

២.ការជ្រើសរើសក្រួចញី : ត្រូវជ្រើសរើសបណ្តាកូនដែលមានក្បាលសមសួន កតូចល្មមកែវភ្នែករហ័សរហួន មានរោមភ្លឺរលោង រោមទ្រូងមានបង្កង់ សលាយខ្មៅរហូតទៅដល់ពោះ តូច មានពណ៌ផ្កាឈូក រន្ធគូថទូលាយ ឆ្អឹងត្រគាករីក និងទំងន់ជាមធ្យមពេលមានអាយុ ២០ថ្ងៃគឺ ១២០-១៦០ ក្រាម ។

៣.ការបង្កាត់ : តាមធម្មតាយើងបង្កាត់បា (♂) ក្មេង ជាមួយ (♀) ក្មេង ។ ប៉ុន្តែ តាមបទពិសោធន៍របស់បណ្តាអ្នកចិញ្ចឹមនោះ កូន ចិញ្ចឹមរហូតទៅដល់ ៣-៤ ខែទើបអោយធ្វើការ បង្កាត់ ។ ( សមាមាត្រនៃការភ្ញាស់គឺ ពី ៧០-៨០% ) និងសមាមាត្រ:

-♂2:♀5, ♂3:♀10, ♂5:♀15 រឺ ♂5:♀20

## ៤ សមាសភាពចំណីសម្រាប់ក្រួចមានកម្រិត Protein ពី២៤-២៦%

| ល.រ | សមាសភាពចំណីផ្សំ | រូបមន្តទី១ (១០ គក្រ) | រូបមន្តទី២ ( ១០ គក្រ ) |
|---|---|---|---|
| ១ | ពោតក្រហម | ២. ៥ គក្រ | ៣. ០ គក្រ |
| ២ | ចុងអង្ករ | ២. ០ គក្រ | ១. ៥ គក្រ |
| ៣ | កន្ទក់ម៉ត់ | ២. ៣ គក្រ | ២. ៩ គក្រ |
| ៤ | ម្សៅត្រី | ១.0 គក្រ | ១.0 គក្រ |
| ៥ | ម្សៅសណ្តែកខៀវ | ១.៧ គក្រ | ១.   គក្រ |
| ៦ | ម្សៅសណ្តែកសៀង | 0.៣ គក្រ | 0.៣ គក្រ |
| ៧ | ម្សៅខ្យល ឬឆ្អឹង | 0. ១ គក្រ | 0. ២ គក្រ |
| ៨ | premix រ៉ែ | 0.0៥ គក្រ | 0.0៥ គក្រ |
| ៩ | premix វីតាមីន | 0.0៥ គក្រ | 0.0៥ គក្រ |
| ១0 | Vitamine A. D. E (១កញ្ចប់១0g ) | ៤ កញ្ចប់ | ៤ កញ្ចប់ |

ការគណនា ទៅតាមអាទិត្យនីមួយៗដូចខាងក្រោម:

- ទើបញាស់ដំបូង មានទំងន់ ពី ៦ - ៨ក្រាម
- អាយុ ១អាទិត្យមានទំងន់ ពី ១៧ - ២៥ក្រាម
- អាយុ ២អាទិត្យមានទំងន់ ពី ៣០ - ៤០ក្រាម
- អាយុ ៣អាទិត្យមានទំងន់ ពី ៤៨ - ៦៥ក្រាម
- អាយុ ៤អាទិត្យមានទំងន់ ពី ៧៥ - ៩០ក្រាម
- អាយុ ៥អាទិត្យមានទំងន់ ពី ៩០ - ១០០ក្រាម
- អាយុ ៦អាទិត្យមានទំងន់ ពី ១១០ - ១២០ក្រាម

អាស្រ័យដោយមានតារាងខាងលើដូច្នេះ យើងអាចធ្វើការប្រៀបធៀបជាមួយនឹងគ្រួចដែលយើងចិញ្ចឹម ដើម្បីអោយដឹងតើការចិញ្ចឹមរបស់យើងល្អ រឺអាក្រក់។

ការចិញ្ចឹមគ្រួចសាច់ត្រូវបានចែកជាពីរតំណាក់កាលគឺ :

១/ តំណាក់កាលទី១ : គឺអាយុពី ១-២៥ថ្ងៃ : ក្នុងតំណាក់កាលនេះ យើងត្រូវចិញ្ចឹម ដូចជា គ្រួចពងដែរ ។

២/តំណាក់កាលទី២ : គឺអាយុពី ១-២៥ថ្ងៃ : ក្នុងតំណាក់កាលនេះ ការចិញ្ចឹមគ្រួច គឺងាយស្រួលណាស់ ហើយការស្លាប់របស់វាគឺតិចណាស់ ព្រោះវាស៊ីច្រើនហើយឆាប់ធំ ។ ចូលមកដល់ តំណាក់កាលនេះ គ្រួចសាច់ត្រូវបានចិញ្ចឹមដោយចំណី ដែលសំបូរទៅដោយថាមពល ។

នៅពេលអោយវាស៊ី ពិសេសគឺគ្រួចសាច់ត្រូវអោយវាស៊ីដោយសេរី គឺទាំងថ្ងៃទាំងយប់។ ជាមួយគ្នានេះដែរ ត្រូវផ្តល់ទឹកអោយវាអោយបានគ្រប់គ្រាន់ ដើម្បីកុំអោយវាឡើងគរជាន់គ្នា ។ មិនត្រូវលាយថ្នាំពពួកអង់ទីប៊ីយ៉ូទិច ទៅក្នុងចំណីក្រួចសាច់ក្នុងតំណាក់កាលពី ៣៥-៤៥ថ្ងៃ ។ ពីព្រោះបណ្តាថ្នាំ ពពួកអង់ទីប៊ីយ៉ូទិចដូចជា : Chloramphenicol, Tetracyclin Furazolidon នឹងបន្សល់ទុកនៅក្នុងខ្លួនគ្រួច គ្មានប្រយោជន៍សំរាប់អ្នកបរិភោគ។

ផ្ទៃក្រឡាសំរាប់ចិញ្ចឹមគ្រួច ក្នុងតំណាក់កាល ពី ៣០-៤៥ថ្ងៃ គឺក្នុង១បន្ទប់ ពី៥០-១០០ក្បាល (៧០-៩០ក្បាល/ម) ។

## សមាសភាពចំណីសម្រាប់ក្រួចសាច់Protein ពី១២-២៤%

| ល.រ | សមាសភាពចំណីផ្សំ | រូបមន្តទី១ (១០ គក្រ) | រូបមន្តទី២ ( ១០ គក្រ ) |
|---|---|---|---|
| ១ | ពោតក្រហម | ៤ គក្រ | ៣. ៥ គក្រ |
| ២ | ចុងអង្ករ | ១. ០ គក្រ | គ្មាន |
| ៣ | កន្ទក់ម៉ត់ | ១. ០ គក្រ | ២. ៥ គក្រ |
| ៤ | ម្សៅត្រី | ១.០ គក្រ | ២.០ គក្រ |
| ៥ | ម្សៅសណ្តែកខៀវ | ១.៧ គក្រ | ១.៧ គក្រ |
| ៦ | ម្សៅសណ្តែកសៀង | ១.៧ គក្រ | ១.៧ គក្រ |
| ៧ | ម្សៅខ្យល ឬឆ្អឹង | ០. ២ គក្រ | ០. ២ គក្រ |
| ៨ | premix រ៉ែ | ០.០៥ គក្រ | ០.៥ គក្រ |
| ៩ | premix វីតាមីន | ០.០៥ គក្រ | ០.៥ គក្រ |
| ១០ | Vitamine A. D. E (១កញ្ចប់១០g ) | ៤ កញ្ចប់ | ៤ កញ្ចប់ |

ការជ្រើសរើសស៊ុតសំរាប់យកទៅភ្ញាស់ ត្រូវយកចេញពីហ្វូងចិញ្ចឹមដែលបានបំពេញគ្រប់គ្រាន់នូវជីវជាតិក្នុងចំណី ស៊ុតដែលមានឈ្មោលគ្រប់គ្រាន់ទៅតាមសមាមាត្រ ដែលបានកំនត់។ ស៊ុត ដែលទើបនឹងពងបាន ២-៣ថ្ងៃ (រដូវប្រាំង) ឯរដូវភ្លៀង និងរដូវត្រជាក់ គឺកុំអោយលើសពី ៥ ថ្ងៃ ។ ក្នុងពេលដែលពុំទាន់បានបញ្ចូលទៅក្នុងទូរភ្ញាស់ ស៊ុតត្រូវរក្សាទុកនៅកន្លែងដែលត្រជាក់ សីតុណ្ហភាពសមស្រេបតី ពី១៥-២០ °C និង សំណើម ៧០% ។ ត្រូវជ្រើសយកស៊ុតដែលមានរូបរាង អោយសមស្រេបតី : សំបកស្អាតល្អ មិនប្រេះ រីស្រាំមិនធំពេក និងមិនតូចពេក មិនមូលមិនស្តេច ពេក. មិនក្រខ្វក់ និងមិនប្រឡាក់ទឹក ។

ស៊ុតដែលយកទៅភ្ញាស់ ត្រូវយកពីកន្លែងដែលហ្វូងមានសុខភាពល្អ គ្មានជំងឺ ។ ប្រសិនបើយកមកពីកន្លែងផ្សេងៗ ត្រូវធ្វើការរំងាប់មេរោគជាមុនសិន ទើបយកទៅភ្ញាស់ ។

## ២.ការភ្ញាស់ស៊ុត :

ក/ការភ្ញាស់ស៊ុតដោយធម្មជាតិ : គឺយើងអោយមេមាន់ រឺព្រាបជាអ្នកភ្ញាស់ ។ មិនមាន មេមាន់ណាដែលអាចភ្ញាស់ពងគ្រួចបាន ព្រោះពងគ្រួចតូច ងាយបែក ព្រោះមេមាន់មានទំងន់ធ្ងន់។ ក៏នៅមានអ្នកចិញ្ចឹមខ្លះ អោយមេមាន់ភ្ញាស់ពងគ្រួច ប៉ុន្តែយើងឃើញថាសមាមាត្រនៃការបែកច្រើន គឺរហូតទៅដល់ ២៥-៣០% ។ ការភ្ញាស់ស៊ុតគ្រួចដោយមេមាន់ យើងអាចជ្រើសរើសយកមេមាន់ដែលតូចដូចមាន់ថៃ ហើយយើងអាចភ្ញាស់បាន ពី២០-៣០ពង ។

ចំពោះព្រាប វាក៏អាចភ្ញាស់ស៊ុតគ្រួចបានដែរ គឺព្រាបមេមួយអាចភ្ញាស់ ៤ពងច្រើនបំផុត ។

ខ/ការភ្ញាស់ស៊ុតដោយម៉ាស៊ីនភ្ញាស់អគ្គិសនីៈ

ម៉ាស៊ីនសម្រាប់ភ្ញាស់គ្រួចមាន ច្រើនប្រភេទ។

នៅក្នុងម៉ាស៊ីនភ្ញាស់អគ្គិសនី មានប្រព័ន្ធសម្រួលសីតុណ្ហភាព និងសំណើមដោយស្វ័យប្រវត្តិ។

- សីតុណ្ហភាពពី ១-១៣ថ្ងៃ គឺ ៣៧.២ °C - ៣៨ °C និង សំណើម ៦០%
- សីតុណ្ហភាពពី ១៤-១៦ថ្ងៃ គឺ ៣៧.២ °C - ៣៨ °C និង សំណើម ៧០%

ក្រោយពេលដាក់ភ្ញាស់បាន៣ថ្ងៃ យើងត្រូវចាប់ផ្តើមបង្វិលស៊ុត ១ដងនៅពេលព្រឹក តាមកាលកំណត់មួយច្បាស់លាស់ ។ នៅថ្ងៃទី៣ រហូតដល់ថ្ងៃទី៨ ត្រូវអោយមានខ្យល់ចូលទៅក្នុងម៉ាស៊ិន ភ្ញាស់រយៈពេល ៣នាទី ។ លុះថ្ងៃបន្ទាប់មកទៀត ត្រូវបង្កើនរយៈពេលពី ១៥-២០នាទី ។

គ/របៀបឆ្លុះស៊ុត : ក្នុងតំណាក់កាលភ្ញាស់ស៊ុត យើងត្រូវឆ្លុះស៊ុតចំនួន២ដង ។

- ការឆ្លុះដំបូង គឺនៅថ្ងៃទី៥ ដើម្បីជំរុះចោលនូវស៊ុតដែលគ្មានកំណកំណើត ។
- លើកទី២ គឺនៅថ្ងៃទី១១ ដើម្បីជំរុះចោលនូវស៊ុត ដែលមានកូនងាប់ ។

នៅពេលយើងធ្វើការឆ្លុះស៊ុត គប្បីប្រើចរន្តពន្លឺខ្លាំងដើម្បីងាយស្រួលក្នុងការឆ្លុះ។ ស៊ុតដែលគ្មានកំនកំណើត ពេលនោះយើងឃើញមានពណ៌សថ្លា ឯស៊ុតដែលមានកំនកំនើតយើងឃើញមាន បណ្តាញសរសៃឈាម និងមានអំប្រីយ៉ុងតូច។ ស៊ុតដែលដាក់ភ្ញាស់រហូតដល់ថ្ងៃទី១៥ ទើបវាចាប់ ផ្តើមចោះសំបក ដូច្នេះយើងពុំចាំបាច់បង្វិលវាទៀតទេ។ លុះដល់ព្រឹកថ្ងៃទី១៦ យើងបង្កើនសំណើម "អោយដល់៨០% ដើម្បីអោយកូនគ្រួចងាយស្រួលក្នុងការញាស់ និងជៀសវាងពេលវាញាស់មកកុំ អោយរោមស្អិតជាប់នឹងសំបក ។

រយៈពេលដែលកូនត្រូចញាស់ចេញមក គឺអូសបន្លាយពី២០-៣០ម៉ោង ក្រោយពេលដែលវារីព្រាបជាអ្នកភ្ញាស់។ មិនមាន ព្រោះមេមាន់មានទំងន់ធ្ងន់ ។ ថាសមាមាត្រនៃការបែកច្រើន ងអាចជ្រើសរើសយកមេមាន់ជំងឺឆ្លង ។

- ❑ ប្រសិនបើសីតុណ្ហភាពភ្ញាស់ខ្ពស់ពេក នោះអំប្រ៊ីយ៉ុងមានការលូតលាស់ខ្លាំង រហ័សចឹកសំបក ។ ប៉ុន្តែតាមធម្មតាកូនច្រើនស្ថិតជាប់នឹងសំបក មិនអាចញាស់ចេញរួច ហើយស្លាប់ក្នុងស៊ុត។
- ❑ ប្រសិនបើសីតុណ្ហភាពភ្ញាស់ទាបពេកនោះ នឹងនាំអោយអំប្រ៊ីយ៉ុងមានការលូតលាស់យឺតរោមជាប់នឹងសំបកពោះធំ កូនត្រូចដែលញាស់ចេញមកមានសភាពខ្សោយ និងមួយចំនួនទៀតគឺ ងាប់នៅក្នុងស៊ុត ។
- ❑ ចំណីសំរាប់ត្រូចពង ប្រសិនបើខ្វះ Vitamine $B_1$. D នោះធ្វើអោយអំប្រ៊ីយ៉ុងស្លាប់នៅ ថ្ងៃទី ១១ រឺកូនត្រូចអាចខ្វិន ។ បើខ្វះ Vitamine A នោះកូនត្រូចឈឺភ្នែក និងខ្វាក់ភ្នែក ។
- ❑ ប្រសិនបើស៊ុតដែលយកទៅភ្ញាស់ទុកក្នុងរយៈពេលយូរថ្ងៃ នោះអំប្រ៊ីយ៉ុងនឹងឈប់លូតលាស់នៅតំណាក់កាលពី ១១-១៦ថ្ងៃ។ ប្រសិនបើញាស់ចេញមក គឺមានសភាពខ្សោយ ហើយ សមាមាត្រនៃការញាស់គឺទាប ។

IVការសិក្សាជំងឺមួយចំនួនដែលធ្លាប់កើតនៅលើត្រូច :

- ❑ ត្រូចសាច់ និង ត្រូចពងពុំសូវមានជំងឺទេ បើប្រៀបធៀបនឹងមាន់។ ប៉ុន្តែមិនមានន័យថា ត្រូច គ្មានកើតជំងឺនោះទេ ពីព្រោះត្រូចក៏ជាប្រភេទបក្សីដែរ ទើបត្រូចក៏នៅតែមានជំងឺដូចជាសត្វស្លាប ដែរ ។

**ជំងឺ Salmonellosis**

- ❑ នេះគឺជាជំងឺឆ្លងមួយ ដែលបង្កឡើងដោយបាក់តេរី Salmonella ។ ជំងឺនេះអាចលេចចេញ នៅពេលដែលត្រូចទើបនឹងញាស់ និងពេលដែលត្រូចកំពុងពង។ មេរោគឆ្លងតាមរយៈចំណីអាហារ ទឹកផឹកចូលទៅក្នុងខ្លួនសត្វ ។ ជាមួយគ្នានេះដែរ មេរោគអាចឆ្លង

តាមរយៈមេទៅដល់ស៊ុត ធ្វើអោយ អំប្រីយ៉ុងត្រូវស្លាប់ ចាប់ពីពេលដែលដាក់ភ្ញាស់ រឺអំប្រីយ៉ុងមិនងាប់នោះ វានឹងឆ្លងជំងឺភ្លាមនៅពេល វាអាយុបាន១ថ្ងៃ ។

១.រោគសញ្ញាៈ ចំពោះកូនក្រូច ធម្មតាឃើញលាមករាគមានពណ៌ស ឈររញ៉ីរញ៉ៃ បើក ភ្នែកត្រឹម ១ ជើងស្ពួត ជ្រុះរោម ធ្លាក់ស្លាប និងស្លាប់ ។

ចំពោះហ្វូងគ្រូចពង យើងឃើញសមាមាត្ររបស់ស៊ុតមានការថយចុះ ពី១០-៣០% ស៊ីតិច សំកុក លាមករាវ និងមានពណ៌ស ស៊ុតមានជាប់ឈាម រាងស្ពួច និងទន់ រួចស្លាប់ ។

២.ការវះពិនិត្យជំងឺ :

- ថ្លើមស្លេក និងប្រែពណ៌
- ប្រម៉ាត់ហើមធំ
- ពោះវៀនចេញឈាម និងហើម
- កន្ទោមពងស្វិត

៣.របៀបការការពារ និងព្យាបាល :

ក/ការការពារ : យើងអាចប្រើ Chloramphenicol ជាមួយនិង Terramycine i

Neotesol លាយចូលទឹកផឹក រឺចំណី ។

- កូនគ្រូចសាច់ ពី ២-៣៥ថ្ងៃ (១អាទិត្យប្រើ ៤ថ្ងៃ សំរាក ៣ថ្ងៃ ) Chloramphenicol : 250g / 1 លីត្រទឹក ( ១គ្រាប់ 250g) Tetramycine : 250g/1លីត្រទឹក ( ១គ្រាប់ 250g)រំ គិនអោយម៉ត់ ២គ្រាប់ថ្នាខាងលើ លាយចូលទឹក ១លីត្រអោយវាផឹករយៈពេល ៤ថ្ងៃជាប់គ្នា។ ក្រៅពីប្រភេទថ្នាំទាំង ២ខាងលើ យើងអាចប្រើប្រភេទថ្នាំដូចខាងក្រោម :
- Neotesol 2,5g / 1 លីត្រទឹក (1/½ ស្លាបព្រាកាហ្វេ )
- Amfuridon 6g/1លីត្រទឹក

- ❑ Neo- Terramycine 500g / 1លីត្រទឹក
- ❑ Chlotetrasoli Neocylin 2,5ml/1 លីត្រទឹក
- ❑ Dexamylone 2,5g/1លីត្រទឹក

កំរិតថ្នាំដែលបានរៀបរាប់ដូចខាងលើ យើងអាចលាយក្នុងទឹកផឹកចំនួន ៤ថ្ងៃជាប់គ្នា បន្ទាប់ មកសំរាក ៣ថ្ងៃ។ យើងអាចប្រើរយៈពេល ៦អាទិត្យចំពោះក្រួចសាច់ ចំណែកគ្រួចពងវិញយើង អាចប្រើរហូតក្នុង ១វដ្តនៃរយៈពេលពងរបស់វា។ ប៉ុន្តែក្នុងអាទិត្យនិមួយៗ យើងប្រើថ្នាំសំរាប់ការ ពាររយៈពេល ៣ថ្ងៃ និងសំរាក ៤ថ្ងៃ ។

ខ/ ការព្យាបាលៈ : យើងអាចប្រើមួយ ក្នុងចំណោមពពួកអង់ទីប៊ីយ៉ូទិចខាងលើ ប៉ុន្តែករិត ដែលប្រើគឺត្រូវបង្កើនទ្វេដង នៃករិតការពារ និងត្រូវព្យាបាលក្នុងរយៈពេល ៥-៧ថ្ងៃទើបឈប់។

បណ្តាអង់ទីប៊ីយ៉ូទិចខាងលើ ប្រើក្នុងការព្យាបាលគឺមានប្រសិទ្ធភាព។

ជំងឺ C. R. D (Chronic Respiratory)

គឺជាជំងឺឆ្លងមួយដ៏សាហាវ ដែលបង្កឡើងដោយ បាក់តេរីឈ្មោះ Mycoplasma ។ ជំងឺ C. R. D ធ្វើអោយរលាកប្រព័ន្ធផ្លូវដង្ហើម គឺចាប់ពីច្រមុះ បំពង់ខ្យល់ ធ្វើអោយគ្រួចពិបាកដក ដង្ហើម ស៊ីតិចថយពងធំឃើត រួចហើយក៏ស្លាប់។ ជំងឺឆ្លងតាមផ្លូវដង្ហើម និងឆ្លងតាមរយៈស៊ុត ប៉ុន្តែសំខាន់បំផុតគឺសំបកស៊ុតមានឆ្លងមេរោគ រី ពេលដែលញាស់ចេញមក កូនគ្រួចហិតត្រូវមេរោគ ទើបឆ្លងជំងឺ ។

មេរោគនេះឆ្លងរាលដាល និងជាពិសេសនៅក្នុងតំណាក់កាល ដែលកូនក្រួចមានអាយុ២-៦អាទិត្យ ។ ចំណែកគ្រួចពង ក៏អាចកើតនូវជំងឺនេះដែរ ជាពិសេសនៅរដូវដែលមានភ្លៀងធ្លាក់ ។

១.រោគសញ្ញា : កូនីគ្រួចបន្ថយនូវការស៊ីចំណីមានហៀរទឹកសំបោរតាមច្រមុះស្រែកខ្វេកៗ និងសមាមាត្រនៃការផ្តល់ស៊ុត មានការថយចុះពី ៥-២០% ។

២.ការវះពិនិត្យ : យើងវះតាមបណ្តោយផ្លូវដង្ហើម គឺចាប់ពីច្រមុះរហូតទៅដល់សួត យើង ឃើញមានទឹករំអិលដែលមានស្លេសជាច្រើន និងកូនថង់សួតហើមប៉ោង។

៣.វិធានការការពារ និងព្យាបាល :

ក/ ការការពារ : ប្រើពពួកអង់ទីប៊ីយ៉ូទិច លាយទៅក្នុងទឹកផឹក ៤ថ្ងៃ/អាទិត្យ ដូចការ ការពារជំងឺ Salmonellosis ដែរ គឺចាប់ពីអាទិត្យទី១-អាទិត្យទី៦ ។

- Suanovil (5): 8ml / 1 លីត្រទឹក
- Suanovil (50): 0,5g / 1 លីត្រទឹក
- Tylan (50) : 5ml / 1 លីត្រទឹក
- Dibiotic : 1g/1លីត្រទឹក
- T. T.S : 2,5g / 1លីត្រទឹក (T. T.S : Tylosin, Trimethoprim, Sulfadiazin)

- យើងអាចប្រើថ្នាំសំអាតទ្រុង ដើម្បីការពារសំឡាប់មេរោគ។
- ខ/ ការព្យាបាល់ : យើងអាចប្រើពពួកអង់ទីប៊ីយ៉ូទិច ដែលប្រើសំរាប់ការពារដូចខាងលើ ប៉ុន្តែត្រូវប្រើក្នុងកំរិតទ្វេដង។
- Tylan (50) :10 / 1លីត្រទឹក អោយផឹកក្នុងរយះពេល ពី ៥-៧ថ្ងៃជាប់គ្នា ។
- T. T.S : 5g / 1 លីត្រទឹក អោយផឹកក្នុងរយៈពេល ពី ៥-៧ថ្ងៃជាប់គ្នា។

# ចប់ដោយបរិបូរណ៍